Disability Rights California

California's protection & advocacy system

# Disability Rights California ឯកសារណែនាំពីការជួយខ្លួនឯងសម្រាប់អ្នកជួលកំពុងប្រឈមនឹងការបណ្តេញចេញ

*ឧសភា 2021, Pub.#7168.06 - Cambodian*

ឯកសារណែនាំនេះផ្តល់ព័ត៌មានទូទៅដើម្បីជួយដល់គូក្តីតំណាងដោយខ្លួនឯង (អ្នកដែលឡើងតុលាការដោយគ្មានមេធាវី) យល់ពីដំណើរការឃាឃាំងដោយខុសច្បាប់ (ហៅម្យ៉ាងទៀតថា "ការបណ្តេញចេញ")។ ដំណើរការឃាឃាំងដោយខុសច្បាប់ គឺជាដំណើរការដែលម្ចាស់ផ្ទះជួលត្រូវតែអនុវត្តតាមដើម្បីបណ្តេញអ្នកជួលចេញពីផ្ទះ។ ទោះជាឯកសារណែនាំនេះមិនគ្របទៅលើអ្វីៗគ្រប់យ៉ាងស្តីពីសកម្មភាពឃាឃាំងដោយខុសច្បាប់ក៏ពិតមែន តែវាត្រូវបានរៀបចំឡើងដើម្បីជួយផ្តល់ជាចំណេះដឹងមូលដ្ឋានអំពីសិទ្ធិរបស់អ្នកជួលក្នុងអំឡុងដំណើរការដែរ។ មាតិកា (នៅទំព័រទី1 និង 2) និងគំនូសតាងលំហូរដំណើរការឃាឃាំងដោយខុសច្បាប់ និងការពិពណ៌នាពីខ្លឹមសារ (នៅទំព័រទី 3 ដល់ទី 5) ផ្តល់នូវសេចក្តីយោងរួម ដើម្បីជាសំអាងនៅពេលអ្នកមើលឯកសារណែនាំនេះ។

ប្រសិនបើអ្នកជាអ្នកជួលដែលត្រូវការជំនួយ អ្នកអាចទាក់ទងមកកាន់មជ្ឈមណ្ឌលជួយខ្លួនឯងរបស់តុលាការក្នុងមូលដ្ឋានរបស់អ្នក ដែលជាកន្លែងអ្នកអាចទទួលបានជំនួយរៀបចំបំពេញទម្រង់បែបបទតុលាការ រួមទាំងជំនួយដែលចាំបាច់ទាំងឡាយនៅក្នុងការឃាយាំងដោយខុសច្បាប់ផងដែរ។ មជ្ឈមណ្ឌលជួយខ្លួនឯងរបស់តុលាការមិនអាចផ្តល់ដល់អ្នកនូវការប្រឹក្សាផ្នែកច្បាប់បានទេ ប៉ុន្តែវាអាចផ្តល់អ្នកនូវព័ត៌មានអំពីអង្គភាពផ្នែកច្បាប់ផ្សេងទៀត ដែលអាចនឹងជួយតំណាងអ្នក ឬផ្តល់ដល់អ្នកនូវការប្រឹក្សាផ្នែកច្បាប់បាន។

រកមើលគេហទំព័ររបស់តុលាការក្នុងមូលដ្ឋានរបស់អ្នក និងព័ត៌មានអំពីមជ្ឈមណ្ឌលជួយខ្លួនឯងនៅទីនេះ៖ https://www.courts.ca.gov/find-my-court.htm?query=browse_courts.

សម្គាល់៖ ពេលខ្លះនៅក្នុងរឿងក្តីបណ្តេញចេញទាំងឡាយ ម្ចាស់ផ្ទះអាចមានជួលមេធាវីដើម្បីតំណាងឲ្យពួកគេ។ ដោយសារតែបែបនេះហើយ ទើបនៅក្នុងឯកសារណែនាំទាំងមូល ពាក្យ "ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះ" នឹងត្រូវប្រើប្រាស់ក្នុងន័យម្ចាស់ផ្ទះ ប្រសិនបើម្ចាស់ផ្ទះមិនមានមេធាវី ឬមេធាវីម្ចាស់ផ្ទះប្រសិនបើម្ចាស់ផ្ទះពិតជាមានមេធាវីនោះ។

Disability Rights California ប្តេជ្ញាឲ្យចំពោះការទទួលបានឱកាសនិងការទទួលស្គាល់ស្មើគ្នានៃអ្នកកែភេទ/អ្នកមានភេទខុសៗគ្នា/អ្នកស្រឡាញ់ភេទដូចគ្នា។ យើងប្រើសព្វនាម "ពួកគេ/ពួកគេ/របស់ពួកគេ" នៅក្នុងឯកសារនេះ ដើម្បីរួមបញ្ចូលពលរដ្ឋកាលីហ្វ័រញ៉ាទាំងអស់។

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្តល់ប្រឹក្សាផ្នែកច្បាប់ទេ ហើយក៏មិនមែនជាការជំនួសឲ្យការប្រឹក្សាផ្នែកច្បាប់ដែរ។

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្តល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្តល់យោបល់ផ្នែកច្បាប់ដែរ។

## មាតិកា

1. ទិដ្ឋភាពទូទៅ ....................................................................................5
1.A. គំនូសតាងលំហូរដំណើរការបណ្ដេញចេញ (ការឃាត់ឃាំងដោយខុសច្បាប់)....................................................................................5
1.B. កំណែបរិយាយពីដំណើរការបណ្ដេញចេញ (ការឃាត់ឃាំងដោយខុសច្បាប់)....................................................................................6
2. ការឆ្លើយតបទៅនឹងការកោះហៅនិងពាក្យបណ្ដឹង – ចម្លើយនិងទម្រង់បែបបទតុលាការផ្សេងទៀត....................................................................................10
ចម្លើយ៖ ....................................................................................10
ឯកសារភ្ជាប់ទៅនឹងបណ្ដឹងឆ្លើយតប (មិនតម្រូវ)....................................................................................11
ភ័ស្តុតាងបញ្ជាក់ពីសេវាកម្ម៖....................................................................................12
ការទាមទារឲ្យមានការជំនុំជម្រះដោយគណៈវិនិច្ឆ័យ៖ ....................................................................................12
សំណើសុំការលើកលែងប្រាក់ប្រដាប់ក្ដី ....................................................................................14
កន្លែងរកជំនួយ៖ ....................................................................................14
តើមានអ្វីកើតឡើងក្រោយពីអ្នកជួលដាក់បណ្ដឹងឆ្លើយតបរបស់គេរួច? .......15
3. ការដោះស្រាយបញ្ហា និងការសម្រុះសម្រួល ....................................................................................16
អ្វីទៅជាការដោះស្រាយបញ្ហា និងតើខ្ញុំអាចស្នើសុំបានតាមរបៀបណា?.....16
ឧទាហរណ៍ពីការព្រមព្រៀងដោះស្រាយបញ្ហាដែលគេនិយមប្រើ៖.............18
ប្រសិនបើការដោះស្រាយបញ្ហាមិនសម្រេចបានទេនោះ - ការសង្គ្រោះពីការរឹបអូសនិងការពន្យាពេលអនុវត្តដីកាបង្គាប់តុលា....................................................................................21
តើអ្វីទៅជាការដោះស្រាយជម្លោះតាមជម្រើស និងការសម្រុះសម្រួល? ......22
ថ្លៃចំណាយ ....................................................................................22

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្ដល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្ដល់យោបល់ផ្នែកច្បាប់ដែរ។

តើអ្នកជួលដឹងបានដោយរបៀបណាថាការសម្រុះសម្រួល ឬ សេវាដោះស្រាយជម្លោះមួយផ្សេងទៀតត្រូវបានផ្តល់ឲ្យ ឬ តម្រូវនៅតុលាការរបស់ខ្លួននោះ? ....... 23
តើនឹងមានអ្វីកើតឡើងនៅក្នុងអំឡុងពេលសម្រុះសម្រួល? ....... 23
ព័ត៌មានសម្ងាត់ ....... 23
តើនរណាជាអ្នកសម្រុះសម្រួល? ....... 23
តើអ្វីទៅជាលទ្ធផលនៃការសម្រុះសម្រួល? ....... 24
ហេតុអ្វីត្រូវចូលរួមក្នុងការសម្រុះសម្រួល? ....... 25
ចុះបើក្នុងករណីដែលអ្នកជួលត្រូវការការទទួលសមស្របមួយដើម្បីចូលរួមនៅក្នុងការសម្រុះសម្រួល? ....... 25
4. ការដោះដូរព័ត៌មានរវាងគូក្តី ....... 26
ពេលវេលាកំណត់ពីការដោះដូរព័ត៌មានក្រោមបទបណ្តោញចេញ ....... 26
តើអ្នកជួលបញ្ជូនចម្លើយរបស់គេទៅកាន់សំណើរដោះដូរព័ត៌មានបានតាមរបៀបណា? ....... 27
តើមានអ្វីកើតឡើងក្នុងករណីដែលភាគីម្ខាងមិនឆ្លើយតបទៅនឹងសំណើរដោះដូរព័ត៌មាន ឬធ្វើការឆ្លើយតបមិនត្រឹមត្រូវនោះ? ....... 28
តើអ្នកជួលមានពេលច្រើនប៉ុណ្ណាដើម្បីឆ្លើយតបទៅនឹងសំណើសុំដោះដូរព័ត៌មាន? ....... 28
តើចំណុចនៃការឆ្លើយតបក្នុងការដោះដូរព័ត៌មានជាអ្វី? ....... 28
តើប្រភេទខុសៗគ្នានៃការដោះដូរព័ត៌មានមានអ្វីខ្លះ? ....... 29
ការទទួលសមស្រប៖ ....... 33
ការបដិសេធទៅនឹងសំណើសុំដោះដូរព័ត៌មាន ....... 34
6. A. ការជំនុំជម្រះក្តី - សេចក្តីផ្តើម ....... 39
ការជំនុំជម្រះដោយចៅក្រម ឬការជំនុំជម្រះដោយគណៈវិនិច្ឆ័យ? ....... 39
អ្វីដែលត្រូវធ្វើនៅមុនការជំនុំជម្រះក្តី ....... 40

ព័ត៌មានជាមូលដ្ឋានពីបន្ទប់សវនាការ....................................................43
អ្វីខ្លះដែលត្រូវយកទៅជាមួយទៅកាន់ការជំនុំជម្រះក្តី.................................45
ការចុះឈ្មោះនិងការនិយាយស្តីនៅក្នុងតុលាការ – វប្បធម៌បន្ទប់សវនាការ..47
6. B. ការជំនុំជម្រះក្តី – ជាជំហានៗ....................................................50
តើនរណាជានរណា ហើយអ្វីកើតឡើងនៅពេលណា?...............................50
ផ្នែក 1 - ករណីរបស់ម្ចាស់ផ្ទះ..............................................................51
ផ្នែក 2 - ករណីរបស់អ្នកជួលៈ.............................................................57
ផ្នែក 3 – ទឡ្ហីករណ៍បិទបញ្ចប់ ...........................................................66
7. ការសម្រេចចុងក្រោយនិងអ្វីដែលកើតឡើងបន្ទាប់..................................67
សេចក្តីថ្លែងសម្រេចក្តី..........................................................................67
"សាលក្រម" ឬ "ដីកា"..........................................................................67
ឈ្នះ ឬ ចាញ់ អ្វីទៅបន្ទាប់? ..................................................................68
សេចក្តីជូនដំណឹងពីការចាកចេញ ..........................................................70
8. ការទទួលសមស្របនៅក្នុងតុលាការៈ....................................................73
តើការទទួលសមស្របនៅក្នុងតុលាការជាអ្វី?............................................73
ហេតុអ្វីបានជាអ្នកជួលអាចនឹងចាំបាច់ត្រូវស្នើសុំនូវការទទួលមួយសមស្រប?
........................................................................................................73
តើអ្នកជួលស្នើសុំនូវការទទួលសមស្របមួយតាមរបៀបណា?....................74
តើនេះវាខុសអ្វីពីការទទួលសមស្របនៅខាងក្រៅតុលាការនោះ?..............74

# 1. ទិដ្ឋភាពទូទៅ

## 1.A. គំនូសតាងលំហូរដំណើរការបណ្តេញចេញ (ការឃាយឃាំងដោយខុសច្បាប់)

សម្គាល់៖ ផ្នែកនេះរៀបរាប់ពីអ្វីដែលត្រូវបានសន្និដ្ឋានថាកើតឡើងនៅពេលដែលម្ចាស់ផ្ទះអនុវត្តច្បាប់បណ្តេញចេញ។ ប្រសិនបើអ្នកមិនប្រាកដថើតើម្ចាស់ផ្ទះរបស់អ្នកកំពុងតែអនុវត្តតាមច្បាប់បណ្តេញចេញឬអត់នោះ អ្នកគួរតែពិភាក្សាជាមួយនឹងមេធាវីការពាររឿងក្តីការបណ្តេញចេញ។

**ការជូនដំណឹង** – មុនពេលដែលម្ចាស់ផ្ទះដាក់បណ្តឹងរឿងក្តីការឃាយឃាំងដោយខុសច្បាប់ទៅតុលា ពួកគេត្រូវតែផ្តល់ដល់អ្នកជួលនូវការជូនដំណឹងជាលាយលក្ខណ៍អក្សរ។ ការជូនដំណឹងផ្តល់ពេលវេលាក្នុងចំនួនជាក់លាក់ ចន្លោះពី 3-90 ថ្ងៃ ដើម្បីអនុវត្តសកម្មភាព ដូចជាការទូទាត់សងថ្លៃឈ្នួលដែលជំពាក់ ផ្សះផ្សាការរំលោភបំពានលើការជួល ឬ ការបណ្តេញចេញពីលំនៅដ្ឋានជាដើម។

↓

**សវនការ និង បណ្តឹង** – សំណុំឯកសារតុលាការ ដែលត្រូវផ្តល់ជូនអ្នកជួល ឬសមាជិកគ្រួសារមុនពេលដែលម្ចាស់ផ្ទះអាចចាប់ផ្តើមរឿងក្តីតុលាការពីបទឃាយឃាំងដោយខុសច្បាប់បាន។ ឯកសារទាំងនេះមិនគួរបញ្ជូនចេញក្រោយផុតកំណត់ការជូនដំណឹងទេ។

អ្នកជួលមានរយៈពេលប្រាំថ្ងៃផ្តល់ដោយតុលាការដើម្បីធ្វើការឆ្លើយតប!

**ចម្លើយ**

**ការដោះស្រាយ** – អាចកើតឡើងមុន ឬក្នុងអំឡុង

**គ្មានចម្លើយ**

**ការជំនំជម្រះ** - ក្នុងរយៈពេល 10ថ្ងៃនៃការដាក់ពាក្យស្នើសុំចម្លើយ គួរទទួលបានលិខិតដោយមានកាលបរិច្ឆេទតុលាការ ការជំនុំជម្រះនឹងត្រូវកំណត់ឡើងក្នុងរយៈពេល 21ថ្ងៃ។

អាចនឹងមានការពន្យាពេលអនុវត្តដីកាបង្គាប់តុលាការ និង ការធ្វើមោឃភាពនៃសាលក្រមកំបាំងមុខ

**សាលក្រមកំបាំងមុខ**

ឈ្នះក្តី

ចាញ់ក្តី → **ចាក់សោរបិទ**

**ស្នាក់នៅនិងបង់ថ្លៃឈ្នួលដែលជំពាក់**

**ការចាក់សោរបិទ** – រយៈពេល 7-9 ថ្ងៃក្រោយ, ប៉ូលីសនឹងបិទសេចក្តីជូនដំណឹងដើម្បីឲ្យចាកចេញ។ រយៈពេល 5-7 ថ្ងៃក្រោយ ប៉ូលីសនឹងត្រឡប់មកវិញ ហើយបង្ខំឲ្យគ្រប់គ្នាចាកចេញក្នុងរយៈពេល 5 នាទី។ អ្នកជួលនឹងមិនត្រូវបានផ្តល់ពេលឲ្យរៀបចំអីវ៉ាន់ឡើយ។

*ថ្ងៃកំណត់ដោយតុលាការមិនរាប់បញ្ចូលថ្ងៃសៅរ៍ ថ្ងៃអាទិត្យ និងថ្ងៃសម្រាករបស់តុលាការទេ។
ថ្ងៃទី0 = ថ្ងៃដែលអ្នកជួលចូលនៅ ចំណែកថ្ងៃទី1 = ថ្ងៃបន្ទាប់។
ប្រសិនបើថ្ងៃចូលនៅផ្ទាល់ខ្លួន – រយៈពេលថ្ងៃ 5 តុលាការ
ប្រសិនបើសេវាត្រូវបានជំនួសដោយសមាជិកក្នុងបន្ទុកគ្រួសារ – រយពេល 10 ថ្ងៃតាមប្រតិទិន + រយៈពេល 5ថ្ងៃតុលាការ
ប្រសិនបើត្រូវបានបិទផ្សាយនៅលើលំនៅដ្ឋានរបស់អ្នកជួល និងផ្ញើតាមសំបុត្រ – រយៈពេល 10ថ្ងៃតាមប្រតិទិន + រយៈពេល 5 កំណត់ដោយតុលាការ

1.B. កំណែបរិយាយពីដំណើរការបណ្តេញចេញ (ការឃាយាំងដោយខុសច្បាប់)

សម្គាល់៖ ផ្នែកនេះរៀបរាប់ពីអ្វីដែលត្រូវបានសន្មតថាកើតឡើងនៅពេលម្ចាស់ផ្ទះអនុវត្តច្បាប់បណ្តេញចេញ។ ប្រសិនបើអ្នកមិនប្រាកដថាតើម្ចាស់ផ្ទះរបស់អ្នកនឹងអនុវត្តតាមច្បាប់បណ្តេញចេញ ឬអត់នោះ អ្នកគួរតែពិភាក្សាជាមួយនឹងមេធាវីការពារក្តីករណីបណ្តេញចេញ។

**ជំហានទី 1 ការជូនដំណឹងពីម្ចាស់ផ្ទះ** – មុនពេលដែលម្ចាស់ផ្ទះដាក់បណ្តឹងពីការបណ្តេញចេញទៅកាន់តុលាការនោះ ពួកគេត្រូវតែផ្តល់ដល់អ្នកជួលនូវការជូនដំណឹងជាលាយលក្ខណ៍អក្សរ។ ការជូនដំណឹងផ្តល់ពេលវេលាក្នុងចំនួនជាក់លាក់ ចន្លោះពី 3-90 ថ្ងៃ ដើម្បីអនុវត្តសកម្មភាព ដូចជាការទូទាត់សងថ្លៃឈ្នួលដែលនៅជំពាក់ "ផ្សះផ្សា" (ជួសជុល) ការបំពានលើកិច្ចសន្យាជួល ឬ "ចាកចេញ" (រើចេញ) ពីលំនៅដ្ឋាន។ ប្រសិនបើអ្នកមានសំណួរអំពីការការពារការបណ្តេញចេញក្នុងស្ថានភាព COVID-19 ដោយសារតែមិនបានបង់ប្រាក់ឈ្នួលនោះ និងវិធានជូនដំណឹងពិសេសនោះ សូមចូលមើល៖
https://www.disabilityrightsca.org/post/coronavirus-housing

**ជំហានទី 2 ការកោះហៅ និង បណ្តឹង** – ទាំងនេះជាសំណុំឯកសារតុលាការដែលត្រូវ "បញ្ជូនទៅឲ្យ" (ផ្តល់ជូន) អ្នកជួល ឬសមាជិកគ្រួសារមុនពេលដែលម្ចាស់ផ្ទះអាចចាប់ផ្តើមដំណើរការរឿងក្តីតុលាការពីការបណ្តេញចេញបាន។ ឯកសារទាំងនេះមិនគួរបញ្ជូនទៅឲ្យក្រោយផុតកំណត់ការជូនដំណឹងឡើយ។ ការក្រើនរម្លឹក – នៅពេលអ្នកជួលទទួលបានការកោះហៅ និងពាក្យបណ្តឹងហើយអ្នកជួលមានពេល **5ថ្ងៃតុលាការ*** ដើម្បីឆ្លើយតបដោយ "ចម្លើយ" មួយដែលជាទម្រង់បែបបទតុលាការ ហើយដាក់វានៅតុលាការ។ មជ្ឈមណ្ឌលជួយខ្លួនឯងរបស់តុលាការក្នុងមូលដ្ឋាន អាចជួយដល់អ្នកជួលក្នុងការបំពេញទម្រង់នេះបាន។ គេហទំព័រតុលាការក្នុងមូលដ្ឋាន និងព័ត៌មានទំនាក់ទំនង អាច

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្តល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្តល់យោបល់ផ្នែកច្បាប់ដែរ។

រកបាននៅទីនេះ៖ https://www.courts.ca.gov/find-my-court.htm?query=browse_courts

*ថ្ងៃតុលាការមិនរាប់បញ្ចូលថ្ងៃសៅរ៍ ថ្ងៃអាទិត្យ និងថ្ងៃឈប់សម្រាករបស់តុលាការទេ។ ថ្ងៃទី0 = ថ្ងៃដែលអ្នកជួលចូលនៅ ចំណែកថ្ងៃទី1 = ថ្ងៃបន្ទាប់។ ប្រសិនបើបញ្ជូនមកដោយផ្ទាល់ខ្លួន អ្នកជួលមានពេល 5ថ្ងៃតុលាការដើម្បីធ្វើការឆ្លើយតប។ ប្រសិនបើពាក្យបណ្ដឹងនិងការកោះហៅត្រូវបានបញ្ជូនទៅកាន់សមាជិកក្នុងបន្ទុកគ្រួសារ ("សេវានៃដំណើរការ") 10ថ្ងៃលើប្រតិទិន + 5ថ្ងៃកំណត់ដោយតុលាការ ដើម្បីដាក់បណ្ដឹងឆ្លើយតប។ ប្រសិនបើត្រូវបានបិទនៅលើលំនៅដ្ឋានរបស់អ្នកជួល និងបញ្ជូនតាមសំបុត្រនោះ 10ថ្ងៃលើប្រតិទិន + 5ថ្ងៃកំណត់ដោយតុលាការ ដើម្បីដាក់បណ្ដឹងឆ្លើយតប។

**ជំហាន 3.A. ក្នុងករណីដែលអ្នកជួលមិនបានដាក់បណ្ដឹងឆ្លើយតប – សាលក្រមកំបាំងមុខ និងការចាក់សោរបិទ។**

សាលក្រមកំបាំងមុខអាចត្រូវបានចេញដោយតុលាការប្រឆាំងចំពោះអ្នកជួលក្នុងករណីដែលពួកគេមិនបានដាក់បណ្ដឹងឆ្លើយតបទៅនឹងពាក្យបណ្ដឹងនិងការកោះហៅទេនោះ។ នេះមានន័យថា អ្នកជួលត្រូវបានបណ្ដេញចេញដោយស្វ័យប្រវត្តិដោយមិនចាំបាច់មានសវនការឡើយ។ ក្នុងរយៈពេល 7-9 ថ្ងៃក្រោយសាលក្រមកំបាំងមុខ ប៉ូលីសនឹងបិទសេចក្តីជូនដំណឹងឲ្យរើចេញ ហើយ 5-7 ថ្ងៃក្រោយមក ប៉ូលីសនឹងត្រឡប់មកវិញនិងបង្ខំឲ្យមនុស្សគ្រប់គ្នាចាកចេញក្នុង រយៈពេល 5នាទី។ អ្នកជួលនឹងមិនត្រូវបានផ្ដល់ពេលវាលាឲ្យរៀបចំអីវ៉ាន់ឡើយ។ អាចនឹងមានទម្រង់នៃការសង្គ្រោះ ដែលគេហៅថា "ការពន្យាពេលអនុវត្តដីកាបង្គាប់តុលាការ" និង "ការធ្វើមោឃភាព" ក្នុងករណីមានហេតុផលផ្នែកច្បាប់ចំពោះមូលហេតុបណ្ដេញចេញមិនគួរត្រូវអនុវត្តឡើយ។ ទោះជាយ៉ាង

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្ដល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្ដល់យោបល់ផ្នែកច្បាប់ដែរ។

ណា ទម្រង់នៃការសង្គ្រោះទាំងនេះមានលក្ខណៈកម្រ និងជាហេតុការណ៍ជាក់លាក់ ដូច្នេះអ្នកជួលគប្បីពិភាក្សាជាមួយមេធាវីផ្នែកការបណ្តេញចេញ។

**ជំហាន 3.B. ប្រសិនបើអ្នកជួលបានដាក់បណ្ដឹងឆ្លើយតប – ការដោះស្រាយបញ្ចប់ ឬ ការជំនុំជម្រះក្ដី**

**ការដោះស្រាយបញ្ចប់** – អ្នកជួលនិងម្ចាស់ផ្ទះធ្វើការព្រមព្រៀងគ្នាមួយ។
ឬ
**ការជំនុំជម្រះ** - ជាទូទៅក្នុងរយៈពេល 10ថ្ងៃនៃការដាក់បណ្ដឹងឆ្លើយតប អ្នកជួលគួរទទួលបានលិខិតមួយច្បាប់ដោយមានកាលបរិច្ឆេទកំណត់ដោយតុលាការ។ អង្គជំនុំជម្រះនឹងត្រូវកំណត់ប្រហែល 21ថ្ងៃក្រោយពីអ្នកជួលបានដាក់បណ្ដឹងឆ្លើយតប។ ទោះជាយ៉ាងណា អ្នកជួលមិនគួរសន្មតថា ពួកគេនឹងទទួលបាននូវការជូនដំណឹងភ្លាមៗនោះទេ ដូច្នេះពួកគេគួរតែសាកសួរមកតុលាការជាមុនដើម្បីឲ្យដឹងពីកាលបរិច្ឆេទសវនាការ។

**ប្រសិនបើអ្នកជួលចាញ់ក្ដី – អ្នកជួលត្រូវបានចាក់សោរមិនឱ្យចូល** – នីតិវិធីបិទជូនដំណឹងនិងពេលវេលាកំណត់ការចាក់សោរបិទដូចគ្នានេះ ត្រូវបានរៀបរាប់ស្ថិតនៅក្រោមជំហាន 3.A.

**ប្រសិនបើអ្នកជួលឈ្នះក្ដី – អ្នកជួលបន្តស្នាក់នៅនិងបង់ថ្លៃឈ្នួលដែលបានជំពាក់។**

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្ដល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្ដល់យោបល់ផ្នែកច្បាប់ដែរ។

## 2. ការឆ្លើយតបទៅនឹងការកោះហៅនិងពាក្យបណ្តឹង – ចម្លើយនិងទម្រង់បែបបទតុលាការផ្សេងទៀត

ផ្នែកនេះពន្យល់ពីទម្រង់បែបបទ ដែលច្រើនដាក់មកតុលាការក្រោយពីអ្នកជួលទទួលបានការកោះហៅនិងពាក្យបណ្តឹង។ ក៏មានផងដែរនូវតំណភ្ជាប់ ដែលផ្តល់នូវធនធានបន្ថែមពីរបៀបបំពេញទម្រង់បែបបទ និងទីកន្លែងទៅស្នើសុំជំនួយបន្ថែម។ ផ្នែកនេះនឹងផ្តល់នូវព័ត៌មានបន្ថែមពីទម្រង់បែបបទដូចខាងក្រោម៖

- ចម្លើយ
- ឯកសារភ្ជាប់ទៅនឹងចម្លើយ (មិនតម្រូវ)
- ភ័ស្តុតាងបញ្ជាក់ពីសេវាកម្ម
- ការទាមទារឲ្យមានគណៈវិនិច្ឆ័យក្តី (មិនតម្រូវ)
- ការលើកលែងប្រាក់ប្រដាប់ក្តី (មិនតម្រូវ)

<u>ចម្លើយ៖</u>

ដើម្បីឆ្លើយតបចំពោះការទាមទាររបស់ម្ចាស់ផ្ទះប្រឆាំងនឹងពួកគេនៅក្នុងការកោះហៅនិងពាក្យបណ្តឹងនោះ អ្នកជួលអាចដាក់ "បណ្តឹងឆ្លើយតប" មួយនៅតុលាការដើម្បី៖

- បដិសេធរាល់ការលើកឡើងដោយមិនត្រឹមត្រូវធ្វើឡើងដោយម្ចាស់ផ្ទះរបស់គេនៅក្នុងពាក្យបណ្តឹង និង
- បញ្ជាក់ពីការការពារទាំងឡាយណា ដែលពួកគេអាចមានចំពោះការបណ្តេញចេញ។

ប្រសិនបើគ្មានការឆ្លើយតបចំពោះបណ្តឹងត្រូវបានដាក់នោះ ចៅក្រម ឬ ក្រឡាបញ្ជីអាចចេញសាលក្រមកំបាំងមុខ ហើយប្រហែលជា 12-14ថ្ងៃក្រោយមក ប៉ូលីសអាចចាក់សោរមិនឲ្យអ្នកជួលចេញចូលផ្ទះរបស់គេ។

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្តល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្តល់យោបល់ផ្នែកច្បាប់ដែរ។

តុលាការបានបង្កើតទម្រង់បណ្តឹងឆ្លើយតបមួយ។ ទម្រង់បែបបទទំនេរ អាចស្វែងរកបាននៅទីនេះ៖ https://selfhelp.courts.ca.gov/jcc-form/UD-105.

សេចក្តីណែនាំលម្អិតពីការបំពេញទម្រង់បណ្តឹងឆ្លើយតបអាចរកបាននៅទីនេះ៖ https://www.disabilityrightsca.org/system/files/file-attachments/Link_4_UD_105_Instructions.pdf, នៅក្នុងឯកសារណែនាំរបស់យើងអំពីការឆ្លើយតបទៅនឹងបណ្តឹងបណ្តេញចេញ អាចរកបាននៅទីនេះ៖ https://www.disabilityrightsca.org/publications/fact-sheet-how-to-answer-an-eviction-lawsuit.

វីដេអូណែនាំខ្លីតាមអនឡាញ ដែលបង្ហាញដល់អ្នកជួលពីរបៀបបំពេញទម្រង់ចម្លើយ អាចរកបាននៅទីនេះ៖ https://www.youtube.com/watch?v=NZNb3WVFo8s.

នៅពេលអ្នកជួលដាក់បណ្តឹងឆ្លើយតបនៅតុលាការ អ្នកជួល "បញ្ជូន" ឬ យកទៅជូនបណ្តឹងឆ្លើយតបរបស់គេមួយច្បាប់ទៅកាន់ម្ចាស់ផ្ទះរបស់ពួកគេ (សូមមើលផ្នែក "ភ័ស្តុតាងបញ្ជាក់ពីសេវាកម្ម" ខាងក្រោម)។

ឯកសារភ្ជាប់ទៅនឹងបណ្តឹងឆ្លើយតប (មិនតម្រូវ)

អ្នកជួលខ្លះដាក់បន្ថែមនូវការការពារផ្នែកច្បាប់ដែលមិនត្រូវបានរាយនៅលើទម្រង់បែបបទបណ្តឹងឆ្លើយតបរបស់តុលាការ ដោយការដាក់ឯកសារភ្ជាប់ជាមួយនឹងបណ្តឹងឆ្លើយតបរបស់គេ។ ទម្រង់ឯកសារភ្ជាប់ អាចស្វែងរកបាននៅទីនេះ៖ ឯកសារភ្ជាប់ 3l ឯកសារភ្ជាប់ទូទាំងរដ្ឋ (pdf)។ ក្រោយពិនិត្យឯកសារភ្ជាប់និងការការពារដោយប្រុងប្រយ័ត្នរួចមក អ្នកជួលអាចគូសក្នុងប្រអប់ដែលសមស្របសម្រាប់ពួកគេ។ ឯកសារក្នុងទម្រង់ PDF ក៏អាចរកបាននៅក្នុងឯកសារណែនាំរបស់ DRC ពីរបៀបឆ្លើយតបទៅនឹងបណ្តឹងបណ្តេញចេញបាននៅទីនេះដែរ៖ https://www.disabilityrightsca.org/publications/fact-sheet-how-to-answer-an-eviction-lawsuit.

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្តល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្តល់យោបល់ផ្នែកច្បាប់ដែរ។

ភស្តុតាងបញ្ជាក់ពីសេវាកម្ម៖

បណ្តឹងឆ្លើយតបមួយច្បាប់ចាំបាច់ត្រូវបញ្ជូន (យកទៅប្រគល់ឲ្យ) ទៅដល់ម្ចាស់ផ្ទះ ឬ មេធាវីរបស់ម្ចាស់ផ្ទះ។ នៅក្នុងរដ្ឋកាលីហ្វ័រញ៉ា អ្នកជួលអាចបញ្ជូនឯកសារទៅកាន់ម្ចាស់ផ្ទះរបស់គេតាមសំបុត្របាន។ សេវាកម្មចាំបាច់ត្រូវធ្វើឡើងដោយនរណាម្នាក់ដែលមានអាយុលើសពី 18ឆ្នាំ ដែលមិនពាក់ព័ន្ធនៅក្នុងពាក្យបណ្តឹងបណ្តេញចេញទេ។ បុគ្គលនោះចាំបាច់ត្រូវបំពេញនិងចុះហត្ថលេខាលើទម្រង់ "បញ្ជាក់ភស្តុតាងពីសេវាកម្ម"។

ទម្រង់បែបបទទំនេរ "បញ្ជាក់ភស្តុតាងពីសេវាកម្ម" អាចស្វែងរកបាននៅទីនេះ៖ https://selfhelp.courts.ca.gov/jcc-form/POS-030. សេចក្តីណែនាំលម្អិតអំពីការបំពេញទម្រង់បែបបទ "បញ្ជាក់ភស្តុតាងពីសេវាកម្ម" នេះ អាចរកបាននៅខាងក្រោយនៃទម្រង់បែបបទបញ្ជាក់ភស្តុតាងពីសេវាកម្ម និងក៏មាននៅទីនេះដែរ៖ https://www.disabilityrightsca.org/system/files/file-attachments/Link_7_POS_Instructions.pdf.

**ប្រយ័ត្ន៖** ក្រោយបំពេញសេវាចប់ អ្នកជួលចាំបាច់ត្រូវដាក់ទាំងទម្រង់បែបបទ "បញ្ជាក់ភស្តុតាងពីសេវាកម្ម" និង "បណ្តឹងឆ្លើយតប" ច្បាប់ដើមនៅតុលាការ។

ការទាមទារឲ្យមានការជំនុំជម្រះដោយគណៈវិនិច្ឆ័យ៖

អ្នកជួលមានជម្រើសឲ្យរឿងក្តីរបស់គេត្រូវបានសម្រេចដោយគណៈវិនិច្ឆ័យដែលជាក្រុមមនុស្សមួយក្រុមមកពីសាធារណៈជន ដែលសម្រេចក្តី ឬ សម្រេចដោយអង្គចៅក្រម។ អង្គជំនុំជម្រះដោយមានគណៈវិនិច្ឆ័យ ត្រូវបានហៅថា អង្គជំនុំជម្រះ គណៈវិនិច្ឆ័យ ហើយអ្នកជួលដែលចង់បានការជំនុំជម្រះដោយ  គណៈវិនិច្ឆ័យ ត្រូវតែស្នើសុំជាមុន។ អង្គជំនុំជម្រះត្រូវសម្រេចឡើងដោយចៅក្រម និងគ្មានគណៈវិនិច្ឆ័យត្រូវបានហៅថាការជំនុំជម្រះដោយ" ចៅក្រម"។ មានទាំងគុណសម្បត្តិនិងគុណវិបត្តិចំពោះការជំនុំជម្រះដោយ

គណៈវិនិច្ឆ័យ និងការជំនុំជម្រះដោយចៅក្រម។ ប្រសិនបើអ្នកជួលមិនច្បាស់ថាត្រូវជ្រើសរើសយកមួយណានោះ ពួកគេអាចពិភាក្សាជាមួយមេធាវីការពារក្តីការបណ្តេញចេញបាន។

ប្រសិនបើអ្នកជួលចង់បានគណៈវិនិច្ឆ័យជាងចៅក្រមនោះ ឲ្យសម្រេចលើលទ្ធផលនៃរឿងក្តីរបស់គេនោះ ពួកគេអាចស្នើសុំឲ្យមានការជំនុំជម្រះរបស់គណៈវិនិច្ឆ័យនៅក្នុង "បណ្តឹងឆ្លើយតប" របស់ពួកគេ ឬ ពួកគេអាចដាក់ឯកសារដាច់ដោយឡែកបាន។ នេះជាទម្រង់ស្តង់ដារបស់តុលាការដើម្បីស្នើសុំការជំនុំជំរះដោយគណៈវិនិច្ឆ័យ៖ [https://selfhelp.courts.ca.gov/jcc-form/UD-150](https://selfhelp.courts.ca.gov/jcc-form/UD-150). ទម្រង់គំរូឯកសារជា Word ដែលអាចប្រើប្រាស់បានដើម្បីស្នើសុំអង្គជំនុំជម្រះគណៈវិនិច្ឆ័យត្រូវភ្ជាប់នៅទីនេះ៖ [ទម្រង់គំរូសុំឲ្យមានការជំនុំជម្រះដោយគណៈវិនិច្ឆ័យ (docx)](#)។ **អ្នកជួលអាចបំពេញនៅក្នុងវង់ក្រចកនិងផ្នែកបញ្ជាក់ដោយពណ៌ ហើយកែសម្រួលទម្រង់បែបបទទាំងពីរមុននឹងដាក់នៅតុលាការ។**

ប្រសិនបើអ្នកជួលសម្រេចស្នើសុំការជំនុំជម្រះគណៈវិនិច្ឆ័យនៅក្នុងឯកសារដាច់ដោយឡែក ជាជាងនៅក្នុងបណ្តឹងឆ្លើយតបរបស់គេ ពួកគេនឹងចាំបាច់ត្រូវបញ្ជូនមួយច្បាប់នៃឯកសារនេះទៅកាន់ម្ចាស់ផ្ទះរបស់គេ ឬមេធាវីម្ចាស់ផ្ទះរបស់ពួកគេ ហើយដាក់ច្បាប់ដើមនៅតុលាការ។ សូមមើលផ្នែក "បញ្ជាក់ភ័ស្តុតាងពីសេវាកម្ម" ខាងលើសម្រាប់ការណែនាំនានាពីរបៀបបំពេញសេវា និងរៀបចំ ហើយដាក់ការបញ្ជាក់ភ័ស្តុតាងពីសេវាកម្ម និងរៀបចំ និងដាក់ទម្រង់បែបបទភ័ស្តុតាងសេវាកម្ម។

## សំណើសុំការលើកលែងប្រាក់ប្រដាប់ក្ដី៖

មានការចំណាយលើតុលាការដែលចាំបាច់ត្រូវបង់ដើម្បីដាក់ឯកសារនៅតុលាការ។ អ្នកជួលអាចស្នើសុំការលើកលែងប្រាក់ប្រដាប់ក្ដី ប្រសិនបើពួកគេអាចមានលទ្ធភាពបង់ប្រាក់ប្រដាប់ក្ដីដោយការបំពេញទម្រង់បែបបទចាំបាច់នានាបាន។

ច្បាប់ទំនេរនៃទម្រង់បែបបទលើកលែងប្រាក់ប្រដាប់ក្ដីទាំងបី អាចរកបាននៅទីនេះ៖
https://selfhelp.courts.ca.gov/jcc-form/FW-001;
https://selfhelp.courts.ca.gov/jcc-form/FW-002;
https://selfhelp.courts.ca.gov/jcc-form/FW-003.

សេចក្ដីណែនាំលម្អិតពីរបៀបបំពេញទម្រង់បែបបទទាំងនេះ អាចរកបាននៅទីនេះ៖
https://www.disabilityrightsca.org/system/files/file-attachments/Link_9_Instructions_on_FW_Forms.pdf.

សម្គាល់៖ ទម្រង់ "FW-002៖ សំណើសុំការលើកលែងប្រាក់ប្រដាប់ក្ដីបន្ថែម" គួរបំពេញ និងដាក់តែក្នុងករណីដែលអ្នកជួលស្នើសុំការជំនុំជម្រះក្ដីដោយគណៈវិនិច្ឆ័យ បើមិនអញ្ចឹងទេអ្នកជួលគ្រាន់តែដាក់ទម្រង់ "FW_001 សំណើរសុំលើកលែងប្រាក់ប្រដាប់ក្ដី" និង ទម្រង់ "FW_003 ដីការស្ដីពីការលើកលែងប្រាក់ប្រដាប់ក្ដី។"

សម្គាល់៖ អ្នកជួលពិតជាចាំបាច់ត្រូវបញ្ជូនទម្រង់បែបបទលើកលែងប្រាក់ប្រដាប់ក្ដីទៅកាន់ម្ចាស់ផ្ទះ ឬ មេធាវីម្ចាស់ផ្ទះ ពួកគេគ្រាន់តែដាក់ទម្រង់បែបបទទាំងនោះនៅតុលាការបានហើយ។

## កន្លែងរកជំនួយ៖

ប្រសិនបើអ្នកជួលត្រូវការជំនួយក្នុងការបំពេញបែបបទបណ្ដឹងឆ្លើយតបរបស់គេ ឬ ទម្រង់បែបបទណាមួយនោះ ពួកគេអាចទៅកាន់មជ្ឈមណ្ឌលជួយខ្លួនឯងក្នុង

មូលដ្ឋានរបស់តុលាការរបស់ពួកគេ ឬ អ្នកផ្តល់ជំនួយផ្នែកច្បាប់ការពារការរឿងក្តីបណ្តេញចេញ។

ព័ត៌មានទំនាក់ទំនងសម្រាប់តុលាការក្នុងមូលដ្ឋានអាចរកឃើញនៅទីនេះ៖ https://www.courts.ca.gov/find-my-court.htm?query=browse_courts.

សន្លឹកបញ្ជូនបន្តសម្រាប់ជំនួយផ្នែកច្បាប់ការពារការបណ្តេញចេញ អាចរកបាននៅទីនេះ៖ https://www.disabilityrightsca.org/system/files/file-attachments/Link_13_Housing_Law_List_2020-with_SR_edits.pdf.

## តើមានអ្វីកើតឡើងក្រោយពីអ្នកជួលដាក់បណ្តឹងឆ្លើយតបរបស់គេរួច?

ក្នុងរយៈពេល 10ថ្ងៃនៃការដាក់បណ្តឹងឆ្លើយតប អ្នកជួលគួរទទួលបានលិខិតមួយច្បាប់ដោយមានកាលបរិច្ឆេទតុលាការ។ អង្គជំនុំជម្រះរបស់គេនឹងត្រូវកំណត់ឡើងក្នុងរយៈពេលប្រហែល 21ថ្ងៃ។ ក្រោយមក ពាក្យបណ្តឹងបណ្តេញចេញជាទូទៅនឹងត្រូវបានដោះស្រាយដោយទាំងតាមការសម្រុះសម្រួល ឬ តាមការជំនុំជម្រះ។ សូមមើលផ្នែកទាំងឡាយដូចខាងក្រោម ដើម្បីរៀនបន្ថែមអំពីដំណើរការនីមួយៗនៃដំណើរការទាំងនេះ។

## 3. ការដោះស្រាយបញ្ចប់ និងការសម្រុះសម្រួល

នៅក្នុងផ្នែកនេះផ្តល់ព័ត៌មានអំពីរបៀបបីយ៉ាង ដែលបណ្តឹងតុលាការពីបទបណ្តេញចេញអាចត្រូវបានដោះស្រាយដោយពុំចាំបាច់ទៅដល់ការជំនុំជម្រះក្តី – ការដោះស្រាយបញ្ចប់ ដំណោះស្រាយជម្លោះតាមការជ្រើសរើស និងការសម្រុះសម្រួល។ ដំណើរការទាំងបីនេះ អាចជាឧបករណ៍ដ៏មានប្រយោជន៍សម្រាប់ភាគីទាំងពីរនៅក្នុងដំណើរការបណ្តេញចេញឈានទៅដល់ការព្រមព្រៀងគ្នាមួយដោយពុំត្រូវឆ្លងកាត់ការតឹងតែងអារម្មណ៍ ការចំណាយពេល និងភាពមិនច្បាស់លាស់នៃការជំនុំជម្រះក្តី។ នៅក្នុងផ្នែកនេះចាប់ផ្តើមដោយការរៀបរាប់ពីអ្វីដែលជាការដោះស្រាយបញ្ហា របៀបស្វែងរកការព្រមព្រៀងដោះស្រាយបញ្ចប់មួយបញ្ហាទាំងឡាយត្រូវពិចារណានៅពេលចូលដល់ការព្រមព្រៀងការដោះស្រាយបញ្ចប់មួយ និងឧទាហរណ៍ពីការដោះស្រាយបញ្ចប់ទូទៅមួយចំនួន។ ផ្នែកនេះបញ្ចប់ដោយមានទម្រង់បែបបទមួយចំនួនដែលអាចមាននៃការសង្គ្រោះ ប្រសិនបើការដោះស្រាយបញ្ចប់មិនសម្រេចនោះ ហើយព័ត៌មានអំពីដំណោះស្រាយជម្លោះតាមជម្រើស និងការសម្រុះសម្រួល។

<u>អ្វីទៅជាការដោះស្រាយបញ្ចប់ និងតើខ្ញុំអាចស្នើសុំបានតាមរបៀបណា?</u>

ការព្រមព្រៀងដោះស្រាយបញ្ចប់ គឺជាមធ្យោបាយមួយដែលគូភាគី – នៅក្នុងករណីនេះ អ្នកជួលនិងម្ចាស់ផ្ទះរបស់គេនៅក្នុងពាក្យបណ្តឹងករណីបណ្តេញចេញ – អាចដោះស្រាយពាក្យបណ្តឹងបានដោយខ្លួនគេ ជំនួសឲ្យការមានចៅក្រម ឬ គណៈវិនិច្ឆ័យនៅឯការជំនុំជម្រះ។

តុលាការមួយចំនួនតម្រូវឲ្យគូភាគីចូលរួមនៅក្នុងអ្វីមួយដែលគេហៅថា "សន្និសិទ្ធដោះស្រាយបិទបញ្ចប់តាមការកំណត់" ដែលជាទូទៅកើតឡើងមុនពេលការជំនុំជម្រះក្តីចាប់ផ្តើមឡើង។ សន្និសីទ្ធដោះស្រាយបញ្ចប់តាមការកំណត់អាចមានលក្ខណៈមិនផ្លូវការ។ ឧទាហរណ៍ វាអាចជាការសន្ទនាគ្នាប្រាំ

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្តល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្តល់យោបល់ផ្នែកច្បាប់ដែរ។

នាទីរវាងគូភាគីនៅតាមផ្លូវដើរក្នុងបន្ទប់ខាងក្រៅបន្ទប់សវនាការ។ ឬ វាអាចមានលក្ខណៈផ្លូវការជាងនេះ ហើយធ្វើឡើងនៅក្នុងបន្ទប់សវនាការជាមួយចៅក្រមដឹកនាំឲ្យមានការសន្ទនាគ្នា។

ពីព្រោះតែម្ចាស់ផ្ទះ ដែលជាអ្នកបានចាប់ផ្តើមនូវដំណើរការបណ្តេញចេញ ជាធម្មតាបានវិនិយោគទឹកប្រាក់នៅក្នុងដំណើរការនេះ – ដោយការបង់ប្រាក់ប្រដាប់ក្តី និងអាចមានបង់ថ្លៃមេធាវី – វាមិនងាយនឹងឃើញមានខាងម្ចាស់ផ្ទះទៅសុំការដោះស្រាយបញ្ចប់ជាមួយអ្នកជួលដោយខ្លួនគេផ្ទាល់នោះទេ។ ទោះជាយ៉ាងណា វាអាចមានប្រយោជន៍ដល់ម្ចាស់ផ្ទះត្រូវដោះស្រាយបញ្ចប់ ជំនួសឲ្យការចំណាយប្រាក់ច្រើនថែមទៀតទៅលើការជំនុំជម្រះនោះ។ ដោយសារតែហេតុផលទាំងនេះហើយ ប្រសិនបើអ្នកជួលចាប់អារម្មណ៍ក្នុងការដោះស្រាយបញ្ចប់រឿងក្តីជំនួសឲ្យការតតាំងគ្នានៅសវនការនោះ អ្នកជួលអាចទៅរកម្ចាស់ផ្ទះដើម្បីស្នើសុំការដោះស្រាយបញ្ចប់បាន។ បើទោះជាតុលាការតម្រូវឲ្យមានសន្និសីទដោះស្រាយបញ្ចប់តាមការកំណត់មួយក៏ពិតមែន ក៏អ្នកជួលនៅតែអាចដោះស្រាយបញ្ចប់រឿងក្តីជាមួយម្ចាស់ផ្ទះរបស់ខ្លួនមុនពេលសន្និសីទចាប់ផ្តើមបានដែរ។

ការចរចារដោះស្រាយបញ្ចប់ អាចចាប់ផ្តើមឡើងដោយការសន្ទនាក្រៅផ្លូវការ ឬដោយការផ្តល់ឲ្យមួយដែលចាប់ផ្តើមឲ្យគូភាគីទាំងសងខាងបញ្ជូនឲ្យគ្នាទៅវិញទៅមកនូវការផ្តល់ជូន។ ឧទាហរណ៍ អ្នកជួលអាចផ្តល់នូវសម្បទានមួយ ហើយម្ចាស់ផ្ទះ ឬមេធាវីតំណាងឲ្យម្ចាស់ផ្ទះ នឹងឆ្លើយតបដោយការយល់ព្រម ឬ មិនយល់ព្រម។ ម្ចាស់ផ្ទះក៏អាចផ្តល់នូវសម្បទានឆ្លើយតបទៅនឹងសម្បទានផ្តល់ដោយអ្នកជួលវិញ ហើយអ្នកជួលអាចទទួលយកសម្បទាននេះ បដិសេធសម្បទាននេះ ឬ ផ្តល់នូវសម្បទានឆ្លើយរបស់គេផ្ទាល់វិញ។

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្តល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្តល់យោបល់ផ្នែកច្បាប់ដែរ។

ពីព្រោះតែវាមានលក្ខណៈងាយស្រួលជាងសម្រាប់គូភាគី ត្រូវដឹងពីអ្វីដែលភាគីទាំងសងខាងបានសន្យាត្រូវធ្វើ ប្រសិនបើវាមានជាលាយលក្ខណ៍អក្សរ អ្នកជួលនិងម្ចាស់ផ្ទះជាធម្មតាធ្វើកិច្ចព្រមព្រៀងរបស់គេជាលាយលក្ខណ៍អក្សរដោយរួមបញ្ចូលនូវរាល់លក្ខខណ្ឌសំខាន់ចំពោះពួកគេ និងត្រូវប្រាកដថា ទាំងអ្នកជួលនិងម្ចាស់ផ្ទះបានចុះហត្ថលេខាលើវា។ ធ្វើបែបនោះ ប្រសិនបើខាងណាមួយមិនធ្វើទៅតាមអ្វីដែលពួកគេបានព្រមព្រៀងគ្នាទេនោះ ភាគីម្ខាងទៀតអាចប្ដឹងទៅតុលាការឲ្យជួយ។ (សូមមើលខាងក្រោមសម្រាប់ឧទាហរណ៍ពីលក្ខខណ្ឌដោះស្រាយបញ្ចប់។)

ប្រសិនបើឃើញថា អ្នកជួលមិនមានលទ្ធភាពឈានដល់ការព្រមព្រៀងជាមួយនឹងម្ចាស់ផ្ទះរបស់គេទេនោះ ពួកគេអាចការពារខ្លួនពួកគេនៅឯអង្គជំនុំជម្រះក្ដីដោយមានចៅក្រម ឬគណៈវិនិច្ឆ័យបាន។ សម្គាល់ – ដោយសារតែក្រម §1152 បញ្ជាក់ភ័ស្តុតាងរដ្ឋកាលីហ្វ័រញ៉ានោះ ការផ្ដល់សម្បទានដល់ការដោះស្រាយបញ្ចប់រឿងក្ដីមិនអាចប្រើប្រឆាំងទៅនឹងនរណាម្នាក់នៅក្នុងតុលាការបានទេ។

<u>ឧទាហរណ៍ពីការព្រមព្រៀងដោះស្រាយបញ្ចប់ដែលគេនិយមប្រើ៖</u>

1. ការចរចារលើការរើចេញ៖ ប្រសិនបើអ្នកជួលចង់រើចេញ ទាំងនេះជាចំណុចមួយចំនួនត្រូវពិចារណានៅក្នុងការចរចារកិច្ចព្រមព្រៀងដោះស្រាយបញ្ចប់។
    - **ពេលវេលា៖** អ្នកជួលស្នើសុំពេលវេលាដែលគេត្រូវការដើម្បីរើចេញ ដោយសំអាងថាម្ចាស់ផ្ទះនឹងព្យាយាមចរចារបន្ថយពេលវេលាឲ្យនៅកាន់តែខ្លី។ ឧទាហរណ៍ – ប្រសិនបើអ្នកជួលអាចទំនងជារើចេញនៅក្នុងរយៈពេល 30ថ្ងៃនោះ អ្នកជួលអាចនឹងចង់ស្នើសុំរយៈពេល 60ថ្ងៃ។ ឬ ប្រសិនបើអ្នកជួលដឹងថា ពួកគេត្រូវការពេល 60ថ្ងៃនោះ ពួកគេអាចនឹងចង់ស្នើសុំរយៈពេល 90ថ្ងៃ។

- **ប្រាក់ឈ្នួលដល់ពេលត្រូវសងកន្លងមក៖** អ្នកជួលអាចចរចារសុំការលើកលែង ឬ ការអភ័យ ចំពោះប្រាក់ឈ្នួលដែលបានជំពាក់ ប្រាក់ឈ្នួលមេធាវី និងការចំណាយលើតុលាការ។ ពេលខ្លះម្ចាស់ផ្ទះគ្រាន់តែចង់ទទួលបានផ្ទះមកវិញ ហើយយល់ព្រមបោះបង់ចោលនូវថ្លៃឈ្នួលដែលអ្នកជួលជំពាក់ប្រសិនបើពួកគេរើចេញនោះ។ អ្នកជួលក៏អាចស្នើសុំម្ចាស់ផ្ទះឲ្យយល់ព្រមលើកលែងប្រាក់ឈ្នួលទាំងឡាយណាដែលពួកគេជំពាក់ ឧទាហរណ៍ក្នុងករណីដែលពួកគេមិនបានបង់ប្រាក់ឈ្នួលពីព្រោះតែផ្ទះរបស់គេមានសភាពមិនល្អសមស្រប ហើយម្ចាស់ផ្ទះមិនបានដោះស្រាយបញ្ហានោះ។
- **ប្រាក់កក់** អ្នកជួលអាចពិចារណាបោះបងប្រាក់កក់របស់គេជាការប្ដូរទៅនឹងការលើកលែង ឬការបញ្ចុះចំនួនទឹកប្រាក់នៃថ្លៃឈ្នួល ឬថ្លៃចំណាយផ្សេងទៀតដែលបានជំពាក់។
- **ពុំមានកំណត់ត្រាពីការបណ្ដេញចេញ៖** អ្នកជួលអាចចរចារដើម្បីឲ្យប្រាកដថាសំណុំរឿងរបស់ពួកគេត្រូវបានបិទបញ្ចប់។ នេះនឹងការពារមិនឲ្យរឿងក្ដីបណ្ដេញចេញបង្ហាញឡើងនៅលើសំណុំឯកសារសាធារណៈ និងការប៉ះពាល់ដល់គុណសម្បត្តិរបស់គេ ឬ ធ្វើឲ្យពួកគេពិបាករកជួលផ្ទះនាពេលអនាគត។

2. ការចរចារសុំទូទាត់និងបន្តស្នាក់នៅ៖

ប្រសិនបើអ្នកជួលចង់ស្នាក់នៅបន្ត ហើយហេតុផលសម្រាប់ការបណ្ដេញចេញនោះគឺដោយសារតែប្រាក់ឈ្នួលមិនបានបង់ ឬថ្លៃឈ្នួលផ្សេងទៀតនោះ អ្នកជួលនឹងទំនងជាត្រូវបង់នូវចំនួនទឹកប្រាក់ពេញ ឬការបង់ជាចំណែកនៃចំនួនប្រាក់ឈ្នួលដែលមិនទាន់បានបង់ ឬថ្លៃឈ្នួលផ្សេងទៀត ដើម្បីស្នាក់បន្តនៅក្នុងផ្ទះនោះ។

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្ដល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្ដល់យោបល់ផ្នែកច្បាប់ដែរ។

នៅក្នុងពាក្យបណ្តឹងបឋម ម្ចាស់ផ្ទះនឹងទំនងជាស្នើសុំឲ្យអ្នកជួលបង់ទាំងអស់ ឬ ភាគច្រើននៃចំនួនប្រាក់ឈ្នួលដែលមិនទាន់បានបង់ ព្រមទាំងថ្លៃចំណាយលើតុលាការ។ អ្នកជួលអាចមានសមត្ថភាពចរចារទាំងសុំការលើកលែង និង ការអភ័យនៃការចំណាយទាំងនេះ ឬបញ្ចុះចំនួនទឹកប្រាក់ត្រូវបង់។ នេះជាចំណុចមួយចំនួនត្រូវពិចារណានៅក្នុងប្រភេទនៃការចរចារទាំងនេះ៖

- **ការបង់ប្រាក់ឈ្នួលពេញ៖** អ្នកជួលអាចបង់ចំនួនទឹកប្រាក់ដែលបានស្នើសុំទាំងអស់ជាការជំនួសឲ្យការបណ្តេញចេញ។
- **ផែនការបង់ប្រាក់៖** អ្នកជួលអាចស្នើសុំផែនការបង់ប្រាក់ប្រសិនបើពួកគេមិនមានទឹកប្រាក់គ្រប់ចំនួនស្នើសុំទាំងអស់។ **ប្រយ័ត្ន** ប្រសិនបើអ្នកជួលខកខានបង់ប្រាក់ទៅតាមផែនការបង់ប្រាក់ ពួកគេអាចនឹងត្រូវបានបណ្តេញចេញដោយពុំមានជូនដំណឹងបន្ថែមទៀតឡើយ។
- **ការសុំការលើកលែង/ការអភ័យ៖** ម្ចាស់ផ្ទះទំនងជាអាចនឹងផ្តល់នូវការអភ័យដល់ប្រាក់ឈ្នួលត្រូវបង់កន្លងមក ថ្លៃឈ្នួលនានា និង ការចំណាយប្រសិនបើអ្នកជួលមានការការពារ ឬ ម្ចាស់ផ្ទះចង់រក្សាអ្នកជួលឲ្យស្នាក់នៅបន្ត។ ឧទាហរណ៍ ប្រសិនបើអ្នកជួលមិនបានបង់ថ្លៃឈ្នួលពីព្រោះតែផ្ទះរបស់គេមានសភាពមិនល្អ ហើយម្ចាស់ផ្ទះមិនបានដោះស្រាយបញ្ហាទាំឡាយនោះ អ្នកជួលអាចស្នើសុំម្ចាស់ផ្ទះឲ្យអនុញ្ញាតដល់ពួកគេបង់ប្រាក់ឈ្នួលតិចជាងមុនរហូតដល់ការជួសជុលត្រូវបានធ្វើឡើង ពេលនោះនឹងបង់ប្រាក់ឈ្នួលធម្មតារបស់គេឡើងវិញនៅពេលផ្ទះត្រូវបានជួសជុលរួច។
- **ពុំមានកំណត់ត្រាការបណ្តេញចេញ៖** អ្នកជួលអាចចរចារសុំការបដិសេធចូលតុលាការ ហើយសុំឲ្យតុលាការបិទបញ្ចប់សំណុំរឿងរបស់គេបាន។

**ប្រយ័ត្ន៖** ប្រសិនបើអ្នកជួលមិនអនុវត្តទៅតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងដោះស្រាយបិទបញ្ចប់ទេនោះ ពួកគេអាចនឹងត្រូវបណ្ដេញចេញ។

<u>ប្រសិនបើការដោះស្រាយបញ្ចប់មិនសម្រេចបានទេនោះ - ការសង្គ្រោះពីការរើបអូសនិងការពន្យាពេលអនុវត្តដីកាបង្គាប់តុលា</u>

ប្រសិនបើអ្នកជួលមិនអាចឈានដល់ការដោះស្រាយបញ្ចប់ទេ មុនការជំនុំជម្រះរបស់គេចាប់ផ្តើម ពួកគេនៅតែអាចស្នើសុំឲ្យតុលាការឲ្យគេអាចបង់អ្វីៗគ្រប់យ៉ាងដែលបានជំពាក់ ដើម្បីឲ្យគេអាចស្នាក់នៅបន្តក្នុងផ្ទះរបស់ពួកគេបាន។ ជាទូទៅគេស្នើសុំ "ការសង្គ្រោះពីការរើបអូស" (ក្រមនៃរដ្ឋប្បវេណី §1179) ប្រសិនបើពួកគេជួបការលំបាកលំបិន ប៉ុន្តែពុំមានការការពារផ្នែកច្បាប់ទេ។ ដើម្បីអាចទទួលបានសម្រាប់ការសង្គ្រោះនេះ អ្នកជួលត្រូវ៖

1. មានគ្រប់ចំនួនប្រាក់ឈ្នួលដែលខ្លួនបានជំពាក់ត្រឹមកាលបរិច្ឆេទជំនុំជម្រះក្តី
2. ត្រូវប្រាកដប្រជាពីសមត្ថភាពបង់ប្រាក់ឈ្នួលនាពេលអនាគត និង
3. ត្រូវតែអាចបង់ថ្លៃមេធាវី ថ្លៃចំណាយលើតុលាការ និងការចំណាយផ្សេងៗទៀត។

ប្រសិនបើអ្នកជួលមិនអាចឈានដល់ការដោះស្រាយបិទបញ្ចប់ទេនោះ អ្នកជួលក៏អាចស្នើសុំឱ្យតុលាការ "ពន្យាពេល" (ពន្យាការអនុវត្តដីកាបង្គាប់តុលាការ) ការបណ្តេញចេញរហូតទៅដល់ 40ថ្ងៃ ប៉ុន្តែម្ចាស់ផ្ទះអាចទាមទារឱ្យបង់ប្រាក់សម្រាប់រយៈពេល 40ថ្ងៃនោះ។ (CCP §1176.) សម្គាល់ អ្នកជួលនៅតែអាចស្នើសុំ "ការពន្យាពេលការអនុវត្តដីកាបង្គាប់តុលាការ" ប្រសិនបើម្ចាស់ផ្ទះមានវត្តមាននៅថ្ងៃជំនុំជម្រះ ឬ ពួកគេត្រូវបានផ្តល់ការជូនដំណឹងមុន (ការជូនដំណឹងជាលាយលក្ខណ៍អក្សរមុន) ទៅដល់ម្ចាស់ផ្ទះនោះ។ អ្នកជួលអាចសាកសួរពី

នីតិវិធីតុលាការក្នុងមូលដ្ឋានរបស់គេជាមួយនឹងក្រឡាបញ្ជី ឬនៅលើគេហទំព័រតុលាការក្នុងមូលដ្ឋានប្រសិនបើពួកគេមានសំណួរនានាអំពីរបៀបជូនដំណឹងសម្រាប់ "ការស្នាក់នៅបន្ត។" ប្រសិនបើអ្នកជួលស្នើសុំ "ការពន្យាពេលការអនុវត្តដីកាបង្គាប់តុលាការ" ដោយសារតែភាពលំបាកខ្លាំងនោះ អ្នកជួលគួរតែយកទៅជាមួយនូវឯកសារទាំងឡាយរបស់គេ និងភ័ស្តុតាងទាំងឡាយផ្សេងទៀតដែលបញ្ជាក់ពីភាពលំបាករបស់គេដល់តុលាការ។ ឧទាហរណ៍ អ្នកជួលអាចយកមកជាមួយនូវឯកសារពេទ្យបង្ហាញពីពេលវេលាដែលពួកគេស្ថិតនៅក្នុងមន្ទីរពេទ្យ។

## តើអ្វីទៅជាការដោះស្រាយជម្លោះតាមជម្រើស និងការសម្រុះសម្រួល?

ការដោះស្រាយជម្លោះតាមជម្រើស (ADR) ជាលក្ខខណ្ឌត្រូវបានប្រើសម្រាប់គ្រប់មធ្យោបាយទាំងអស់ដើម្បីដោះស្រាយរឿងក្ដីតុលាការ ដែលមិនរួមបញ្ចូលនូវការជំនុំជម្រះក្ដី ឬការសម្រេចរបស់តុលាការ។ ដំណើរការ ADR មួយចំនួនអាចគ្រាន់តែជម្រើស ឬ ក្រៅផ្លូវការបំផុត ដំណើរការផ្សេងៗទៀតអាចជាការចាប់បង្ខំ និងមានលក្ខណៈផ្លូវការ។

ការសម្រុះសម្រួល គឺជាប្រភេទមួយនៃជម្រើសដោះស្រាយជម្លោះ។ ការសម្រុះសម្រួលគឺជាការពិភាក្សាផ្លូវការជាមួយនឹងភាគីទាំងសងខាងនៃបណ្ដឹងតុលាការនៅក្នុងកិច្ចខិតខំប្រឹងប្រែងក្នុងបំណងដោះស្រាយរឿងក្ដីទាំងមូលឬដោយផ្នែកណាមួយ។

## ថ្លៃចំណាយ

ប្រសិនបើតុលាការផ្ដល់ការសម្រុះសម្រួលនោះ នឹងពុំមានចំណាយចំពោះការចូលរួមក្នុងការសម្រុះសម្រួលទេ។ ទោះជាយ៉ាងណា ប្រសិនបើម្ចាស់ផ្ទះនាំ

មេធាវីមកចូលរួមក្នុងការសម្រុះសម្រួលនោះ នេះនឹងបង្កើនថ្លៃមេធាវីដល់ម្ចាស់ដែលអ្នកជួលអាចនឹងជាអ្នកទទួលខុសត្រូវលើចំណាយនេះ។

<u>តើអ្នកជួលដឹងបានដោយរបៀបណាថាការសម្រុះសម្រួល ឬ សេវាដោះស្រាយជម្លោះមួយផ្សេងទៀតត្រូវបានផ្តល់ឲ្យ ឬ តម្រូវនៅតុលាការរបស់ខ្លួននោះ?</u>

អ្នកជួលគប្បីសាកសួរជាមួយមជ្ឈមណ្ឌលជួយខ្លួនឯងរបស់តុលាការក្នុងមូលដ្ឋានរបស់គេ ឬទីភ្នាក់ជំនួយផ្នែកច្បាប់ដើម្បីស្វែងយល់ពីការអនុវត្តក្នុងមូលដ្ឋានរបស់តុលាការរបស់ពួកគេ និងលក្ខខណ្ឌតម្រូវទាំងឡាយសម្រាប់ការសម្រុះសម្រួលដោយមានភាគីបីចូលរួម ឬទម្រង់ផ្លូវការផ្សេងទៀតនៃការដោះស្រាយជម្លោះតាមការជ្រើសរើស។

<u>តើនឹងមានអ្វីកើតឡើងនៅក្នុងអំឡុងពេលសម្រុះសម្រួល?</u>

អ្នកសម្រុះសម្រួលនឹងនិយាយទៅកាន់ភាគីទាំងសងខាង ដើម្បីជួយដល់ពួកគេឲ្យយល់ពីការមើលឃើញពីគ្នាទៅវិញទៅមក។ នៅពេលខ្លះ គូភាគីទាំងពីរអាចស្ថិតនៅក្នុងបន្ទប់ជាមួយគ្នានឹងអ្នកសម្របសម្រួល ពេលខ្លះទៀតមានតែភាគីម្ខាងទេដែលអាចស្ថិតនៅក្នុងបន្ទប់ជាមួយអ្នកសម្រុះសម្រួល។

<u>ព័ត៌មានសម្ងាត់</u>

ការពិភាក្សាក្នុងអំឡុងពេលសម្រុះសម្រួលមានលក្ខណៈសម្ងាត់ ហើយមិនអាចប្រើប្រាស់ដូចការសារភាពនៅក្នុងតុលាការទេ។ ករណីលើកលែងតែមួយគត់ចំពោះការពិភាក្សាដែលពាក់ព័ន្ធដល់តុលាការគឺក្នុងអំឡុងរឿងក្តីព្រហ្មទណ្ឌ។ ក្រមបញ្ញាក់ភស្តុតាងរដ្ឋកាលីហ្វ័រញ៉ា 1119។

<u>តើនរណាជាអ្នកសម្រុះសម្រួល?</u>

អ្នកសម្រុះសម្រួលគឺជាភាគីទីបីដែលទទួលបានការបណ្តុះបណ្តាលជាពិសេស។ អ្នកសម្រុះសម្រួលមិនមែនជាចៅក្រម ប៉ុន្តែពេលខ្លះជាមេធាវី។ បើទោះជាភាគីម្ខាងទៀតខុស 100% ហើយភាគីម្ខាងទៀតត្រូវ 100% ក៏ដោយ ក៏អ្នកសម្រុះសម្រួលនឹងមិនលំអៀងទៅរកភាគីណាមួយឡើយ។ អ្នកសម្រុះសម្រួលស្ថិតនៅជាអព្យាក្រឹត្យ។ អ្នកសម្រុះសម្រួលនឹងមិនសម្រេចទៅលើភាពត្រឹមត្រូវតាមច្បាប់ទាំងស្រុង ឬ ភាពយុត្តិធម៌នៃជម្លោះនោះទេ។ អ្នកសម្រុះសម្រួលនឹងសួរសំណួរដល់ភាគីនីមួយៗឱ្យព្យាយាមសម្រេចបាននូវការព្រមព្រៀងគ្នាមួយរវាងគូភាគីទាំងពីរ។

តើអ្វីទៅជាលទ្ធផលនៃការសម្រុះសម្រួល?

ដូចគ្នាទៅនឹងការដោះស្រាយបញ្ហាប់តាមការចរចារដែរ ប្រសិនបើអ្នកជួលឈានដល់ការព្រមព្រៀងមួយទៅលើជម្លោះទាំងស្រុងឬដោយផ្នែកនោះ វានឹងជាការប្រសើរបំផុតប្រសិនបើពួកគេរៀបចំការព្រមព្រៀងគ្នានោះជាលាយលក្ខណ៍អក្សរ។ ការព្រមព្រៀងគួរដាក់បញ្ចូលនូវលក្ខខណ្ឌទាំងឡាយស្តីពីរបៀបត្រូវដោះស្រាយបណ្តឹងតុលាការ (ឧទាហរណ៍ បញ្ចូលនូវលក្ខខណ្ឌទាំងឡាយស្តីពីការលុបចេញជាអចិន្ត្រៃយ៍នូវកំណត់ត្រាតុលាការស្តីពីការបណ្តេញចេញទៅតាមវិធានច្បាប់របស់តុលាការរដ្ឋកាលីហ្វ័រញ៉ា 2.551 បើទោះជាការសម្រុះសម្រួលធ្វើឡើងក្រៅបន្ទប់សវនាការក៏ដោយ)។ **ប្រយ័ត្ន** – អ្នកជួលមិនត្រូវទទួលយកលក្ខខណ្ឌដោះស្រាយបញ្ហាប់ទាំងឡាយណាដែលម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះ ឬ អ្នកសម្រុះសម្រួលស្នើឡើងនោះទេ។ ប្រសិនបើអ្នកជួលមិនឈានទៅដល់ ការព្រមព្រៀងមួយទេ រឿងក្តីរបស់គេនឹងបញ្ជូនត្រឡប់ទៅកាន់តុលាការប្រៀបដូចជាការសម្រុះសម្រួលពុំបានកើតឡើងអញ្ចឹងដែរ។

## ហេតុអ្វីត្រូវចូលរួមក្នុងការសម្រុះសម្រួល?

ប្រសិនបើអ្នកជួលមានការលំបាកលំបិនក្នុងការព្យាយាមដោះស្រាយរឿងក្តីរបស់គេជាមួយនឹងម្ចាស់របស់គេនោះ អ្នកសម្រុះសម្រួលអាចជួយដល់អ្នកជួលទំនាក់ទំនងជាមួយនឹងម្ចាស់ផ្ទះរបស់គេបាន។ ប្រសិនបើអ្នកជួលមិនឈានទៅដល់ការព្រមព្រៀងមួយទេ ពួកគេនៅតែអាចបន្តទៅកាន់ការជំនុំជម្រះបានដែរ។ បើទោះបីជាអ្នកជួលមិនឈានទៅដល់ការព្រមព្រៀងគ្នាមួយក៏ដោយ ក៏តាមរយៈដំណើរការសម្រុះសម្រួល អ្នកជួលអាចរៀនពីអ្វីដែលសំខាន់ចំពោះភាគីម្ខាងទៀតដើម្បីដោះស្រាយបណ្តឹងតុលាការ ដែលអាចនឹងជួយដល់អ្នកជួលឲ្យដោះស្រាយបញ្ហាប់បាននៅទីបំផុតដែរ។

## ចុះបើក្នុងករណីដែលអ្នកជួលត្រូវការការទទួលសមស្របមួយដើម្បីចូលរួមនៅក្នុងការសម្រុះសម្រួល?

ប្រសិនបើតុលាការរបស់អ្នកជួលផ្តល់នូវការសម្រុះសម្រួលវិញ ពួកគេអាចយោងទៅផ្នែកទី 7 ដែលមានចំណងជើង "ការទទួលសមស្របនៅក្នុងតុលាការ" នៅទំព័រទី 37។

## 4. ការដោះដូរព័ត៌មានរវាងគូក្តី

ការដោះដូរព័ត៌មានរវាងគូក្តី គឺជាពាក្យសម្រាប់ដំណើរការផ្នែកច្បាប់នៅក្នុងបណ្តឹងតុលាការ ដែលនៅក្នុងករណីនេះអ្នកជួលនិងម្ចាស់ផ្ទះ សុំឯកសារ ព័ត៌មាន និងការបញ្ជាក់ការពិតឱ្យគ្នាទៅវិញទៅមក។ គូភាគីទាំងពីរនៅក្នុងបណ្តឹងតុលាការចង់បានព័ត៌មាននេះពីគ្នា ដើម្បីឲ្យពួកគេអាចប្រើវានៅឯសវនាការ ដើម្បីព្យាយាម និងបញ្ជាក់ពីភ័ស្តុតាងដល់ករណីរបស់គេ ឬ ប្រើវាដើម្បីព្យាយាមចរចារការដោះស្រាយបញ្ចប់នៅមុនការជំនុំជម្រះក្តី។

ផ្នែកខាងក្រោមផ្តល់នូវព័ត៌មានអំពីដំណើរការដោះដូរព័ត៌មានគ្នា – ដោយរួមបញ្ចូលទាំងជំហាននិងពេលវេលាកំណត់ទាំងឡាយសម្រាប់ការដោះដូរព័ត៌មាន ការពិពណ៌នា និងឧទាហរណ៍នានានៃប្រភេទផ្សេងៗគ្នានៃសំណើដោះដូរព័ត៌មានគ្នា និងការបដិសេធនានាដែលអាចត្រូវធ្វើឡើងចំពោះសំណើដោះដូរព័ត៌មាន។

ប្រយ័ត្ន - ការឆ្លើយតបទៅនឹងសំណើដោះដូរព័ត៌មានទាំងឡាយត្រូវតែផ្ទៀងផ្ទាត់។ នេះមានន័យថា អ្នកជួលនឹងត្រូវចុះហត្ថលេខា ស្ថិតក្រោមទោសទណ្ឌនៃការនិយាយកុហកតុលាការ ដែលព័ត៌មានទាំងអស់បានផ្តល់នៅក្នុងឯកសារ គឺត្រឹមត្រូវ ហើយដែលចម្លើយរបស់ពួកគេគឺពិតនិងត្រឹមត្រូវ។

<u>ពេលវេលាកំណត់ពីការដោះដូរព័ត៌មានក្រោមបទបណ្តេញចេញ</u>

ការដោះដូរព័ត៌មានចាប់ផ្តើម៖

- 5 ថ្ងៃ *បន្ទាប់*ពីម្ចាស់ផ្ទះបញ្ជូនទៅឲ្យអ្នកជួលនូវការកោះហៅនិងពាក្យបណ្តឹង ឬ
- 5 ថ្ងៃ *ក្រោយ*ពីអ្នកជួលបានដាក់បណ្តឹងឆ្លើយតបទៅនឹងបណ្តឹងតុលាការពីការបណ្តេញចេញ ពោលគឺមួយណាក៏ដោយដែលកើត<u>មុន</u>។

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្តល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្តល់យោបល់ផ្នែកច្បាប់ដែរ។

ការដោះដូរព័ត៌មានត្រូវបញ្ចប់៖

- ប្រាំថ្ងៃលើប្រតិទិន*មុន*ពេលការជំនុំជម្រះធ្វើឡើង។

**ប្រយ័ត្ន** – គូភាគីទាំងពីរតម្រូវឲ្យឆ្លើយតបទៅនឹងការដោះដូរព័ត៌មាន ដែលត្រូវបានបញ្ជូនទៅដល់ពួកគេយ៉ាងត្រឹមត្រូវ។ ដើម្បីបញ្ចៀសផលលំបាកធ្ងន់ធ្ងរនោះ អ្នកជួលនៅក្នុងដំណើរការដោះដូរព័ត៌មាន គប្បីត្រៀមនិងផ្តល់ចម្លើយទៅដល់សំណើទាំងនេះឲ្យបានមុនការលបរិច្ឆេទផុតកំណត់ដោយច្បាប់។

អ្នកជួលនិងម្ចាស់ផ្ទះរបស់គេ ក៏អាចឯកភាពគ្នាទៅនឹងកាលបរិច្ឆេទផុតកំណត់ផ្សេងបានផងដែរ។ ទោះជាយ៉ាងណា ប្រសិនបើពួកគេពិតជាព្រមព្រៀងគ្នាទៅនឹងកាលបរិច្ឆេទផុតកំណត់ក្នុងការដោះដូរព័ត៌មានផ្សេងពីនេះនោះ វាជាការប្រសើរប្រសិនបើការព្រមព្រៀងនោះត្រូវបានកត់ត្រាទុកជាលាយលក្ខណ៍អក្សរតាមអ៊ីម៉ែល សារ ឬលិខិត។

<u>តើអ្នកជួលបញ្ជូនចម្លើយរបស់គេទៅកាន់សំណើរដោះដូរព័ត៌មានបានតាមរបៀបណា?</u>

អ្នកជួលត្រូវតែឲ្យនរណាម្នាក់ផ្សេងធ្វើការឆ្លើយតប ("បញ្ជូន") និងចុះហត្ថលេខាជាភ័ស្តុតាងបញ្ជាក់ពីសេវាកម្ម។ ភ័ស្តុតាងបញ្ជាក់ពីសេវាកម្មជាការប្រកាសជាលាយលក្ខណ៍អក្សរ ដែលបុគ្គលបានបញ្ជូន ឬប្រគល់ជូននូវលិខិតស្នាមទៅដល់នរណាម្នាក់។ បុគ្គលដែលបញ្ជូន និងដែលចុះហត្ថលេខាលើភ័ស្តុតាងបញ្ជាក់ពីសេវាកម្មសម្រាប់អ្នកជួល ត្រូវតែជាពលរដ្ឋរស់នៅ ឬនិយោជិតនៅក្នុងខោនធីដែលការផ្ញើលិខិតកើតឡើង ហើយត្រូវតែមានអាយុ 18ឆ្នាំឡើងទៅ (យោងទៅលើ "ភ័ស្តុតាងបញ្ជាក់ពីសេវាកម្ម" នៅទំព័រទី 7)។

តើមានអ្វីកើតឡើងក្នុងករណីដែលភាគីម្ខាងមិនឆ្លើយតបទៅនឹងសំណើរដោះដូរព័ត៌មាន ឬធ្វើការឆ្លើយតបមិនត្រឹមត្រូវនោះ?

ចៅក្រមអាចចេញដីការពិន័យទៅដល់ភាគី ក្នុងករណីដែលរកឃើញថាភាគីនោះប្រមាថតុលាការ បង្គាប់ឲ្យបង់ថ្លៃមេធាវីឲ្យភាគីម្ខាងទៀត ឬ សម្រេចរឿងក្តីមុនការជំនុំជម្រះកើតឡើង។

តើអ្នកជួលមានពេលច្រើនប៉ុណ្ណាដើម្បីឆ្លើយតបទៅនឹងសំណើសុំដោះដូរព័ត៌មាន?

មានពេលវេលាកំណត់ផ្សេងៗគ្នា អាស្រ័យទៅលើរបៀបដែលអ្នកជួលទទួលបានសំណើ៖

- ប្រសិនបើនរណាម្នាក់បញ្ជូនសំណើរសុំដោះដូរព័ត៌មានទៅដល់អ្នកជួលដោយផ្ទាល់ អ្នកជួលមានពេល 5ថ្ងៃតាមប្រតិទិនរាប់ចាប់ពីថ្ងៃដែលគេត្រូវបានបញ្ជូនមកឲ្យឆ្លើយតប។
- ប្រសិនបើនរណាម្នាក់ផ្ញើមកអ្នកជួលនូវសំណើសុំដោះដូរព័ត៌មានដោយបញ្ជូនមកទាំងយប់ អ្នកជួលមានពេល 7ថ្ងៃរាប់ចាប់ពីថ្ងៃដែលសំណើនោះត្រូវបានផ្ញើមកឲ្យឆ្លើយតប។
- ប្រសិនបើនរណាម្នាក់បញ្ជូនមកអ្នកជួលនូវសំណើសុំដោះដូរព័ត៌មានតាមរយៈបញ្ញើធម្មតា អ្នកជួលមានពេល 10ថ្ងៃរាប់ចាប់ពីថ្ងៃសំណើត្រូវបានផ្ញើមកឲ្យឆ្លើយតប។

**សម្គាល់** – ម្ចាស់ផ្ទះក៏មានពេល 5, 7, ឬ 10 ថ្ងៃរាប់ចាប់ពីកាលបរិច្ឆេទដែលអ្នកជួលត្រូវបានបញ្ជូនការដោះដូរព័ត៌មានត្រូវឆ្លើយតបទៅនឹងសំណើរសុំដោះដូរព័ត៌មានរបស់អ្នកជួល អាស្រ័យទៅលើវិធីសាស្ត្រនៃសេវាកម្មរបស់អ្នកជួល (ដោយផ្ទាល់ មកទាំងយប់ ឬតាមបញ្ញើធម្មតា) ដូចត្រូវបានកំណត់ខាងលើ។

តើចំណុចនៃការឆ្លើយតបក្នុងការដោះដូរព័ត៌មានជាអ្វី?

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្តល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្តល់យោបល់ផ្នែកច្បាប់ដែរ។

ការឆ្លើយតបអាចត្រូវបានប្រើដើម្បីលើកជាសំណួរនានាអំពីភាពពិតប្រាកដ ឬភាពដែលអាចជឿជាក់បានរបស់ភាគីឆ្លើយតប ឬ ដើម្បីចាប់ផ្តើម ឬ ដាក់ការកំណត់ទៅលើ អ្វីដែលជាបញ្ហាអាចត្រូវបានលើកឡើងចំពោះមុខតុលាការក្នុងអំឡុងពេលជំនុំជម្រះក្តី។ នេះជាមូលហេតុដែលវាមានសារសំខាន់ត្រូវឆ្លើយតបទៅនឹងការដោះដូរព័ត៌មាន ការទទួលបាននូវការប្រឹក្សាផ្នែកច្បាប់ប្រសិនបើអាច និងត្រូវតែប្រាកដថាភាគីម្ខាងទៀតកំពុងអនុវត្តទៅតាមវិធានច្បាប់នៅក្នុងសំណើសុំដោះដូរព័ត៌មានរបស់ខ្លួន។

<u>តើប្រភេទខុសៗគ្នានៃការដោះដូរព័ត៌មានមានអ្វីខ្លះ?</u>

មានប្រភេទនៃការដោះដូរព័ត៌មានចំនួនប្រាំ៖

1. សំណួរ – សំណួរជាលាយលក្ខណ៍អក្សរដែលត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរ។
2. សំណើសុំឯកសារ – សំណើរសុំពិនិត្យមើលឯកសារ ឬភ័ស្តុតាងជារូបវ័ន្ត។
3. សំណើរសុំបញ្ជាក់ពីភាពត្រឹមត្រូវ – សំណើសុំឲ្យបញ្ជាក់លើហេតុការណ៍ថាពិតប្រាកដមែន។
4. វិធីយកសក្ខីកម្ម – ការសម្ភាសន៍ដោយផ្ទាល់អំពីហេតុការណ៍នៃករណីបណ្តឹង។
5. ដីកាកោះសាក្សី – របៀបស្នើសុំឯកសារ ព័ត៌មាន ឬការសម្ភាសន៍នៃនរណាម្នាក់ ឬពីនរណាម្នាក់ដែលមិនមែនជាភាគីនៅក្នុងរឿងក្តី។

ប្រភេទនីមួយៗនៃប្រភេទទាំង 5 នៃការដោះដូរព័ត៌មាន ត្រូវបានពន្យល់លម្អិតថែមទៀតនៅខាងក្រោមដោយមានឧទាហរណ៍ភ្ជាប់មកជាមួយផង។

1. **សំណួរ** – សំណួរជាលាយលក្ខណ៍អក្សរដែលត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរ។ ជាទូទៅ ភាគីខាងណាមួយក៏បានអាចគ្រាន់តែបញ្ជូន 35សំណួរទៅភាគីម្ខាងទៀត។ ក្រមច្បាប់នីតិវិធីរដ្ឋប្បវេណី 2030.30. ទោះជា

យ៉ាងណា នៅក្នុងករណីបណ្តេញចេញ មាន "ទម្រង់" សំណួរទាំងឡាយដែលអ្នកជួលនឹងចាំបាច់ត្រូវឆ្លើយតបទៅនឹងសំណើទាំងអស់ បើទោះបីជាមានលើសពី 35សំណួរក៏ដោយ។

សម្គាល់ – នៅក្នុងរឿងក្តីបណ្តេញចេញ ម្ចាស់ផ្ទះគឺជា "ដើមចោទ" ឬ ជាភាគីជាអ្នកដាក់បណ្តឹង ហើយអ្នកជួលគឺជា "ចុងចោទ" ជាភាគីដែលករណីបណ្តឹងត្រូវបានចោទ។

ទាំងនេះជាឧទាហរណ៍នៃសំណួរដែលគេនិយមសួរ៖

a. "តើចុងចោទបានចូលកាន់កាប់ផ្ទះជួលពីពេលណាមក?"
b. "តើចុងចោទបានបរាជ័យបង់ប្រាក់ឈ្នួលឲ្យបានទាន់ពេលមែនទេ?"
c. "សូមរាយនូវលក្ខខណ្ឌទាំងឡាយនៃផ្ទះជួលដែលបំពានទៅលើច្បាប់ក្នុងមូលដ្ឋាន ច្បាប់រដ្ឋ និងច្បាប់សហព័ន្ធ។"

អ្នកជួលគួរយកចិត្តទុកដាក់បំផុតទៅលើអ្វី ដែលកំពុងសួរនៅក្នុងសំណួរ។ ពួកគេមិនចាំបាច់ត្រូវផ្តល់ព័ត៌មានដែលមិនត្រូវបានសួរនោះទេ។ បន្ថែមលើនេះ អ្នកជួលអាចពិចារណាជំទាស់ទៅនឹងសំណួរ (សូមមើលផ្នែកអំពីការជំទាស់ទៅនឹងសំណើសុំដោះដូរព័ត៌មានខាងក្រោម)។ ប្រសិនបើ  អ្នកជួលមិនដឹងពីចម្លើយទៅនឹងសំណួរទេ ពួកគេអាចបញ្ជាក់ *"ចុងចោទពុំមានព័ត៌មានគ្រប់គ្រាន់ឆ្លើយទៅនឹងសំណើលេខ [លេខ]បានទេ។"*

2. **សំណើសុំឯកសារ** – ជាបំណងមើលឲ្យដឹងថាមានឯកសារ ឬភ័ស្តុតាងជារូបវ័ន្តអ្វីខ្លះដែលភាគីម្ខាងទៀតត្រូវបញ្ជាក់ជាភ័ស្តុតាងរឿងក្តីរបស់ខ្លួន។ ក្រមច្បាប់នីតិវិធីរដ្ឋប្បវេណី 2031.010 ទៅ 2031.510។ <u>កាលបរិច្ឆេទផុតកំណត់នៅក្នុង</u> CCP 2031.260.

នេះជាឧទាហរណ៍ទាំងឡាយនៃសំណើសុំឯកសារ៖

a. "សូមផ្តល់រូបថតទាំងអស់ដែលអ្នកមានពីការខូចខាតដោយទឹកនៅក្នុងផ្ទះ។"
b. "សូមផ្តល់នូវការជូនដំណឹងទាំងឡាយដែលអ្នកមាន ដែលត្រូវបានផ្ញើវាទៅឱ្យម្ចាស់ផ្ទះរបស់អ្នក។"

3. **សំណើសុំបញ្ជាក់ពីការពិត** – ក្នុងបំណងដើម្បីឱ្យបញ្ជាក់ពីហេតុការណ៍មួយថាពិតប្រាកដមែន ដូច្នេះវាមិនត្រូវបញ្ជាក់ភ័ស្តុតាងនៅអង្គជំនុំជម្រះឡើយ។ ជាទូទៅ គូភាគីម្ខាងៗអាចបញ្ជូនទៅតែ 35សំណើទៅកាន់ភាគីម្ខាងទៀត ដោយមិនរាប់បញ្ចូលនូវសំណើឲ្យបញ្ជាក់ទៅលើឯកសារទាំងឡាយថាជាឯកសារពិតឥតក្លែងបន្លំទេ។ ក្រមច្បាប់នីតិវិធីរដ្ឋប្បវេណី 2033.030(b)។

នេះជាឧទាហរណ៍៖

a. "សូមបញ្ជាក់មកថា ភាគីដើមចោទស្នាក់នៅផ្ទះ 123 Main Street, Salinas, California 93905។"
    i. ប្រសិនបើអ្នកជួល "បញ្ជាក់" ថានេះជាការពិតឆ្លើយតបទៅនឹងសំណើសុំឲ្យបញ្ជាក់ហើយនោះ អ្នកជួលមិនអាចជំទាស់បានឡើយ ឬប្រកែកថាវាមិនពិតបានឡើយនៅពេលស្ថិតនៅក្នុងអង្គជំនុំជម្រះនោះ។
        1. ឧបមាថា អ្នកជួលតាមពិតរស់នៅក្នុងផ្ទះ 123 ½ Main Street (ផ្ទះតូចមួយខាងក្រោយផ្ទះធំ) ហើយវាជាផ្ទះខុសច្បាប់។ នៅឯអង្គជំនុំជម្រះ អ្នកជួលនឹងមិនអាចស្នើសុំឲ្យចៅក្រមពិចារណាថាតើផ្ទះ 123 ½ Main

Street ជាផ្ទះខុសច្បាប់ឬអត់បានទេ ពីព្រោះយោងទៅតាមចម្លើយសារភាពដែលបានដាក់កន្លងមកនោះ គឺអ្នកជួលស្នាក់នៅផ្ទះ 123 Main Street ពោលគឺមិនមែននៅក្នុងផ្ទះ 123 ½ Main Street ទេ។

នៅក្នុងចម្លើយរបស់អ្នកជួលទៅកាន់សំណើសុំឲ្យបញ្ជាក់ពីព្រឹត្តិការណ៍ពិតនោះ ពួកគេគ្រាន់តែត្រូវការឲ្យ "សារភាព" ទៅលើការលើកឡើងថាពិត 100% និង "បដិសេធ" ការលើកឡើងនោះថាមិនពិតតែប៉ុណ្ណោះ។ សំណើសុំសារភាពការពិតអាចមានលក្ខណៈគ្រោះថ្នាក់ ពីព្រោះប្រសិនបើអ្នកជួលមិនឆ្លើយវាឲ្យបានទាន់ពេលទេ ម្ចាស់ផ្ទះអាចស្នើសុំឲ្យតុលាការសម្រេចថាអ្នកជួលសារភាពគ្រប់យ៉ាង (ស្នើសុំឲ្យចៅក្រម "ចាត់ទុកថាសំណើទាំងឡាយត្រូវបានសារភាពទាំងអស់") ហើយបន្ទាប់មក ប្រើប្រាស់ចម្លើយសារភាពទាំងនោះនៅឯអង្គជំនុំជម្រះប្រឆាំងនឹងអ្នកជួល។

4. **វិធីផ្តល់សក្ខីកម្ម** – ការសម្ភាសន៍ដោយផ្ទាល់អំពីហេតុការនៃករណីបណ្តឹង។ គូភាគីមួយណាក៏បាន អាចស្នើសុំឲ្យមានសក្ខីកម្មពីភាគីម្ខាងទៀត។ បុគ្គលណាម្នាក់ដែលត្រូវបានឲ្យផ្តល់សក្ខីកម្ម (អ្នកផ្តល់សក្ខីកម្ម) នឹងតម្រូវឲ្យស្បថនិយាយការពិតក្នុងអំឡុងការផ្តល់សក្ខីកម្ម។ អ្នកផ្តល់សក្ខីកម្មអាចចាំបាច់ត្រូវមើលការតាំងបង្ហាញដើម្បីឆ្លើយសំណួរ។

អ្នកជួលត្រូវផ្តល់សក្ខីកម្មដោយត្រូវឆ្លើយតែសំណួរដែលពួកគេត្រូវបានសួរតែប៉ុណ្ណោះ ហើយពុំមានអ្វីលើសពីនេះទេ។ បន្ថែមលើនេះ ប្រសិនបើអ្នកជួលមិនយល់សំណួរ អ្នកជួលអាចសុំឲ្យគេសួរសំណួរឡើងវិញ ឬបញ្ជាក់សំណួរឡើងវិញ ជាជាងសន្មតថាពួកគេដឹងពីអ្វីដែលម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះកំពុងសួរ។ អ្នកជួលក៏អាចបដិសេធទៅនឹងសំណួរ ហើយស្នើសុំទៅបន្ទប់ទឹក ឬការសម្រាកញុំាទឹក/អាហារ។

មេធាវីជាធម្មតាធ្វើការផ្តល់សក្ខីកម្មនៅក្នុងការិយាល័យរបស់គេ។ ភាគីដែលស្នើសុំឲ្យមានការផ្តល់សក្ខីកម្ម ត្រូវបង់ថ្លៃចំណាយលើអ្នកបកប្រែភាសា ប្រសិនបើអ្នកផ្តល់សក្ខីកម្មស្នើសុំឲ្យមាននោះ។ ជាធម្មតាអ្នកកត់ត្រាតុលាការមានវត្តមាន ដែលជាអ្នកនឹងថតការសម្ភាសន៍ និងវាយចេញជាអត្ថបទពីបទសម្ភាសន៍មានផ្តល់ជូនសម្រាប់លក់។ អ្នករាយការណ៍តុលាការនឹងសួរឲ្យភាគីត្រូវធ្វើសក្ខីកម្ម ថាតើពួកគេចង់ឲ្យលើកលែងការចុះហត្ថលេខារបស់គេនៅលើអត្ថបទសម្ភាសន៍នោះដែរឬទេ។ ការចុះហត្ថលេខាលើអត្ថបទផ្តល់សក្ខីកម្មបង្ហាញថា ពាក្យពេចន៍ទាំងឡាយដែលត្រូវបានសរសេរឡើងនោះ ជាពាក្យដែលពួកគេបានថ្លែងឡើងក្នុងអំឡុងផ្តល់សក្ខីកម្ម។ ជាទូទៅអ្នកជួលមិនគួរសុំមិនចុះហត្ថលេខារបស់គេទេ។ អ្នកជួលអាចទទួលបានមួយច្បាប់នៃសក្ខីកម្មដើម្បីអាន ពិនិត្យមើល និងកែតម្រូវបើចាំបាច់ មុននឹងពួកគេផ្តល់ហត្ថលេខា ដោយការបញ្ជាក់ថា ទាំងនោះគឺជាពាក្យពេចន៍ដែលពួកគេបានថ្លែងឡើងនៅក្នុងការផ្តល់សក្ខីកម្ម។

ការផ្តល់សក្ខីកម្មអាចត្រូវបានកំណត់កាលវិភាគយ៉ាងហោចណាស់ប្រាំថ្ងៃក្រោយសេវាកម្មនៃការជូនដំណឹងពីការផ្តល់សក្ខីកម្ម ប៉ុន្តែការផ្តល់សក្ខីកម្មត្រូវកើតឡើងប្រាំថ្ងៃមុនការជំនុំជម្រះក្តី។ ក្រមច្បាប់នីតិវិធីរដ្ឋប្បវេណី 2025.270.

5. **ដីការកោះសាក្សី** – ដីការកោះសាក្សី គឺជារបៀបស្នើសុំឯកសារ ព័ត៌មានរបស់ភាគី ឬជាការសម្ភាសន៍នរណាម្នាក់ដែលមិនមែនជាភាគីចំពោះរឿងក្តី។

<u>ការទទួលសមស្រប៖</u>

ប្រសិនបើអ្នកជួលតម្រូវឲ្យមានការទទួលសម្រាប់ការផ្តល់សក្ខីកម្មរបស់គេនោះ ពួកគេអាចដាក់សំណើទៅកាន់ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះជាលាយលក្ខណ៍អក្សរ ហើយ/ឬ ទូរសព្ទទៅកាន់ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះ ដើម្បីពិភាក្សាពីការទទួលសមស្រប។ សូមចាំថា បុគ្គលដែលមានពិការភាពមិនចាំបាច់បង្ហាញពីរោគវិនិច្ឆ័យ(ទាំងឡាយ) របស់ខ្លួនចំពោះសំណើសុំការទទួលសមស្របនោះទេ។

<u>ការបដិសេធទៅនឹងសំណើសុំដោះដូរព័ត៌មាន</u>

អ្នកជួលអាចបដិសេធចំពោះសំណើសុំដោះដូរព័ត៌មានបាន ប្រសិនសិនបើពួកគេមានមូលដ្ឋានច្បាប់នោះ។ ខាងក្រោមជាឧទាហរណ៍ទាំងឡាយនៃប្រភេទខុសៗគ្នានៃការបដិសេធដែលធ្វើឡើងភាគច្រើន។ ទោះជាយ៉ាងណា វាគួរតែកត់សម្គាល់ថា ក្រោយការបដិសេធ អ្នកជួលអាចនៅតែត្រូវឆ្លើយទៅនឹងសំណើដោយផ្អែកលើចំណេះដឹងរបស់គេ ឬ ប្រសិនបើមានមែននោះ ពួកគេអាចបញ្ជាក់ថាពួកគេមិនមានព័ត៌មានគ្រប់គ្រាន់ដើម្បីឆ្លើយទៅនឹងសំណើនោះទេ។

ការបដិសេធទៅនឹងសំណើសុំដោះដូរព័ត៌មានដែលធ្វើឡើងច្រើនបំផុតទាំងប្រាំមួយ៖

- <u>ភាពពាក់ព័ន្ធ៖</u> ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះសុំព័ត៌មានដែលមិនពាក់ព័ន្ធទៅនឹងរឿងក្តី។
- <u>ភាពពាក់ព័ន្ធ/ឯកជនភាព</u>៖ ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះកំពុងសួរសំណួរដែលពាក់ព័ន្ធដល់ព័ត៌មានបង្ហាញពីអត្តសញ្ញាណបុគ្គល ឬព័ត៌មានឯកជន។
- <u>ទូលំទូលាយពេកនិងការរំខានហួសហេតុ</u>៖ ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះសុំព័ត៌មានច្រើនពេកដែលពិបាកនឹងផ្តល់ជូន។
- <u>ការស្មាន៖</u> ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះកំពុងព្យាមឲ្យអ្នកជួលនិយាយអ្វីក្រៅពីការយល់ដឹងរបស់គាត់ ឬក្រៅពីអ្វីដែលពួកគេជួបប្រទះ។

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្តល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្តល់យោបល់ផ្នែកច្បាប់ដែរ។

- <u>សមាសសំណួរ៖</u> ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះកំពុងតែសួរអ្នកជួលនូវសំណួរដែលមានច្រើនផ្នែកដែលតម្រូវឲ្យឆ្លើយដាច់ដោយឡែកៗពីគ្នា។
- <u>សំណួរនិងចម្លើយដដែលៗ៖</u> ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះកំពុងសួរអ្នកជួលនូវសំណួរដដែលៗដែលពួកគេបានឆ្លើយរួចហើយ។

នីមួយៗនៃការជំទាស់ទៅនឹងសំណើសុំដោះដូរព័ត៌មានច្រើនកើតមានទាំងប្រាំមួយនេះ ដូចមានខាងលើ ត្រូវបានពន្យល់កាន់តែលម្អិតបន្ថែមព្រមជាមួយនឹងឧទាហរណ៍។

- <u>ភាពពាក់ព័ន្ធ៖</u> ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះកំពុងសុំព័ត៌មានដែលមិនពាក់ព័ន្ធទៅនឹងរឿងក្តី។ ឧទាហរណ៍ នៅក្នុងសំណួរមួយ ម្ចាស់ផ្ទះបានសួរទៅដល់អ្នកជួលនូវឈ្មោះរបស់ចៅហ្វាយរបស់គាត់ ហើយចៅហ្វាយរបស់គាត់គ្មានអ្វីពាក់ព័ន្ធទៅនឹងការស្នាក់នៅរបស់គេទេ។ ការឆ្លើយតបជាឧទាហរណ៍របស់អ្នកជួលអាចជា៖ "ចុងចោទសូមជំទាស់ទៅនឹងសំណួរលេខ 9 ដោយសារតែសំណួរនេះស្នើសុំព័ត៌មានដែលមិនពាក់ព័ន្ធទៅនឹងនីតិវិធីរឿងក្តីទាំងនេះទេ។ កម្មវត្ថុចំពោះការជំទាស់ដែលបានលើកឡើងនោះ ចៅហ្វាយរបស់ខ្ញុំគឺ Crystal Garcia។"

- <u>ភាពពាក់ព័ន្ធ / ឯកជនភាព៖</u> ម្ចាស់ផ្ទះកំពុងសួរសំណួរដែលពាក់ព័ន្ធទៅនឹងព័ត៌មានបង្ហាញពីអត្តសញ្ញាណបុគ្គល ដូចជាលេខសន្តិសុខសង្គមរបស់អ្នកជួល ថ្ងៃខែឆ្នាំកំណើត លេខប័ណ្ណបើកបរ ឬ ព័ត៌មានផ្ទាល់ខ្លួនដូចជាស្ថានភាពអន្តោប្រវេសន៍របស់ពួកគេ ឬ ពិការភាពជាក់លាក់ណាមួយ ឬ ព័ត៌មានផ្នែកវេជ្ជសាស្ត្រ។ អ្នកជួលអាចជំទាស់ដោយផ្អែកទៅលើ៖ (1) ភាពពាក់ព័ន្ធ ពីព្រោះតែព័ត៌មានមិនពាក់ព័ន្ធទៅនឹងការបណ្តេញចេញ

និង (2) ឯកជនភាព ពីព្រោះតែវាជាព័ត៌មានផ្ទាល់ខ្លួនដែលត្រូវបានការពាររបស់អ្នកជួល។ ឧទាហរណ៍ នៅក្នុងការផ្តល់សក្ខីកម្ម មេធាវីម្ចាស់ផ្ទះសួរអ្នកជួលពីលេខសន្តិសុខសង្គមរបស់ពួកគេ។ ចម្លើយគំរូរបស់ពួកគេអាចជា៖ "ខ្ញុំសូមជំទាស់ទៅនឹងសំណួរនោះដោយផ្អែកលើភាពមិនពាក់ព័ន្ធនិងឯកជនភាព។" អ្នកជួលមិនចាំបាច់ឆ្លើយទៅនឹងសំណួរដោយពាក់ព័ន្ធដល់ព័ត៌មានឯកជនផ្ទាល់ខ្លួនរបស់គេទេ។

- ទូលំទូលាយពេកនិងការរំខានហួសហេតុ៖ ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះសុំព័ត៌មានច្រើនពេកដែលពិបាកនឹងផ្តល់ជូន។ ឧទាហរណ៍ នៅក្នុងសំណើសុំឯកសារ ម្ចាស់ផ្ទះកំពុងស្នើសុំនូវគ្រប់កំណត់ហេតុរបស់គ្រូពេទ្យ ដែលអ្នកជួលធ្លាប់ទទួលបានទាក់ទងទៅនឹងពិការភាពរបស់ពួកគេ ដែលគេមានក្នុងរយៈពេល 30ឆ្នាំមកនេះ។ ការឆ្លើយតបគំរូរបស់អ្នកជួលអាចជា៖ "ចុងចោទសូមជំទាស់ទៅនឹងសំណើរផ្តល់ឯកសារលេខ 9 ដោយសារតែទូលំទូលាយពេកនិងជាការរំខានហួសហេតុពេក ហើយមិនពាក់ព័ន្ធទាល់តែសោះ ដោយសារតែវាស្នើសុំព័ត៌មានចាប់ពីសាមសិបឆ្នាំកន្លងមក ហើយកិច្ចសន្យាជួលរបស់ខ្ញុំចាប់ផ្តើមត្រឹម 8ខែកន្លងមកនេះទេ។ កម្មវត្ថុចំពោះការជំទាស់បែបនេះ ភាគីចុងចោទផ្តល់នូវកំណត់ហេតុចុងក្រោយពីររបស់គ្រូពេទ្យ ដែលគាត់ទទួលបានថ្មីៗបំផុត ហើយរក្សាទុកនូវឯកសារទាំងឡាយដែលនៅសល់។

- ការស្មាន៖ ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះកំពុងព្យាមឲ្យអ្នកជួលនិយាយអ្វីក្រៅពីការយល់ដឹងរបស់គាត់ ឬក្រៅពីអ្វីដែលពួកគេជួបប្រទះ។ ឧទាហរណ៍ នៅក្នុងការផ្តល់សក្ខីកម្ម មេធាវីម្ចាស់សួរអ្នកជួលពីអ្វីដែលពួកគេនឹងធ្វើ ប្រសិនបើម្ចាស់ផ្ទះរបស់គេបានឆ្លើយទូរសព្ទរបស់គេ បើទោះជាម្ចាស់ផ្ទះរបស់ពួកគេមិនបានឆ្លើយទូរសព្ទក៏ដោយ។ ការឆ្លើយតបគំរូរបស់អ្នកជួល

អាចជា៖ "ជំទាស់ ទាញទៅរកការស្មាន។ កម្មវត្ថុការជំទាស់បែបនេះ ខ្ញុំនឹងបានប្រាប់ម្ចាស់ខ្ញុំអំពីរ៉ូប៊ី ណេធ្លាយ ហើយសុំឲ្យគាត់ជួសជុលវា។ សម្គាល់៖ នៅក្នុងតុលាការ អ្នកជួលមិនគួរត្រូវឆ្លើយទៅសំណួរដែលនាំឲ្យធ្វើការសន្និដ្ឋានទាល់តែសោះ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការផ្តល់សក្ខីកម្មពុំមានវត្តមានចៅក្រមទេ ដូច្នេះអ្នកជួលអាចជំទាស់បានហើយនិយាយថាជាការសន្និដ្ឋាន ហើយមិនឆ្លើយសំណួរឡើយ។ ឬ អ្នកជួលអាចជំទាស់ហើយនិយាយអ្វីមួយដែលមិនប៉ះពាល់ដល់រឿងក្តីរបស់គេ។

- សមាសសំណួរ៖ ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះកំពុងតែសួរអ្នកជួលនូវសំណួរដែលមានច្រើនផ្នែកដែលតម្រូវឲ្យឆ្លើយដាច់ដោយឡែកៗពីគ្នា។ ឧទាហរណ៍ នៅក្នុងការស្នើសុំឲ្យបញ្ជាក់ពីហេតុការណ៍ពិត មេធាវីម្ចាស់ផ្ទះនិយាយថា៖ "ភាគីចុងចោទសារភាពថា គាត់បានបើកតន្ត្រីខ្លាំងៗនៅពាក់កណ្តាលយប់នៅថ្ងៃទី09 ខែឧសភា ឆ្នាំ2020 ពីព្រោះគាត់មានពិធីជប់លៀងនៅគេហដ្ឋាន។" ការឆ្លើយតបគំរូរបស់អ្នកជួលអាចជា៖ "ជំទាស់សំណើលេខ 9 ជាសមាសសំណួរ។ កម្មវត្ថុចំពោះការបេដិសេធបែបនេះត្រូវបានបដិសេធ។"

- សំណួរនិងចម្លើយដដែលៗ៖ ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះកំពុងសួរអ្នកជួលនូវសំណួរដដែលៗដែលពួកគេបានឆ្លើយរួចហើយ។ ឧទាហរណ៍ នៅឯការផ្តល់សក្ខីកម្ម មេធាវីម្ចាស់ផ្ទះសួរថា "ដូច្នេះអ្នកមិនបានបង់ថ្លៃឈ្នួលខែវិច្ឆិកាមែនទេ?" ហើយអ្នកជួលឆ្លើយ ហើយក្រោយមកបន្តិច មេធាវីសួរថា "តើអ្នកមិនបានបង់ថ្លៃឈ្នួលខែវិច្ឆិកាមែនទេ?" អ្នកជួលអាចជំទាស់ទៅនឹងសំណួរទៅពីរបានដោយនិយាយថា "សូមជំទាស់ ជាការសួរដដែលៗ" ហើយមិនត្រូវឆ្លើយទៅនឹងសំណួរទីពីរនោះម្តងទៀតឡើយ។

សម្គាល់៖ ប្រសិនបើអ្នកជួលមានការពិបាកចងចាំឈ្មោះនៃការជំទាស់ក្នុងអំឡុងការផ្តល់សក្ខីកម្ម ពួកគេនៅតែអាចបញ្ជាក់ "ការជំទាស់" និងហេតុផលសម្រាប់ការជំទាស់តាមពាក្យរបស់គេផ្ទាល់បាន។ ចៅក្រមអាចពិចារណាលើករណីនេះ។

## 6. A. ការជំនុំជម្រះក្តី - សេចក្តីផ្តើម

នៅក្នុងផ្នែកនេះ ពន្យល់ពីអ្វីដែលកើតមានឡើងក្រោយពីដំណើរការដោះដូរព័ត៌មានបានបញ្ចប់ ពោលវាជាការចាប់ផ្តើមនៃការជំនុំជម្រះក្តី។ វាពន្យល់ពីមូលដ្ឋានទាំងឡាយនៃអ្វីដែលរំពឹងទុក របៀបដែលអ្នកជួលត្រូវត្រៀមនៅមុនការជំនុំជម្រះក្តី ដោយរាប់បញ្ចូលទាំងអ្វីដែលត្រូវយកមកជាមួយមកកាន់អង្គជំនុំជម្រះ និងពីរបៀបចូលមកតុលាការ។

<u>ការជំនុំជម្រះដោយចៅក្រម ឬការជំនុំជម្រះដោយគណៈវិនិច្ឆ័យ?</u>

អ្នកជួលដែលទីបំផុតទៅត្រូវឡើងទៅដល់ការជំនុំជម្រះក្តីនោះ ជាជាងការដោះស្រាយបញ្ចប់រឿងក្តីតាមរយៈការព្រមព្រៀងដោះស្រាយបញ្ចប់មួយនោះ មានជម្រើសឲ្យរឿងក្តីរបស់គេត្រូវបានសម្រេចដោយគណៈវិនិច្ឆ័យ ដែលជាក្រុមមនុស្សមួយក្រុមមកពីសាធារណៈជន សម្រេចរឿងក្តី ឬ សម្រេចដោយចៅក្រម។ ការជំនុំជម្រះដោយមានគណៈវិនិច្ឆ័យ ត្រូវបានហៅថា ការជំនុំជម្រះដោយគណៈវិនិច្ឆ័យ ហើយអ្នកជួលដែលចង់បានការជំនុំជម្រះដោយគណៈវិនិច្ឆ័យត្រូវតែស្នើសុំជាមុន (សូមមើល "ផ្នែកទី 2 ការឆ្លើយតបទៅនឹងការកោះហៅនិងពាក្យបណ្តឹង – ចម្លើយនិងទម្រង់បែបបទតុលាការផ្សេងទៀត" "ទាមទារឲ្យមានការជំនុំជម្រះដោយគណៈវិនិច្ឆ័យ")។ ការជំនុំជម្រះត្រូវបានសម្រេចឡើងដោយចៅក្រម ហើយគ្មានគណៈវិនិច្ឆ័យនោះ ត្រូវបានហៅថាការជំនុំជម្រះដោយចៅក្រម។ មានទាំងគុណសម្បត្តិនិងគុណវិបត្តិចំពោះការជំនុំជម្រះគណៈវិនិច្ឆ័យ និងការជំនុំជម្រះចៅក្រម។ ប្រសិនបើអ្នកជួលមិនច្បាស់ថាត្រូវជ្រើសរើសយកមួយណានោះ ពួកគេអាចពិភាក្សាជាមួយមេធាវីការពាររឿងក្តីបណ្តេញចេញ។

**ប្រយ័ត្ន៖ ដោយសារតែជំងឺរាតត្បាត COVID-19 តុលាការមួយចំនួនបើកសវនាការពីចម្ងាយតែប៉ុណ្ណោះ។ តុលាការអាចនឹងជំនុំជម្រះក្តីតាមទូរសព្ទ តាមកម្មវិធី**

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្តល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្តល់យោបល់ផ្នែកច្បាប់ដែរ។

**កុំព្យូទ័រ ឬ តាមវេទិកា “Zoom” ដែលអាចចូលរួមបានតាមកុំព្យូទ័រ ទូរសព្ទ ឬឧបករណ៍អេឡិចត្រូនិកផ្សេងទៀតដែលមានភ្ជាប់អ៊ីនធឺណិត ឬតាមរយៈការទទួលបានសេវាកម្មតាមទូរសព្ទ។ អ្នកជួលអាចទូរសព្ទទៅកាន់ក្រឡាបញ្ជីនៃតុលាការក្នុងមូលដ្ឋានរបស់គេ ឬ សេវាជំនួយរបស់តុលាការក្នុងមូលដ្ឋាន ដើម្បីទទួលបានព័ត៌មានបន្ថែមអំពីនីតិវិធីបើកសវនាការពីចម្ងាយរបស់តុលាការរបស់គេ។**

<u>អ្វីដែលត្រូវធ្វើនៅមុនការជំនុំជម្រះក្តី</u>

នៅមុនការជំនុំជម្រះក្តី អ្នកជួលអាចនឹងចាំបាច់ត្រូវ៖

1. **បញ្ជូនបញ្ជីសាក្សីទៅកាន់ម្ចាស់ផ្ទះរបស់គេ ហើយផ្តល់បញ្ជីនេះមួយច្បាប់ជូនទៅតុលាការ។** បញ្ជីសាក្សីមានឈ្មោះនិងព័ត៌មានទំនាក់ទំនងរបស់អ្នកទាំងឡាយដែលអ្នកជួលមានបំណងចង់ឲ្យធ្វើជាសាក្សី ឬ និយាយនៅចំពោះមុខតុលាការ ក្រោមពាក្យសម្បថ និងក្នុងនាមពួកគេនៅពេលជំនុំជម្រះក្តី។ បញ្ជីនេះរួមបញ្ចូលនូវម្ចាស់ផ្ទះ ឬ សាក្សីម្ចាស់ផ្ទះ ប្រសិនបើអ្នកជួលត្រូវការឲ្យពួកគេធ្វើសក្ខីកម្មដើម្បីបញ្ជាក់ពីភ័ស្តុតាងចំណុចណាមួយ។ អ្នកជួលមិនត្រូវហៅទូរសព្ទទៅមនុស្សគ្រប់គ្នានៅលើបញ្ជីសាក្សីរបស់គេឱ្យផ្តល់កសិណធ្វើសាក្សីនោះទេ ប៉ុន្តែពួកគេមិនអាចឲ្យអ្នកណាដែលមិនមានឈ្មោះនៅលើបញ្ជីសាក្សីផ្តល់កសិណបានដែរ។

2. **បញ្ជូននូវសេចក្តីណែនាំរបស់គណៈវិនិច្ឆ័យ និងទម្រង់សាលក្រមទៅកាន់ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះរបស់គេ ហើយដាក់បញ្ជូនមួយច្បាប់ទៅតុលាការ។** អ្នកជួលគប្បីទូរសព្ទទៅកាន់មជ្ឈមណ្ឌលជួយខ្លួនឯងក្នុងមូលដ្ឋានរបស់គេ ឬ ទីភ្នាក់ងារជំនួយផ្នែកច្បាប់ និងអនុវត្តទៅតាមនីតិវិធីរបស់តុលាការក្នុងមូលដ្ឋានរបស់គេ។ អាចនឹងមាន "ជីកាស្លាពរ" ផ្តល់ជូនដោយមានការណែនាំ

ពីចៅក្រមរបស់គេ។ ឧទាហរណ៍ – ខោនធីមួយចំនួនទាក់ទងនឹងការជំនុំជម្រះក្តីពីចម្ងាយតាមអនឡាញតម្រូវឲ្យយកឯកសារភ័ស្តុតាងមកដាក់ក្នុងហិបដាក់ឯកសារ នៅសាលាក្តី ឬផ្ញើតាមអ៊ីម៉ែលមកកាន់សាលាក្តី ព្រមជាមួយនឹង ការផ្ញើតាមអ៊ីម៉ែល ឬយកទៅប្រគល់ឲ្យដល់ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះ។

នៅមុនការជំនុំជម្រះក្តី អ្នកជួលអាចចង់៖

1. **គិតឡើងវិញទៅលើទឡ្ហីករណ៍ទាំងឡាយដែលពួកគេចង់លើកឡើង និងឯកសារទាំងឡាយ ឬ សាក្សីទាំងឡាយដែលគេត្រូវការដើម្បីជួយបង្ហាញជាភ័ស្តុតាងដល់រឿងក្តីនេះ។** វាអាចនឹងមានប្រយោជន៍ដែលយើងត្រូវមើលទៅលើទម្រង់បណ្តឹងឆ្លើយតប ដើម្បីដឹងថាការការពារអ្វីខ្លះដែលគេបានលើកឡើង។ អ្នកជួលខ្លះយល់ថាវាមានប្រយោជន៍ត្រូវសរសេរចេញគ្រោងគោលៗដែលគេអាចយកទៅអង្គជំនុំជម្រះជាមួយបាន ដើម្បីកុំឲ្យពួកគេភ្លេចនូវចំណុច សំខាន់ៗដែលពួកគេចង់លើកឡើង។ គ្រោងគោលៗអាចរួមបញ្ចូលនូវទឡ្ហីករណ៍របស់គេ និង ចំណុចនីមួយៗនៃទឡ្ហីករណ៍របស់ពួកគេ - ពីភ័ស្តុតាងទាំងឡាយ ឬការលើកឡើងទាំងឡាយរបស់គេ ឬរបស់សាក្សី ដែលគេនឹងប្រើដើម្បីបង្ហាញវាជាភ័ស្តុតាង។ សូមមើល "ភ័ស្តុតាង" និង "សាក្សី" ស្ថិតនៅក្រោមផ្នែក "អ្វីត្រូវយកទៅជាមួយទៅកាន់អង្គជំនុំជម្រះ" នៅដើមទំព័រទី 23 សម្រាប់ព័ត៌មានបន្ថែម។

2. **គិតឡើងវិញឲ្យបានល្អិតល្អន់ទៅលើទឡ្ហីករណ៍ទាំងឡាយដែលពួកគេគិតថាម្ចាស់ផ្ទះអាចនឹងលើកឡើង និងឯកសារទាំងឡាយ ឬ សាក្សីទាំងឡាយដែលគេត្រូវការដើម្បីជួយបង្ហាញជាភ័ស្តុតាងដល់រឿងក្តីនេះ។** វាអាចមានប្រយោជន៍ដែលត្រូវមើលពាក្យបណ្តឹងពីម្ចាស់ផ្ទះ ដើម្បីឲ្យឃើញពីមូលហេតុដែលពួកគេសំអាងថាអ្នកជួលគួរតែត្រូវទទួលទោស។ អ្នកជួលអាចនឹងទទួលបានប្រយោជន៍ពីនេះ ពីព្រោះថាពេលនោះគេអាចមានអារម្មណ៍កាន់តែមានទំនុកចិត្តបន្តិចអំពីអ្វីដែលត្រូវរំពឹង និងអាចត្រូវត្រៀមខ្លួនដើម្បីឆ្លើយតប។ ឧទាហរណ៍ ប្រសិនបើពួកគេដឹងថាម្ចាស់ផ្ទះរបស់ពួកគេនឹងអះអាងលើអ្វីមួយដែលមិនពិត ប្រសិនបើគេធ្វើបែបនេះមែន អ្នកជួលអាចត្រៀមនូវភ័ស្តុតាងដែលបញ្ជាក់ថាវាមិនពិត។

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្តល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្តល់យោបល់ផ្នែកច្បាប់ដែរ។

3. **កំណត់ថាតើពួកគេនឹងត្រូវការអ្នកបកប្រែភាសាឬអត់ ឬត្រូវការកន្លែងសមស្របដែរឬទេ ដើម្បីចូលរួមនៅក្នុងដំណើរការនីតិវិធីតុលាការនោះ។** សូមមើលផ្នែក "ព័ត៌មានមូលដ្ឋានពីបន្ទប់សវនាការ" ខាងក្រោមមានព័ត៌មានច្រើនថែមទៀត។

4. **កំណត់ថាតើពួកគេនឹងត្រូវការសម្របសម្រួលការមើលថែទាំក្មេងនិង/ឬការធ្វើដំណើរ និង/ឬ ពេលឈប់សម្រាកពីការងារ ដើម្បីអាចមកចូលរួមសវនាការដែរឬទេ។** សូមមើលផ្នែក "ព័ត៌មានមូលដ្ឋានពីសាលាក្តី" ខាងក្រោមមានព័ត៌មានច្រើនថែមទៀត។

<u>ព័ត៌មានជាមូលដ្ឋានពីបន្ទប់សវនាការ</u>

**ម៉ោង៖** អ្នកជួលចាំបាច់ត្រូវមកដល់តុលាការឲ្យបានមុនម៉ោង។ អ្នកជួលចាំបាច់ត្រូវមានពេលគ្រប់គ្រាន់ដើម្បីមកដល់ ឆ្លងកាត់ម៉ាស៊ីនស្កេន រកមើលបន្ទប់សវនាការរបស់គេ រកមើល "កាលវិភាគ" និងចុះឈ្មោះចូលជាមួយនឹងក្រឡាបញ្ជីមុននឹងចៅក្រម ឬក្រឡាបញ្ជីចាប់ផ្តើមប្រកាសក្តីទៅតាមពេលវេលាសម្រាប់កាលបរិច្ឆេទតុលាការរបស់គេ។ បញ្ជីហៅឈ្មោះគឺជាក្រដាសមួយសន្លឹកដែលបិទជាប់ទៅនឹងទ្វារបន្ទប់សវនាការ ឬ ដោតដោយម្ជុលជាប់ទៅនឹងជញ្ជាំងក្បែរទ្វារបន្ទប់សវនាការ បង្ហាញពីឈ្មោះក្តីនិងលេខសម្គាល់ក្តី ដែលមានកាលបរិច្ឆេទកំណត់ដោយតុលាការនៅក្នុងថ្ងៃនោះ។

**ការជំនុំជម្រះក្តីពីចម្ងាយ៖** ប្រសិនបើការជំនុំជម្រះធ្វើឡើងពីចម្ងាយជំនួសឲ្យការធ្វើផ្ទាល់នោះ អ្នកជួលនៅតែចង់ឲ្យប្រាកដថា ពួកគេបានផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ខ្លួនគេ ដើម្បីឲ្យរួចរាល់នៅមុនតុលាការចាប់ផ្តើម។ ឧទាហរណ៍ អ្នកជួលអាចនឹងចាំបាច់ត្រូវរៀបចំកន្លែង ដែលពួកគេនឹងចូល

សវនាការ ថាតើវានឹងធ្វើឡើងតាមទូរសព្ទរបស់គេ ឬតាមកុំព្យូទ័រ ហើយដើម្បីធ្វើតេស្តសាកល្បងបច្ចេកវិទ្យាទាំងឡាយដែលពួកគេនឹងប្រើ រួមទាំងការភ្ជាប់ អ៊ីនធឺណិតរបស់គេផងបើចាំបាច់។ ជាការប្រឹងប្រែងឲ្យអស់ពីលទ្ធភាពនោះ អ្នកជួលគួរតែព្យាយាមធានាថាកន្លែងដែលពួកគេនឹងប្រើប្រាស់នោះមានសភាពស្ងប់ស្ងាត់និងមានឯកជនភាព។
**ការស្លៀកពាក់៖** អ្នកជួលគប្បីព្យាយាមស្លៀកពាក់ឲ្យបានសមរម្យ។

**ការថែទាំកុមារ៖** អាចនឹងពុំមានសេវាថែទាំកុមារផ្តល់ជូនឡើយនៅឯសាលាក្តី។ គ្រប់គ្នាដែលកំពុងមើលតុលាការត្រូវស្ងៀមស្ងាត់នៅពេលចៅក្រមឡើងលើសវនដ្ឋានចៅក្រម ឬ អាជ្ញាសាលា ដែលមានលក្ខណៈដូចសន្តិសុខការពារនៅក្នុងបន្ទប់សវនាការនោះ នឹងសុំឲ្យពួកគេចាកចេញពីបន្ទប់សវនាការ។ ដូចគ្នានេះដែរសម្រាប់ការបើសវនការពីចម្ងាយ – ចៅក្រមនឹងមិនចង់ឲ្យត្រូវបានរំខានដោយសម្លេងខាងក្រោយនៅលើទូរសព្ទទេ រួមទាំងក្មេងៗផងដែរ។

**អ្នកបកប្រែភាសាផ្ទាល់មាត់៖** នៅមុនកាលបរិច្ឆេទបើសវនាការ អ្នកជួលអាចទូរសព្ទមកសាលាក្តីដើម្បីស្នើសុំអ្នកបកប្រែភាសាផ្ទាល់មាត់។ នៅថ្ងៃបើកសវនាការរបស់គេ អ្នកជួលអាចអនុញ្ញាតឲ្យក្រឡាបញ្ជីដឹងថាពួកគេត្រូវការអ្នកបកប្រែភាសាផ្ទាល់មាត់ឲ្យបានឆាប់តាមតែអាចធ្វើបាន ឬ នៅពេលពួកគេចូលទៅដល់បន្ទប់សវនាការ។ ប្រសិនបើចៅក្រមប្រកាសក្តី ហើយអ្នកបកប្រែភាសាមិនស្ថិតនៅទីនោះទេ អ្នកជួលអាចសុំឲ្យចៅក្រមឱ្យរង់ចាំឲ្យអ្នកបកប្រែភាសាផ្ទាល់មាត់មកដល់សិន។

**ការទទួលសមស្របនៅក្នុងតុលាការ៖** សូមមើលផ្នែកនិយាយពី “ការទទួលសមស្របនៅក្នុងតុលាការ” ខាងក្រោម។

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្តល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្តល់យោបល់ផ្នែកច្បាប់ដែរ។

## អ្វីខ្លះដែលត្រូវយកទៅជាមួយទៅកាន់ការជំនុំជម្រះក្តី

អ្នកជួលគប្បីមានជាប់ជាមួយនូវភ័ស្តុតាងទាំងអស់របស់គេ និងដែលត្រូវបានរៀបចំត្រឹមត្រូវ និងមានវត្តមានសាក្សីរបស់គេនៅក្នុងតុលាការនៅពេលសវនាការរបស់គេចាប់ផ្តើម។

**ភ័ស្តុតាង** – សម្រាប់ភ័ស្តុតាងទាំងអស់ អ្នកជួលចាំបាច់ត្រូវយកមកជាមួយយ៉ាងហោចណាស់ច្បាប់ដើម 1ច្បាប់ និងច្បាប់ថតចម្លងចំនួន 2ច្បាប់។ នេះក៏ព្រោះតែម្ចាស់ផ្ទះមានសិទ្ធិមើលច្បាប់ដើម ហើយនឹងទទួលបានមួយច្បាប់ដែរ។ ចៅក្រមនឹងទទួលយកច្បាប់ដើម ហើយអ្នកជួលអាចប្រើច្បាប់ថតចម្លងក្នុងអំឡុងជំនុំជម្រះក្តី។ ប្រសិនបើការជំនុំជម្រះក្តីធ្វើឡើងពីចម្ងាយ អ្នកជួលអាចសាកសួរជាមួយនឹងក្រឡាបញ្ជីនៅមុនកាលបរិច្ឆេទជំនុំជម្រះក្តី ដើម្បីឲ្យដឹងពីរបៀបមើលឯកសារក្នុងអំឡុងជំនុំជម្រះក្តី។

ឧទាហរណ៍នៃភ័ស្តុតាងមួយចំនួន ដែលអ្នកជួលអាចយកមកតុលាការមាន៖

- រូបថតនៃការខូចមិនដំណើរការ ឬ លក្ខខណ្ឌមិនសមប្រកបនៅក្នុងផ្ទះរបស់គេ
- ច្បាប់ថតចម្លងដែលត្រូវបានបញ្ជាក់នៃរបាយការណ៍ពីនាយកដ្ឋានសុខភាពកំណត់ត្រារដ្ឋាភិបាល ឬ កំណត់ត្រាអាជីវកម្មទាំងឡាយ
- បង្កាន់ដៃបង់ប្រាក់ឈ្នួលផ្ទះទាំងអស់ ឬភ័ស្តុតាងនៃការទូទាត់ថ្លៃឈ្នួល ឧទាហរណ៍មាន របាយការណ៍ធនាគារបង្ហាញមូលប្បទានប័ត្រដែលត្រូវបានដកប្រាក់ បង្កាន់ដៃបង់ប្រាក់តាមការបញ្ជាបង់ប្រាក់ ឬបង្កាន់ដៃទាំងឡាយ និង

- លិខិតស្នាមនានា សេចក្តីជូនដំណឹង សារជាអក្សរ ឬការទំនាក់ទំនងតាមសារជាសម្លេង ដែលអ្នកជួលបានធ្វើឡើងជាមួយនឹងម្ចាស់ផ្ទះរបស់គេ។ ឧទាហរណ៍ អ្នកជួលអាចយកមកនូវលិខិតស្នាមទាំងឡាយណា ដែលពួកគេបានផ្តល់ជូនទៅម្ចាស់ផ្ទះរបស់គេ ស្នើសុំឲ្យធ្វើការជួសជុល ឬ ជូនដំណឹងដល់ម្ចាស់ផ្ទះរបស់គេពីបញ្ហាណាមួយពាក់ព័ន្ធនឹងម្ចាស់ផ្ទះ។ អ្នកជួលក៏អាចរួមបញ្ចូលនូវស្រោមសំបុត្រនានាផងដែរ ពីព្រោះតែមប្រៃសណីយ៍បង្ហាញកាលបរិច្ឆេទនៃការផ្ញើចេញ និងស្រោមសំបុត្រទាំងឡាយដែលបង្ហាញថាលិខិតផ្ញើបានទៅ និងមកពីនរណា។

  **ប្រយ័ត្ន៖** អ្នកជួលមិនអាចផ្អាកការជំនុំជម្រះក្តីបានដោយសារតែពួកគេមិនមានភ័ស្តុតាងទាំងអស់របស់គេមកជាមួយ (ឬបានដាក់បញ្ជូនមកយ៉ាងត្រឹមត្រូវសម្រាប់ការជម្រះក្តីតាមអ៊ីនធឺណិត) នោះទេ។ អ្នកជួលត្រូវត្រៀមខ្លួនឲ្យបានរួចរាល់នៅថ្ងៃសវនាការរបស់គេ។

**សាក្សី** – សាក្សីទាំងឡាយត្រូវតែមានវត្តមាននៅក្នុងតុលាការនៅពេលចាប់ផ្តើមការជំនុំជម្រះក្តី និងទំនេរអាចឆ្លើយសំណួរនិងផ្តល់កសិណបាន។ ឧទាហរណ៍ អ្នកជួលមិនអាចយកលិខិតពីអ្នកជិតខាងរបស់គេមកជំនួសឲ្យអ្នកជិតខាងរបស់គេមកតុលាការដោយផ្ទាល់ដើម្បីផ្តល់កសិណបាននោះទេ។ នេះគឺដោយសារតែលិខិតមួយមិនអាចបញ្ជាក់ឲ្យបានសព្វជ្រុងជ្រោយដោយភាគីម្ខាងទៀតបានទេ។ ប្រសិនបើអ្នកជួលព្រួយបារម្ភថា សាក្សីរបស់គេអាចនឹងមកកាន់តុលាការនោះ អ្នកជួលអាចនឹងចេញដីកាកោះបាន។ អ្នកជួលអាចទទួលបានដីកាកោះពីការិយាល័យក្រឡាបញ្ជី ហើយបន្ទាប់មកឲ្យអ្នកផ្សេងយកវាទៅជូនសាក្សីរបស់ពួកគេឲ្យបានមុនថ្ងៃជំនុំជម្រះក្តី។

ប្រសិនបើសាក្សីសុំ អ្នកជួលអាចត្រូវបង់ថ្លៃការធ្វើដំណើររបស់សាក្សី និងថ្លៃចំណាយចំពោះសាក្សី។ ($35/ក្នុងមួយថ្ងៃដោយបន្ថែមការចំណាយលើការធ្វើដំណើរតាមការជាក់ស្តែង។ Gov. Code 68093.) អ្នកជួលមិនត្រូវបង់ថ្លៃឲ្យការធ្វើដំណើររបស់ម្ចាស់ផ្ទះរបស់គេ ឬថ្លៃចំណាយលើសាក្សីរបស់ម្ចាស់ផ្ទះរបស់គេទេ ប្រសិនបើពួកគេទូរសព្ទទៅម្ចាស់ផ្ទះរបស់គេ ឬសាក្សីរបស់ម្ចាស់ផ្ទះរបស់គេជាសាក្សីផ្ទាល់ខ្លួនរបស់គេនោះ។

<u>ការចុះឈ្មោះនិងការនិយាយស្តីនៅក្នុងតុលាការ – វប្បធម៌បន្ទប់សវនាការ</u>

1. អាចនឹងមាននូវបញ្ជីឈ្មោះបិទនៅលើទ្វារបន្ទប់សវនាការ ឬនៅលើជញ្ជាំងជាប់នឹងទ្វារ។ អ្នកជួលគប្បីរកមើលសំណុំរឿងក្តីរបស់គេ ឬឈ្មោះនិងចាំលេខដែលស្ថិតនៅលើបញ្ជីបិទបង្ហាញ។

2. បន្ទាប់មក អ្នកជួលនឹងចូលទៅតាមទ្វារ ហើយចូលជួរដើម្បីប្រាប់ដល់ក្រឡាបញ្ជីថា ពួកគេបានមកដល់ហើយ លេខសំណុំរឿងរបស់ពួកគេ និងប្រាប់ថាពួកគេជាភាគីចុងចោទ។ នៅពេលនេះ អ្នកជួលក៏បញ្ជាក់ជាមួយនឹងក្រឡាបញ្ជីផងដែរថាតើអ្នកបកប្រែភាសាទំនេរទេ ប្រសិនបើអ្នកជួលត្រូវការម្នាក់នោះ។ បើសមស្រប អ្នកជួលក៏អាចបញ្ជាក់ជាមួយនឹងក្រឡាបញ្ជីថា តុលាការបានដឹងពីសំណើសុំការទទួលសមស្របរបស់អ្នកជួលជាមួយនឹងតុលាការហើយដែរ។

3. ក្រោយចុះឈ្មោះចូលរួចហើយ អ្នកជួលមានកន្លែងអង្គុយ និងត្រូវប្រាកដថាទូរសព្ទដៃរបស់គេត្រូវបានបិទឬដាក់ឲ្យគ្មានសម្លេងរោរ៍។ ប្រសិនបើអ្នកជួលមកដល់លឿនខ្លាំង ហើយបើចង់នោះ ពួកគេអាចសុំនិយាយជាមួយនឹងម្ចាស់ផ្ទះ ឬមេធាវីម្ចាស់ផ្ទះរបស់គេនៅតាមផ្លូវក្នុងបន្ទប់ខាងក្រៅបន្ទប់សវនាការក្នុងបំណងដោះស្រាយបញ្ចប់រឿងក្តីរបស់គេបាន។ (<u>សូមមើល</u>

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្តល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្តល់យោបល់ផ្នែកច្បាប់ដែរ។

ផ្នែកស្តីអំពីការដោះស្រាយបញ្ហា នៅដើមទំព័រទី 9។) ទោះជាយ៉ាងណា អ្នកជួលគួរតែត្រូវប្រាកដថា ពួកគេស្ថិតនៅក្នុងបន្ទប់សវនាការនៅពេលដែលចៅក្រមស្ថិតនៅលើ "សវនដ្ឋានចៅក្រម។" ("សវនដ្ឋានចៅក្រម" គឺជាតុដែលស្ថិតខាងមុខក្នុងបន្ទប់សវនការ ដែលចៅក្រមអង្គុយ "នៅលើសវនដ្ឋានចៅក្រម" មានន័យថា នៅពេលដែលចៅក្រមកំពុងអង្គុយនៅលើតុ)។

4. នៅពេលដែលចៅក្រមចូលមកក្នុងបន្ទប់សវនាការ គ្រប់គ្នានៅក្នុងបន្ទប់សវនាការអាចក្រោកឈរ។ នៅពេលចៅក្រមអង្គុយចុះ គ្រប់គ្នាអង្គុយចុះ។ នៅពេលចៅក្រមស្ថិតនៅលើសវនដ្ឋានចៅក្រម អ្នកដែលអាចគួរនិយាយគឺមានតែចៅក្រម គូភាគីដែលត្រូវបានហៅឲ្យឡើងមកខាងមុខចៅក្រម និងក្រឡាបញ្ជីតែប៉ុណ្ណោះ។

5. នៅពេលករណីរបស់អ្នកជួលត្រូវបានហៅ អ្នកជួលក្រោកឈរឡើង ប្រសិនបើអាច ហើយប្រាប់គោត្តនាមរបស់គេខ្លាំងៗ ឬបញ្ជាក់ថាជា "ភាគីចុងចោទ"។ បន្ទាប់មកអ្នកជួលដើរទៅកាន់សវនដ្ឋានចៅក្រម ហើយឈរប្រសិនបើពួកគេអាច នៅខាងមុខសញ្ញាដែលនិយាយថាភាគីចុងចោទ។
    a. ប្រសិនបើអ្នកជួលត្រូវការអ្នកបកប្រែភាសា ហើយអ្នកបកប្រែភាសាមិនទាន់មានវត្តមាននៅឡើយនោះ អ្នកជួលអាចស្នើសុំចៅក្រមនូវអ្នកបកប្រែភាសាម្នាក់។
    b. ប្រសិនបើអ្នកជួលនៅតែមិនមានឱកាសនិយាយជាមួយនឹងម្ចាស់ផ្ទះអំពីការព្យាយាមដើម្បីដោះស្រាយបញ្ហារឿងក្តីនោះ ហើយចង់បានឱកាសនេះ អ្នកជួលអាចសុំឲ្យចៅក្រមអនុញ្ញាតដល់ពួកគេមានពីរបីនាទីដើម្បីនិយាយជាមួយម្ចាស់ផ្ទះ និងមេធាវីម្ចាស់ផ្ទះទាក់ទងនឹងរឿងក្តីបាន។ បន្ទាប់មកអ្នកជួលនិងម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះដើរចូល

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្តល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្តល់យោបល់ផ្នែកច្បាប់ដែរ។

ទៅផ្លូវក្នុងបន្ទប់ ឬ ទៅក្នុងបន្ទប់ដាច់ដោយឡែកមួយ ប្រសិនបើមាន ហើយនិយាយជាមួយគ្នាទៅវិញទៅមក។ នៅពេលដែលគូភាគីបញ្ចប់ការនិយាយគ្នា ពួកគេនឹងត្រឡប់មកខាងក្នុងវិញ ហើយចុះឈ្មោះចូលឡើងវិញជាមួយនឹងក្រឡាបញ្ជីដើម្បីឲ្យបានរឿងក្តីរបស់ពួកគេហៅឡើងវិញនៅខាងមុខចៅក្រម។

សម្គាល់៖ ឈ្មោះសមស្របត្រូវហៅទៅកាន់ចៅក្រមគឺ "លោកចៅក្រម" និង "អង្គតុលាការជាទីគោរព។" នៅពេលគូភាគីស្ថិតនៅខាងមុខចៅក្រម គូរភាគីនឹងនិយាយទៅកាន់ចៅក្រម និងមិននិយាយរកគ្នានោះទេ។ ប្រសិនបើអ្នកជួលអាចធ្វើបាន ពួកគេគួរតែសម្លឹងទៅកាន់ចៅក្រម ហើយនិយាយទៅកាន់ចៅក្រមនៅពេលពួកគេនិយាយ ហើយមិននិយាយទៅកាន់ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះទេ។ ឧទាហរណ៍ អ្នកកំពុងតែស្ថិតនៅលើបង់ ហើយមេធាវីម្ចាស់ផ្ទះប្រាប់ដល់តុលាការថា អ្នកបានយល់ព្រមរើចេញ។ ជំនួសឲ្យការនិយាយថា "ទេ ខ្ញុំមិនបាននិយាយទេ តើអ្នកកំពុងនិយាយអំពីអ្វី" ទៅកាន់មេធាវីនោះ អ្នកគួរតែនិយាយបែបនេះទៅកាន់ចៅក្រម៖ "លោកចៅក្រម មេធាវីតំណាងឲ្យម្ចាស់ផ្ទះកំពុងតែនិយាយពីអ្វីមួយដែលខ្ញុំមិនបាននិយាយទេ។ អ្វីដែលខ្ញុំពិតជាបាននិយាយនោះគឺ ខ្ញុំអាចនឹងមានឆន្ទៈរើចេញ ប្រសិនបើពួកគេផ្តល់ពេលវេលាឲ្យខ្ញុំច្រើនបន្ថែមទៀត ប៉ុន្តែយើងមិនមានឱកាសបានពិភាក្សាអំពីបញ្ហានេះនៅឡើយទេ។ តើខ្ញុំអាចមានឱកាសដើម្បីពិភាក្សាចំណុចនេះជាមួយនឹងម្ចាស់ផ្ទះខ្ញុំនិងមេធាវីរបស់ពួកគេនៅតាមផ្លូវក្នុងសាលាក្តីបានទេ?"

## 6. B. ការជំនុំជម្រះក្ដី – ជាជំហានៗ

ផ្នែកនេះនឹងផ្តល់នូវលំហូរជាជំហានៗទូទៅ នៃរបៀបដែលទាំងអ្នកជួលនិងម្ចាស់ផ្ទះប្រាប់សាច់រឿងដល់គ្នាទៅវិញទៅមក និងពីរបៀបបង្ហាញភ័ស្តុតាងក្នុងអំឡុងជំនុំជម្រះក្តី រួមទាំងសាក្សីផងដែរ។

តើនរណាជានរណា ហើយអ្វីកើតឡើងនៅពេលណា?

ការជំនុំជម្រះក្តីរឿងបណ្តេញចេញអាចបញ្ចប់ទៅយ៉ាងលឿន។ ម្ចាស់ផ្ទះ (ភាគីដើមចោទ) នឹងបង្ហាញពីរឿងក្តីទាំងមូលរបស់គេមុន។ បន្ទាប់ពីនេះ អ្នកជួល (ភាគីចុងចោទ) បង្ហាញពីរឿងក្តីទាំងមូលរបស់គេ។ គូភាគីទាំងសងខាងមានឱកាសធ្វើទៅតាមជំហានៗដូចគ្នាដើម្បីព្យាយាមនិងបង្ហាញភ័ស្តុតាងរឿងក្តីរបស់ពួកគេ។ ជំហានទាំងនេះមាន៖

1. សេចក្តីថ្លែងចាប់ផ្តើម – សេចក្តីសង្ខេបខ្លីនៃទឡ្ហីករណ៍របស់ភាគីអំពីមូលហេតុដែលពួកគេគួរតែឈ្នះក្តី (ម្ចាស់ផ្ទះ ឬ អ្នកជួល) និងអ្វីដែលពួកគេចង់បង្ហាញ ឬមិនបង្ហាញនៅពេលជំនុំជម្រះក្តី។
2. ការធ្វើសក្ខីកម្មសាក្សី – ជាឱកាសមួយសម្រាប់ភាគីឲ្យនាំមនុស្សមកនិយាយក្នុងតុលាការ ដែលហៅថាសាក្សី ដើម្បីនិយាយអំពីព័ត៌មានដែលពួកគេដឹង ឬដើម្បីបញ្ជាក់ទៅលើរូបថត ឬ ឯកសារផ្សេងទៀត។
3. ការសួរដេញដោលសាក្សី – សួរសំណួរទាំងឡាយទៅលើសាក្សីទាំងឡាយរបស់ភាគីម្ខាងទៀត (ឧទាហរណ៍ អ្នកជួលសួរសំណួរសាក្សីដែលម្ចាស់ផ្ទះបាននាំមកឲ្យនិយាយ)។
4. ការសួរដេញដោលសាក្សីខ្លួនឯង – ជាពេលត្រូវសួរសាក្សីខ្លួនឯងរបស់ភាគីនៅក្រោយពីភាគីម្ខាងទៀតបានសួរដេញដោលសាក្សីរបស់គេនោះ។
5. ការបង្ហាញភ័ស្តុតាង – ជាឱកាសដើម្បីបង្ហាញភ័ស្តុតាងជាឯកសារនានា។

6. ការផ្តល់ទឡ្ហីករណ៍បិទបញ្ចប់ – ជាឱកាសសម្រាប់គូភាគីទាំងពីរផ្តល់នូវសេចក្តីសង្ខេបពីទឡ្ហីករណ៍របស់គេ អំពីអ្វីដែលភ័ស្តុតាងដែលបានបញ្ជាក់នៅក្នុងអំឡុងជំនុំជម្រះក្តី និងពីមូលហេតុដែលចៅក្រម ឬ គណៈវិនិច្ឆ័យគួរឯកភាពជាមួយពួកគេ។

ជំហាននីមួយៗត្រូវបានពន្យល់លម្អិតបន្ថែមទៀតខាងក្រោមសម្រាប់ទាំងម្ចាស់ផ្ទះ និងអ្នកជួល រួមទាំងមានឧទាហរណ៍និងគន្លឹះដ៏មានប្រយោជន៍នានាផងដែរ។ សម្គាល់៖ ចៅក្រមខ្លះនឹងមិនអនុញ្ញាតឲ្យមានការថ្លែងបើកនិង/ឬបិទបញ្ចប់ទឡ្ហីករណ៍នៅក្នុងករណីបណ្តេញចេញនោះទេ។ ប៉ុន្តែប្រសិនបើភាគីម្ខាងមានឱកាសថ្លែងបើក នេះគ្រាន់តែជាឧទាហរណ៍ទេ ភាគីម្ខាងទៀតត្រូវតែទទួលបានឱកាសធ្វើការថ្លែងបើកដែរ – ភាគីមួយអាចនៅតែសម្រេចឲ្យ "លើកលែង" ឬ មិនធ្វើការថ្លែងបើក ប៉ុន្តែពួកគេត្រូវតែទទួលបានឱកាសដើម្បីធ្វើវា។

<u>ផ្នែក 1 - ករណីរបស់ម្ចាស់ផ្ទះ</u>

ក្នុងអំឡុងការជំនុំជម្រះក្តីរឿងបណ្តេញចេញ ម្ចាស់ផ្ទះនិងទទួលបានឱកាសមុនដើម្បីបង្ហាញពីករណីរបស់គេ - ឬ ដើម្បីបញ្ជាក់ពីមូលហេតុដែលអ្នកជួលគួរត្រូវបានបណ្តេញចេញ។ ដើម្បីការពារក្តីរបស់គេ ម្ចាស់ផ្ទះ ឬ មេធាវីម្ចាស់ផ្ទះអាចនឹងហៅសាក្សី និង/ឬបង្ហាញភ័ស្តុតាង។ ក្នុងអំឡុងការបង្ហាញរឿងក្តីរបស់ម្ចាស់ផ្ទះ អ្នកជួលគួរតែស្តាប់ដោយប្រុងប្រយ័ត្ន និង/ឬ កត់ត្រាទុកនូវអ្វីមួយដែលម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះបង្ហាញថាវាមិនពិត ឬ មិនពិតទាំងស្រុងនោះ។ នេះនឹងជួយដល់ពួកគេឲ្យត្រៀមខ្លួនសម្រាប់ការសាកសួរដេញដោលសាក្សី និងដើម្បីធ្វើការជំទាស់។ ការសួរដេញដោយសាក្សី និងការជំទាស់ ត្រូវបានពិភាក្សានៅផ្នែកខាងក្រោមក្នុងលេខបួន។

1. **ការថ្លែងបើកសំណុំរឿង៖** ម្ចាស់ផ្ទះនឹងចាប់ផ្តើមដំណើរការករណីរបស់គេដោយបង្ហាញនូវសេចក្តីសង្ខេបជាមូលដ្ឋានពីមូលហេតុដែលអ្នកជួលគួរត្រូវបណ្តេញចេញ។

2. **សាក្សី៖** ម្ចាស់ផ្ទះនឹងហៅសាក្សី ហើយសួរសំណួរទាំងឡាយដែលពួកគេគិតថានឹងជួយបញ្ជាក់ពីមូលហេតុដែលអ្នកជួលគួរតែត្រូវបានបណ្តេញចេញ។ ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះ អាចសូម្បីតែហៅអ្នកជួលឲ្យផ្តល់កសិណាដើម្បីជួយបញ្ជាក់ដល់ករណីរបស់គេក៏បានដែរ។ ក្នុងអំឡុងការធ្វើបទបង្ហាញរបស់ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះ អ្នកជួលអាចនឹងជំទាស់ទៅនឹងអ្វីមួយដែលត្រូវបានលើកឡើង ប្រសិនបើពួកគេមានមូលដ្ឋានច្បាប់សម្រាប់ការជំទាស់នោះ។ ប្រសិនបើចៅក្រមនិយាយថា "ជំទាស់គ្មានប្រសិទ្ធិភាព" សាក្សីអាចឆ្លើយសំណួរបាន។ ប្រសិនបើចៅក្រមនិយាយថា "ជំទាស់មានប្រសិទ្ធិភាព" សាក្សីមិនអាចឆ្លើយសំណួរបានទេ។ (សូមមើលព័ត៌មានបន្ថែមខាងក្រោមស្តីពីការថ្លែងជំទាស់នៅក្នុងអំឡុងជំនុំជម្រះក្តី ហើយទំព័រទី 18 សម្រាប់ឧទាហរណ៍បន្ថែមពីការជំទាស់)។

3. **ការជំទាស់៖** លើកលែងតែការធ្វើសេចក្តីថ្លែងជំទាស់ តុលាការនឹងមិនពេញចិត្តឡើយ ហើយអាចនឹងស្តីបន្ទោសអ្នកជួល ប្រសិនបើពួកគេនិយាយកាត់ ភាគីម្ខាងទៀត ឬ និយាយក្នុងខណៈដែលភាគីម្ខាងទៀតកំពុងតែបង្ហាញពីករណីរបស់គេនោះ។ ការជំទាស់ជាទូទៅក្នុងអំឡុងជំនុំជម្រះក្តីគឺ "ភាពពាក់ព័ន្ធ" (សំណួរកំពុងត្រូវបានសួរមិនពាក់ព័ន្ធដល់រឿងក្តីទេ) ឬ "ពាក្យចរចាមអារ៉ាម" (សាក្សីកំពុងតែលើកឡើងវិញពីអ្វីដែលអ្នកផ្សេងបាននិយាយនៅខាងក្រៅតុលាការដើម្បីបញ្ជាក់ពីអ្វីមួយដែលបុគ្គលបាននិយាយគឺជាអ្វីដែលពិតជាបានកើតឡើងមែន)។ ឧទាហរណ៍មួយនៃការថ្លែងដោយពាក្យចរចាមអារ៉ាមដោយម្ចាស់ផ្ទះគួរតែជា៖ "អ្នកជិតខាងអ្នកជួលបាន

ប្រាប់ខ្ញុំច្រើនដងថា អ្នកជួលធ្វើឲ្យមានសម្លេងខ្លាំងៗនៅពាក់កណ្ដាលអធ្រាត្រ" នៅពេលដែលអ្នកជិតខាង មិនមានវត្តមានជាសាក្សីនៅក្នុងតុលាការនោះ។

នេះជាឧទាហរណ៍មួយពីរបៀបដែលអាចធ្វើការជំទាស់ក្នុងអំឡុងធ្វើសក្ខីកម្មសាក្សី៖ មេធាវីម្ចាស់ផ្ទះសួរសាក្សីម្ចាស់ផ្ទះពីមូលហេតុដែលអ្នកជួលបានធ្វើអ្វីមួយ។ អ្នកជួលស្រែកឡើងខ្លាំងៗថា "សុំជំទាស់ នេះជាការទាញការសន្និដ្ឋាន" ភ្លាមៗក្រោយពីម្ចាស់ផ្ទះសួរសំណួរហើយរង់ចាំឲ្យចៅក្រម "សម្រេច" (សម្រេចថាតើពួកគេឯកភាព ឬមិនឯកភាពទៅនឹងការជំទាស់)។ នៅក្នុងករណីនេះ ចៅក្រមនឹងនិយាយថា "ជំទាស់មានប្រសិទ្ធិភាព" ដែលមានន័យថាសាក្សីរបស់ម្ចាស់ផ្ទះមិនអាចឆ្លើយសំណួរបានទេ ពីព្រោះអ្នកជួលបានធ្វើការជំទាស់ដោយមានសុពលភាព។

4. **ការសាកសួរដេញដោលសាក្សីដោយភាគីបដិបក្ខ៖** ភ្លាមៗក្រោយម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះបញ្ចប់ការសួរសំណួរដល់សាក្សី អ្នកជួលនឹងត្រូវបានផ្ដល់ឱកាសឲ្យសួរសំណួរទៅដល់សាក្សីនោះដែរ។ ដំណើរការនេះហៅថា "ការសួរដេញដោលសាក្សីដោយភាគីបដិបក្ខ"។ មូលហេតុនៃការសួរដេញដោលសាក្សីដោយភាគីបដិបក្ខនោះ គឺដើម្បីទាំងបញ្ជាក់ពីអ្វីមួយដែលសាក្សីបាននិយាយ ដែលអាចជួយដល់ករណីរបស់អ្នកជួល ឬ ព្យាយាមដើម្បីកាត់បន្ថយគ្រោះថ្នាក់នៃអ្វីមួយដែលពួកគេបាននិយាយ ដែលនឹងប៉ះពាល់ដល់ករណីរបស់អ្នកជួល។

វាមានប្រយោជន៍ប្រសិនបើអ្នកជួលកត់ត្រាទុកនូវអ្វីដែលសាក្សីនិយាយនៅពេលដែលម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះសួរសំណួរ និងសរសេរចូលនូវចំណុចទាំងឡាយណាដែលអ្នកជួលចង់ឲ្យសាក្សីបញ្ជាក់ឡើងវិញ ឬឆ្លើយ។

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្ដល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្ដល់យោបល់ផ្នែកច្បាប់ដែរ។

ធ្វើបែបនេះ នៅពេលដល់វេនរបស់អ្នកជួលត្រូវសួរសំណួរដេញដោលសាក្សីភាគីបដិបក្ខនោះ ពួកគេបានត្រៀមរួចរាល់។

**សម្គាល់៖** អ្នកសួរដេញដោលសាក្សីភាគីបដិបក្ខ មិនត្រូវសួរសាក្សីពីកម្មវត្ថុថ្មីតែផ្ទុយទៅវិញពួកគេគ្រាន់តែត្រូវសួរសំណួរដល់សាក្សីពីអ្វីដែលត្រូវបានពិភាក្សាគ្នារួចនៅក្នុងអំឡុងការសួរដេញដោលផ្ទាល់។ នេះមានន័យថា ប្រសិនបើម្ចាស់ផ្ទះ/សាក្សីមេធាវីរបស់ម្ចាស់ផ្ទះមិនត្រូវបានសួរអំពីកម្មវត្ថុដែលនឹងមានប្រយោជន៍ដល់អ្នកជួលនោះទេ អ្នកជួលនឹងត្រូវតែរង់ចាំដើម្បីសួរអំពីកម្មវត្ថុនោះរហូតដល់វេនរបស់អ្នកជួលដើម្បីបង្ហាញពីករណីរបស់អ្នកជួលមកដល់។ បន្ទាប់មក ពួកគេអាចហៅបុគ្គលនេះជាសាក្សីរបស់គេផ្ទាល់ ហើយសួរសាក្សីនោះអំពីកម្មវត្ថុនោះ។

ឧទាហរណ៍៖ ម្ចាស់ផ្ទះបានសួរដល់សាក្សីតែអំពីរឿងការបង់ថ្លៃឈ្នួល ប៉ុន្តែមិនបានសួរអំពីលក្ខខណ្ឌមិនល្អរបស់ផ្ទះអ្នកជួលនៅក្នុងការសួរដេញដោលផ្ទាល់នោះទេ។ ក្នុងអំឡុងការសួរដេញដោលសាក្សីដោយភាគីបដិបក្ខ ពួកគេអាចសួរសំណួរទាំងឡាយដែលពាក់ព័ន្ធដល់ការបង់ប្រាក់។ ក្រោយមកនៅពេលដល់វេនអ្នកជួលត្រូវបង្ហាញករណីរបស់គេ អ្នកជួលអាចហៅបុគ្គលនេះថាជាសាក្សីរបស់ពួកគេ ដើម្បីសួរពួកគេអំពីលក្ខខណ្ឌមិនល្អនៅក្នុងផ្ទះរបស់អ្នកជួល។

5. **ការសួរដេញដោលសាក្សីខ្លួនឯង៖** ក្រោយពីអ្នកជួលបញ្ចប់ការសួរដេញដោលសាក្សី មេធាវីម្ចាស់ផ្ទះអាចនឹងធ្វើការ "សួរសាក្សីខ្លួនឯងឡើងវិញ" (មានន័យថាសួរសាក្សីដដែលជាចុងក្រោយអំពីចម្លើយរបស់សាក្សីក្នុងអំឡុងការសួរដេញដោលសាក្សីដោយភាគីបដិបក្ខ)។ បន្ទាប់មក ចៅក្រមនឹងឲ្យ

បញ្ចប់សាក្សី ហើយមេធាវីម្ចាស់ផ្ទះអាចបន្តបង្ហាញនូវភ័ស្តុតាងផ្សេងទៀត ហើយហៅសាក្សីផ្សេងទៀតសម្រាប់ម្ចាស់ផ្ទះ។

6. **ការបង្ហាញភ័ស្តុតាង៖** ក្នុងអំឡុងវេនរបស់ពួកគេបង្ហាញនូវករណីរបស់គេ ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះ ក៏អាចបង្ហាញភ័ស្តុតាងជាឯកសារនានាជាវត្ថុតាងដែលពួកគេគិតថានឹងជួយបញ្ជាក់ពីមូលហេតុដែលអ្នកជួលគួរត្រូវបណ្តេញចេញ។ ឧទាហរណ៍ទាំងឡាយនៃវត្ថុតាងអាចជារូបថត ឬសោយហ៊ុយធនាគារលើមូលប្បទានប័ត្រដែលមានសាច់ប្រាក់។

   នៅពេលបង្ហាញភ័ស្តុតាងដល់តុលាការ ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះចាំបាច់ត្រូវធ្វើរឿងមួយចំនួនដើម្បីឲ្យប្រាកដថាភ័ស្តុតាងត្រូវបាន "ត្រូវបាននបញ្ចូលទៅក្នុងសំណុំរឿង។" ប្រសិនបើភ័ស្តុតាងមិនត្រូវបាន "បញ្ចូល" ត្រឹមត្រូវទេ ពេលនោះចៅក្រម ឬ គណៈវិនិច្ឆ័យមិនអាចពិចារណាវាបានទេនៅពេលធ្វើសេចក្តីសម្រេចជាចុងក្រោយនោះ។

   ដំបូង អ្នកជួលត្រូវបានអនុញ្ញាតឲ្យមើលវត្ថុតាងដើម និងត្រូវតែផ្តល់ឲ្យមួយច្បាប់នៃវត្ថុតាង។ ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះ ក៏នឹងចាំបាច់ត្រូវឲ្យម្ចាស់ផ្ទះ ឬ សាក្សីផ្សេងទៀតឆ្លើយសំណួរអំពីភ័ស្តុតាងជាឯកសារ ដើម្បីបញ្ជាក់ពីទីតាំងដែលជាប្រភពឯកសារ និងថាវាពិតប្រាកដ ហើយជាច្បាប់ត្រឹមត្រូវទៀតផង។ អ្នកជួលត្រូវបានអនុញ្ញាតឲ្យជំទាស់ទៅនឹងភ័ស្តុតាងដែលកំពុងត្រូវដាក់មកដោយផ្អែកលើ "ការដាក់បន្ទុក" ប្រសិនបើម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះមិនអាចបង្ហាញពីប្រភពឯកសារបានទេនោះ ឬថាឯកសារទាំងនោះពិត និងជាច្បាប់ត្រឹមត្រូវទេនោះ។

សូមមើល "ផ្នែកទី 2 – ករណីរបស់អ្នកជួល" ខាងក្រោមសម្រាប់ជាព័ត៌មានបន្ថែមអំពីការបញ្ចូលភស្តុតាងនៅក្នុងតុលាការ។

ផ្នែក 2 - ករណីរបស់អ្នកជួលៈ

ដើម្បីកុំឲ្យចាញ់ក្តី អ្នកជួលចាំបាច់ត្រូវបង្ហាញថា ម្ចាស់ផ្ទះ៖

(1) បរាជ័យក្នុងការបង្ហាញនូវករណីរបស់ខ្លួន ឬ
(2) ថាអ្នកជួលមានការការពារដែលរារាំងមិនឲ្យម្ចាស់ផ្ទះឈ្នះក្តីបាន។

ជំហានទាំងឡាយនៅក្នុងករណីរបស់អ្នកជួលធ្វើទៅតាមលំដាប់និងបែបបទដូចគ្នាទៅនឹងជំហានទាំងឡាយនៅក្នុងករណីរបស់ម្ចាស់ផ្ទះដែរ។

**សម្គាល់៖ ការស្នើសុំទម្លាក់ការចោទប្រកាន់។** ក្រោយពីដើមចោទ "សម្រាក" ឬបានបង្ហាញនូវសាក្សីទាំងអស់ហើយ និងបានបញ្ចូលភ័ស្តុតាងទាំងអស់ដែលគេចង់បញ្ចូល ដើម្បីព្យាមនិងបង្ហាញពីករណីរបស់គេស្តីពីមូលហេតុដែលអ្នកជួលគួរតែត្រូវបានបណ្តេញចេញរួចមកនោះ អ្នកជួលអាចសុំចៅក្រមបដិសេធរឿងក្តីដោយស្នើសុំឲ្យបដិសេធរឿងក្តី។ ក្រមច្បាប់នីតិវិធីរដ្ឋប្បវេណី §581c សម្រាប់ឧទាហរណ៍ អ្នកជួលអាចនិយាយថា "អង្គតុលាការជាទីគោរព ដោយក្តីគោរពខ្ញុំសូមឲ្យធ្វើការទម្លាក់រឿងក្តីនេះចោល។" ចៅក្រមនឹង "អនុញ្ញាតតាមសំណើ" ឬឯកភាពជាមួយនឹងសំណើសុំទម្លាក់ការចោទប្រកាន់ ប្រសិនបើចៅក្រមរកឃើញថាម្ចាស់ផ្ទះមិនអាចបញ្ជាក់ពីករណីរបស់គេដោយផ្អែកលើភ័ស្តុតាងដែលបានស្តាប់រហូតមកដល់ពេលនេះ។ ប្រសិនបើសំណើនេះត្រូវបានអនុញ្ញាតនោះ អ្នកជួលមិនចាំបាច់ត្រូវបង្ហាញនូវករណីរបស់គេទេ ពីព្រោះរឿងក្តីនឹងត្រូវចប់សព្វគ្រប់ទៅហើយ។ ប្រសិនបើចៅក្រមបដិសេធទៅនឹងការស្នើសុំឲ្យទម្លាក់ការចោទប្រកាន់នោះ អ្នកជួលនៅតែមានឱកាសបង្ហាញពីករណីរបស់គេដែលត្រូវបានហៅថាការការពារក្តី។

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្តល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្តល់យោបល់ផ្នែកច្បាប់ដែរ។

1. **ការថ្លែងបើកសំណុំរឿង៖** អ្នកជួលនឹងជម្រាប់ពីជ្រុងនៃសាច់រឿងរបស់គេទៅដល់ចៅក្រម ឬ គណៈវិនិច្ឆ័យក្ដី។ មនុស្សភាគច្រើនរួមទាំងចៅក្រម និង គណៈវិនិច្ឆ័យផង យល់ថាព័ត៌មានមានលក្ខណៈងាយស្រួលយល់ ប្រសិនបើវាត្រូវបានបង្ហាញឡើងតាមលក្ខណៈជាកាលប្បវត្តិ ដែលមានន័យថាតាមលំដាប់ដែលវាបានកើតឡើង។ អ្នកជួលនឹងគ្រាន់តែចង់បញ្ចូលនូវសេចក្ដីលម្អិតដែលពាក់ព័ន្ធដល់សាច់រឿង និងពន្យល់ពីមូលហេតុដែលសេចក្ដីលម្អិតទាំងនោះសំខាន់។ ចៅក្រមអាចនឹងសួរកាត់អ្នកជួល។ អ្នកជួលនឹងចាំបាច់ត្រូវឆ្លើយសំណួររបស់ចៅក្រមហើយបន្ទាប់មកបន្តបង្ហាញពីសាច់រឿងរបស់គេ។

   សម្គាល់៖ អ្នកជួលដែលអាចនឹងមានអារម្មណ៍ភ័យអំពីការភ្លេចអ្វីមួយ ឬនិយាយខុសសាច់រឿងក្នុងករណីត្រូវបានកាត់នោះ អាចយកជាប់ជាមួយនូវកំណត់ចំណាំនានា ឬគ្រោងគោលៗនៃអ្វីដែលគេចង់និយាយមកបាន។ ធ្វើបែបនេះ ប្រសិនបើចៅក្រមសួរសំណួរកាត់ ពួកគេអាចមើលកំណត់ចំណាំរបស់គេ ដើម្បីបន្តនិយាយពីកន្លែងចាស់របស់គេ។

2. **សាក្សី៖** អ្នកជួលនឹងមានឱកាសដើម្បីបង្ហាញពីសាក្សីរបស់គេផ្ទាល់ ដូចគ្នាទៅនឹងម្ចាស់ផ្ទះបានបង្ហាញពីសាក្សីរបស់គេដែរ។ អ្នកជួលច្រើនយល់ថាវាមានប្រយោជន៍ត្រូវកត់សំណួរ ឬ ចំណុចសំខាន់ៗរបស់គេ ដែលពួកគេចង់ឲ្យសាក្សីនិយាយទុកជាមុន ដូច្នេះពួកគេបានចាំគ្រប់អ្វីៗតែក្នុងរយៈពេលមួយភ្លែត។

   អ្នកជួលនឹងហៅសាក្សីរបស់គេម្ដងមួយៗ។ សាក្សីទាំងឡាយអាចប្រាប់ទៅដល់ចៅក្រមតែអ្វីដែលពាក់ព័ន្ធទៅនឹងមូលហេតុដែលអ្នកជួលត្រូវបណ្ដេញចេញ។ សាក្សីទាំងឡាយក៏អាចផ្ដល់ជាកសិណចំពោះអ្វីៗដែលពួកគេបានឃើញ ឮ ដឹងក្លិន ឬ មានអារម្មណ៍ដោយផ្ទាល់ខ្លួន។ សាក្សីទាំងឡាយនឹងមិនអាចចាប់ផ្ដើមនិយាយដោយខ្លួនឯងបានទេ។ ផ្ទុយទៅវិញ អ្នក

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្ដល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្ដល់យោបល់ផ្នែកច្បាប់ដែរ។

ជួលត្រូវសួរដល់សាក្សីរបស់គេ ដើម្បីឲ្យគេផ្តល់ព័ត៌មាន។ ចៅក្រមនឹងមិនសួរសាក្សីរបស់អ្នកជួលជំនួសឲ្យអ្នកជួលនោះទេ។ ទោះជាយ៉ាងណា ចៅក្រមអាចនឹងមានសំណួរមួយចំនួនសួរដល់សាក្សីទាំងឡាយទាំងក្នុងអំឡុងពេលសួរដេញដោលរបស់អ្នកជួល ឬនៅក្រោយពីអ្នកជួលបញ្ចប់ការសួរដេញដោលដល់សាក្សី។ អ្នកជួលក៏នឹងបញ្ចូលនូវរាល់ភ័ស្តុតាងដែលពួកគេតាមការចង់បាន តាមរយៈសាក្សីទាំងឡាយរបស់គេក្នុងខណៈសាក្សីរបស់គេកំពុងផ្តល់កសិណនោះ។ (សូមមើលផ្នែកបន្ទាប់ស្តីពីភ័ស្តុតាងដាក់បន្ទុក។)

វាច្រើនតែមានប្រយោជន៍ដែលចៅក្រមនិង/ឬគណៈវិនិច្ឆ័យដឹងថា សាក្សីជានរណា តើពួកគេមានទំនាក់ទំនងបែបណាជាមួយនឹងបុគ្គលដែលហៅពួកគេមកធ្វើជាសាក្សី ហើយតើពួកគេដឹងអ្វីដែលគេដឹងតាមរបៀបណា។ ការធ្វើបែបនេះត្រូវបានគេហៅថា "ការដាក់បន្ទុក។" នេះជាសំណួរជាច្រើនដែលជាគំរូដែលផ្តល់ជាឧទាហរណ៍ពីរបៀបដាក់បន្ទុកសម្រាប់ព័ត៌មានដែលអ្នកជួលព្យាយាមឲ្យសាក្សីជួយឆ្លើយ។

- តើអ្នកឈ្មោះអ្វី?
- តើអ្នកជាប់ពាក់ព័ន្ធទៅនឹងផ្ទះលេខ 9 នៅផ្លូវ 123 យ៉ាងដូចម្តេច?
- តើធ្លាប់បានចូលទៅខាងក្នុងផ្ទះនេះពីមុនមកទេ?
- តើមានបន្ទប់ទឹកទេ?
- តើអ្នកបានប្រើបន្ទប់ទឹកទេ?
- តើបន្ទប់ទឹកមានបញ្ហាអ្វីទេនៅពេលអ្នកចង់ប្រើវា?
- សូមរៀបរាប់ពីបញ្ហា។

ដូចបានបង្ហាញនៅក្នុងឧទាហរណ៍នេះ ដើម្បីឲ្យអ្នកជិតខាងម្នាក់មកធ្វើជាសាក្សីអំពីលក្ខខណ្ឌនៃបន្ទប់ទឹកនោះ ចៅក្រម ឬគណៈវិនិច្ឆ័យដំបូងនឹង

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្តល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្តល់យោបល់ផ្នែកច្បាប់ដែរ។

ចង់ដឹងថាតើសាក្សីនោះជានរណា និងតើដឹងពីអ្វីដែលគេបានដឹងអំពីបន្ទប់ទឹកនោះយ៉ាងដូចម្ដេច។ ចំណុចនេះជួយដល់ចៅក្រម ឬ គណៈវិនិច្ឆ័យសម្រេចថាតើសាក្សីនិងព័ត៌មានដែលបានផ្ដល់មកអាចជឿជាក់បានប៉ុណ្ណា។

ក្នុងអំឡុងការបង្ហាញសាក្សីរបស់អ្នកជួល ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះ អាចនឹងជំទាស់ទៅនឹងសំណួររបស់អ្នកជួល។ នៅពេលករណីនេះកើតឡើង អ្នកជួលរង់ចាំឲ្យចៅក្រមលោកសម្រេចទៅលើការជំទាស់មុននឹងបន្តទៅទៀត។ ប្រសិនបើចៅក្រមនិយាយថា "ជំទាស់គ្មានប្រសិទ្ធិភាព" សាក្សីអាចឆ្លើយសំណួរបាន។ ប្រសិនបើចៅក្រមនិយាយថា "ជំទាស់មានប្រសិទ្ធិភាព" សាក្សីមិនអាចឆ្លើយសំណួរបានទេ។ ចៅក្រមនឹងទំនងជាអនុញ្ញាតឲ្យអ្នកជួលសួរសំណួរតាមរបៀបផ្សេង ("រៀបពាក្យ" សំណួរឡើងវិញ)។

ការជំទាស់ភាគច្រើនគឺពាក្យចចាមអារ៉ាម។ ការលើកឡើងខាងក្រោមជាឧទាហរណ៍នៃពាក្យចចាមអារ៉ាម៖ "ជាងប្រព័ន្ធទឹកបានប្រាប់ខ្ញុំថា ផ្ទះរបស់ខ្ញុំមិនអាចរស់នៅបានទេ។" ដើម្បីបញ្ចៀសបញ្ហាពាក្យចចាមអារ៉ាមនោះ អ្នកជួលអាចហៅជាងប្រព័ន្ធទឹកមកធ្វើជាសាក្សី ហើយឲ្យជាងប្រព័ន្ធទឹកនោះពន្យល់ពីលក្ខខណ្ឌប្រព័ន្ធទឹកដែលធ្វើឲ្យផ្ទះរបស់អ្នកជួលមិនអាចនៅបាន។ ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះ ពេលនោះនឹងមានឱកាសសួរដេញដោលសាក្សីជាជាងប្រព័ន្ធទឹករបស់គូបដិបក្ខបាន។

3. **ការសាកសួរដេញដោលសាក្សីដោយគូរបដិបក្ខ៖** ក្រោយពីអ្នកជួលបញ្ចប់ការសួរសំណួររបស់គេទៅដល់សាក្សីនីមួយៗរួចមក ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះនឹងមានឱកាសសួរដេញដោលសាក្សីគូបដិបក្ខដែលជាសាក្សីរបស់អ្នកជួល។ ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះគ្រាន់តែអនុញ្ញាតឲ្យសួរសំណួរទាំងឡាយអំពីកម្មវត្ថុដូចគ្នាទៅនឹងសំណួរទាំងឡាយដែលអ្នកជួលបានសួរ។ ប្រសិនបើ

ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះសួរអំពីកម្មវត្ថុផ្សេង អ្នកជួលអាចជំទាស់ទៅនឹងសំណួរថា "ជាសំណួរមិនពាក់ព័ន្ធ។"

4. **ការសាកសួរសាក្សីខ្លួនឡើងវិញ៖** ក្រោយពីការសាកសួរសាក្សីគូបដិបក្ខដោយម្ចាស់ផ្ទះ/មេធាវីម្ចាស់រួចមក អ្នកជួលអាចសួរសំណួរបន្តទៅដល់សាក្សីរបស់ខ្លួនបាន។ ដំណើរការនេះហៅថា ការសួរដេញដោលសាក្សីខ្លួនឯង "ឡើងវិញ"។ អ្នកជួលត្រូវកំណត់សំណួររបស់គេចំពោះកម្មវត្ថុដែលម្ចាស់ផ្ទះទើបតែបានសួរសាក្សីរបស់ខ្លួន។ ឧទាហរណ៍ ប្រសិនបើម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះកាត់ពាក់កណ្តាលចម្លើយសាក្សីរបស់អ្នកជួល ឬ អ្នកជួលដឹងថាសាក្សីរបស់គេអាចនឹងនិយាយអ្វីមួយដែលមានប្រយោជន៍ដល់កម្មវត្ថុនោះ អ្នកជួលអាចសួរសំណួរនោះនៅជុំដែលត្រូវសួរសាក្សីខ្លួនឡើងវិញ។

5. **ការដាក់បន្ទុកភ័ស្តុតាងទៅក្នុងសំណុំរឿង៖** មានមធ្យោបាយមួយដែលគូភាគីត្រូវបង្ហាញពីភ័ស្តុតាងដើម្បីឲ្យប្រាកដថាភ័ស្តុតាងដែលពួកគេបានយកមកកាន់ការជំនុំជម្រះ អាចត្រូវបានពិចារណាដោយចៅក្រម ឬ គណៈវិនិច្ឆ័យ។ ផ្នែកខាងក្រោម ផ្តល់នូវឧទាហរណ៍ទាំងឡាយពីរបៀបដែលអ្នកជួលអាចដាក់បន្ទុកភ័ស្តុតាង។

**ឧទាហរណ៍ 1**

អ្នកជួលមិនបានបង់ប្រាក់ឈ្នួលពីព្រោះតែម្ចាស់ផ្ទះមិនបានដោះស្រាយបញ្ហាកើតមាននៅផ្ទះរបស់គេ។

A. អ្នកជួលបានថតចម្លងរូបភាព និងឯកសារនីមួយៗចំនួន 3ច្បាប់ដែលគេចង់ប្រើ។ នៅខាងខ្នងនៃរូបភាព ឬនៅខាងមុខនៃទំព័រដំបូងរបស់ឯកសារ អ្នកជួលសរសេរថា វត្ថុតាងភាគីចុងចោទ A (ទាំង 3ច្បាប់នឹងនិយាយថា វត្ថុតាង A)។ នៅលើរូបភាព ឬឯកសារបន្ទាប់ អ្នកជួល សរសេរ

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្តល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្តល់យោបល់ផ្នែកច្បាប់ដែរ។

ថា វត្ថុតាងភាគីចុងចោទ B (នៅលើទាំង 3ច្បាប់)។ នៅលើរូបភាព ឬឯកសារបន្ទាប់ អ្នកជួលសរសេរថា វត្ថុតាងភាគីចុងចោទ C (នៅលើទាំង 3ច្បាប់) និងធ្វើបែបនេះជាបន្តបន្ទាប់។

B. អ្នកជួលជម្រាបទៅចៅក្រមថា៖ "ខ្ញុំមិនបានបង់ថ្លៃឈ្នួលទេ ដោយសារតែលក្ខខណ្ឌមិនសមប្រកប ហើយម្ចាស់ផ្ទះមិនបានមកជួសជុល។"

C. អ្នកជួលបានផ្តល់ច្បាប់ថតចម្លងនៃរូបភាព ឬឯកសារទៅឲ្យម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះ ហើយបន្ទាប់មកផ្តល់ច្បាប់ថតចម្លងនៃរូបភាព ឬឯកសារទៅជូនចៅក្រម។

D. អ្នកជួលអាចពន្យល់រូបភាពទាំងនោះម្តងមួយៗជាមួយនឹងចៅក្រម និងជម្រាបដល់ចៅក្រមនូវព័ត៌មានដូចខាងក្រោមអំពីរូបភាពនីមួយៗ៖

1. អ្នកជួលបញ្ជាក់ពីរូបភាពថាជា<u>រូបភាពនៃលក្ខខណ្ឌដែលមានលក្ខណៈយុត្តិធម៌និងត្រឹមត្រូវ</u>នៅពេលដែលរូបភាពត្រូវបានថត ហើយ/ឬ ដោយសារតែលក្ខខណ្ឌនៅដដែលនៅពេលនេះ ហើយថា<u>អ្នកជួលដឹងច្បាស់</u>ពីអ្វីដែលបានបង្ហាញនៅក្នុងរូបភាព។ (ថ្វីបើវាតម្រូវយករូបថតនោះមកដាក់បន្ទុកក៏ពិតមែន តែអ្នកជួលត្រូវបានត្រៀមឆ្លើយដោយបង្ហាញថា <u>នរណា</u>ជាអ្នកថតរូបនោះ ហើយវាត្រូវបានថត<u>នៅពេលណា</u>។)
2. អ្នកជួលបញ្ជាក់ពីអ្វីដែលពិតជាដូចត្រូវបានបង្ហាញនៅក្នុងរូបភាពមែន។ ឧទាហរណ៍ អ្នកជួលនិយាយថា "នៅពេលបើកទឹក ទឹកលេចនៅខាងក្រោមឡាបូ ហើយអ្នកត្រូវត្រងទឹកដើម្បីកុំឲ្យវាហៀរហូរពេញបន្ទប់។ អ្នកអាចឃើញធុងទឹកពណ៌លឿងរបស់ខ្ញុំដែលស្ថិតនៅខាងក្រោមឡាបូ។"
3. អ្នកជួលបញ្ជាក់ឲ្យដឹងពីរយៈពេលដែលបញ្ហាបានកើតឡើង។ អ្នកជួលត្រូវតែនិយាយឲ្យបានជាក់លាក់ពីបញ្ហា។ អ្នកជួលដាក់បញ្ចូលនូវភស្តុតាងណាមួយដែលពួកគេមានអំពីពេលវា

ដែលបញ្ហានេះបានចាប់ផ្តើម ដូចជារបាយការណ៍អ្នកត្រួតពិនិត្យផ្នែកសុខភាព។

4. អ្នកជួលបញ្ជាក់ពីពេលវេលាដែលគេបានប្រាប់ទៅអ្នកគ្រប់គ្រង/ម្ចាស់ផ្ទះ អំពីបញ្ហា។ អ្នកជួលដាក់បញ្ចូលនូវហេតុការណ៍ពាក់ព័ន្ធ ដូចជាថាតើគេប្រាប់បញ្ហានេះដល់ម្ចាស់ផ្ទះញឹកញាប់ប៉ុណ្ណា។ ជាថ្មីម្តងទៀត នៅទីនេះអ្នកជួលត្រូវតែលើកឡើងឲ្យបានជាក់លាក់ –ឧទាហរណ៍ អ្នកជួលឆ្លើយថា "ប្រាប់រហូត" អ្នកជួលត្រូវតែនិយាយ "រៀងរាល់ពីរថ្ងៃម្តងពេញមួយខែ" ឬ "នៅថ្ងៃទី9 ខែវិច្ឆិកា ឆ្នាំ2020 ខ្ញុំបានហៅទូរសព្ទទៅកាន់លោកម្ចាស់ផ្ទះ Notagood ហើយបានផ្ញើសារជាសម្លេងទុកប្រាប់គាត់អំពីការលេចទឹកនៅក្នុងសារជាសម្លេងនោះ។ នៅថ្ងៃទី10 ខែវិច្ឆិកា ឆ្នាំ2020 ខ្ញុំបានផ្ញើសារជាអក្សរជូន Mr. Notagood ហើយបានសុំឲ្យជួយចំពោះបញ្ហាទឹកលេចនេះ។ នៅថ្ងៃទី11 ខែវិច្ឆិកា ឆ្នាំ2020 ខ្ញុំបានផ្ញើអ៊ីម៉ែលជូន Mr. Notagood ហើយបានសុំឲ្យជួយចំពោះបញ្ហាទឹកលេចនេះ។ ហើយនៅថ្ងៃទី12 ខែវិច្ឆិកា ឆ្នាំ2020 ខ្ញុំបានផ្ញើលិខិតនេះជូន Mr. Notagood ដែលបានដាក់កំណត់សម្គាល់ថាជាវត្ថុតាងទី 4 របស់ចុងចោទ។ លោកអាចមើលឃើញបង្កាន់ដៃទទួលចេញដោយការិយាល័យប្រៃសណីយ៍ ចុះថ្ងៃទី12 ខែវិច្ឆិកា ឆ្នាំ2020 ដែលជាការបញ្ជាក់បន្ថែមទៅលើលិខិតដែលខ្ញុំបានផ្ញើ។ បង្កាន់ដៃនេះត្រូវបានដាក់សំគាល់ថាជាវត្ថុតាងទី 5។"

5. **អ្នកជួលស្នើសុំឲ្យលោកចៅក្រមបញ្ចូលរូបថតជា "ភ័ស្តុតាងដាក់បន្ទុក។"**

6. អ្នកជួលបញ្ជាក់ថាតើម្ចាស់ផ្ទះបានជួសជុលបញ្ហាឬអត់។ សម្រាប់ជាឧទាហរណ៍ អ្នកជួលជម្រាបទៅអង្គចៅក្រមឱ្យបានជ្រាប

ប្រសិនបើម្ចាស់ផ្ទះបានសន្យាដោះស្រាយបញ្ហា ប៉ុន្តែបន្ទាប់មក មិនដែលបានធ្វើ។

7. ប្រសិនបើអ្នកជួល ឬ ក្រុមគ្រួសារអ្នកជួល ឬ មិត្តភក្តិមិនធ្វើឲ្យមានបញ្ហាទេ អ្នកជួលជម្រាបដល់ចៅក្រម ហើយដាក់បញ្ចូលនូវព័ត៌មានពាក់ព័ន្ធ។ ឧទាហរណ៍ ប្រសិនបើមានកន្លាត អ្នកជួលគួរនិយាយថា "គ្រួសាររបស់ខ្ញុំនិងខ្ញុំមិនទុកចំណីអាហារចោលខាងក្រៅទេ។ យើងយកសម្រាមយើងចោលនៅពេលវាពេញ ហើយទុកដាក់សម្រាមជាកំប៉ុងនៅក្នុងទូរដើម្បីកុំឲ្យវាស្ថិតនៅខាងក្រៅកណ្តាលវាល។ យើងក៏បានលាងសម្អាតចានក្រោយពេលបរិភោគ ហើយមិនទុកចានចោលនៅក្នុងឡាប្ងលាងចោលពេលយប់ទេ។"

8. អ្នកជួលជម្រាបជូនចៅក្រមអំពីរបៀបដែលបញ្ហាប៉ះពាល់ដល់អ្នកជួលនិងក្រុមគ្រួសាររបស់គេ។ ឧទាហរណ៍ សម្រាប់លេចទឹក អ្នកជួលគួរនិយាយ "ដោយសារតែឡាប្ងលេចទឹកនោះ វាធ្វើឲ្យមានអារម្មណ៍តានតឹងខ្លាំងណាស់នៅពេលលាងចានម្តងៗ។ យើងត្រូវចេញទៅខាងក្រោយផ្ទះជាប្រចាំដើម្បីចាក់ទឹកនោះចោល ហើយយើងត្រូវជូតសំអាតអាហារចេញហើយយកចានទៅលាងនៅក្នុងបាញ់រ៉បន្ទប់ទឹកដើម្បីលាងវា។ បន្ទាប់មកយើងត្រូវសម្អាតបាញ់រ៉ញឹកញាប់ជាងមុន។" ឬ ចំពោះកន្លាតវិញ អ្នកជួលគួរនិយាយជាឧទាហរណ៍ដូចជា៖ "ខ្ញុំព្រួយបារម្ភថាកន្លាតនឹងចម្លងរោគ។ ខ្ញុំមានទារកតូចដែលត្រូវការវារលេងនៅលើឥដ្ឋ ហើយមានប្រដាប់ប្រដាក្មេងលេងនៅលើដី ហើយខ្ញុំមិនចង់ឲ្យកូនខ្ញុំប៉ះកន្លែងដែលកន្លាតវារលើទេ។"

E. សម្រាប់ភ័ស្តុតាងទាំងអស់ដូចជារបាយការណ៍ស្តីពីសុខភាព លិខិតអ្នកជួលផ្ញើទៅកាន់ម្ចាស់ផ្ទះ ។ល។ អ្នកជួលជាដំបូងនិងផ្ញើមួយច្បាប់ទៅ

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្តល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្តល់យោបល់ផ្នែកច្បាប់ដែរ។

កាន់ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះ ហើយបន្ទាប់មកផ្តល់ឯកសារទាំងនោះទៅដល់ចៅក្រម។ ជាថ្មីម្តងទៀត អ្នកជួលនឹងពន្យល់ទៅដល់ចៅក្រមថាឯកសារទាំងនោះជាអ្វី ហើយឯកសារអ្វីដែលជួយដល់អ្នកជួលបញ្ជាក់ជាភស្តុតាង។ បន្ទាប់ពីការពន្យល់ពីសារៈតារនេះ អ្នកជួលនឹងសុំឲ្យបញ្ចូលឯកសារទាំងនោះជា "ភស្តុតាងដាក់បន្ទុក។"

**ឧទាហរណ៍ 2**

ប្រសិនបើម្ចាស់ផ្ទះបានដាក់បណ្តឹងពីព្រោះតែគាត់ផ្តល់ការជូនដំណឹងដល់អ្នកជួលចំនួនបីថ្ងៃ នៅថ្ងៃទី3 នៃខែ ប៉ុន្តែអ្នកជួលព្យាយាមបង់ថ្លៃឈ្នួលនៅថ្ងៃទី 8នៃខែដែលជាពេលវេលាអ្នកជួលជាធម្មតាតែងតែបង់ថ្លៃឈ្នួលនោះ៖

A. អ្នកជួលជម្រាប់ដល់ចៅក្រមថា "ជាធម្មតាខ្ញុំបង់ថ្លៃឈ្នួលនៅថ្ងៃទី 8 នៃខែ ហើយម្ចាស់ផ្ទះទទួលយកវា។"
B. អ្នកជួលបង្ហាញដល់ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះ និងបន្ទាប់មកដល់ចៅក្រមនូវបង្កាន់ដៃបង់ប្រាក់ទាំងអស់ ដែលបញ្ជាក់ថាពួកគេតែងតែ ឬជាធម្មតាបានបង់ប្រាក់ថ្លៃឈ្នួលរបស់គេនៅថ្ងៃទី8 នៃខែ មិនមែននៅថ្ងៃទី1 នៃខែនោះទេ។
C. អ្នកជួលមានគំនូសតាងបង្ហាញជាស្រេចពីថ្ងៃដែលគេបានបង់ប្រាក់ឈ្នួលសម្រាប់ឆ្នាំចុងក្រោយ ឬច្រើនជាងនេះ និងជម្រាបដល់ចៅក្រមថាបង្កាន់ដៃបង់ប្រាក់នីមួយៗ និងកាលបរិច្ឆេទនៅលើគំនូសតាងតំណាងឲ្យពេលវេលានិងកាលបរិច្ឆេទដែលពួកគេបានបង់ប្រាក់ថ្លៃឈ្នួល។
D. អ្នកជួលស្នើសុំឲ្យបញ្ចូលបង្កាន់ដៃបង់ប្រាក់និងគំនូសតាងទាំងនោះចូលជាភស្តុតាង។

សម្គាល់៖ ម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះ នឹងអាចសួរដល់សាក្សី ឬ អ្នកជួលនូវសំណួរទាំងឡាយក្នុងការសួរដេញដោលសាក្សីគូបដិបក្ខទាក់ទងនឹងឯកសារ។

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្តល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្តល់យោបល់ផ្នែកច្បាប់ដែរ។

## ផ្នែក 3 – ទឡ្ហីករណ៍បិទបញ្ចប់

ក្រោយពីទាំងម្ចាស់ផ្ទះនិងអ្នកជួលបានបង្ហាញនូវករណីនិងការការពារទាំងមូល រួចហើយមក ចៅក្រមអាចនឹងអនុញ្ញាតឲ្យគូភាគីទាំងពីរធ្វើ "ការបញ្ជាក់ពីទឡ្ហីករណ៍បិទបញ្ចប់" ឬ សេចក្តីថ្លែងជាចុងក្រោយ។ នៅក្នុងសេចក្តីថ្លែងនេះ អ្នកជួលជម្រាប់ដល់អង្គចៅក្រម ឬ គណៈវិនិច្ឆ័យពីមូលហេតុទាំងឡាយដែលចៅក្រម ឬ អង្គវិនិច្ឆ័យគួរតែឯកភាពជាមួយពួកគេ និងមិនឯកភាពជាមួយនឹងម្ចាស់ផ្ទះ។ អ្នកជួលក៏អាចប្រើពេលវេលានេះដើម្បីបញ្ជាក់ដល់អង្គចៅក្រម ឬ គណៈវិនិច្ឆ័យពីអ្វីដែលអត្ថន័យភ័ស្តុតាងដែលពួកគេបានស្តាប់ ហើយពីមូលហេតុដែលវាសំខាន់ចំពោះការការពាររបស់ពួកគេ។ អ្នកជួលបញ្ជាក់ (1) ហេតុការណ៍ពិតទាំងឡាយ ដែលជាមូលហេតុម្ចាស់ផ្ទះមិនអាចផ្តល់ការបញ្ជាក់ការអះអាងរបស់ម្ចាស់ផ្ទះប្រឆាំងនឹងពួកគេ ហើយ (2) ហេតុការណ៍ពិតទាំងឡាយដែលគាំទ្រដល់ការការពាររបស់ពួកគេ។ អ្នកជួលបន្ទាប់មកសុំឲ្យអង្គចៅក្រម ឬ គណៈវិនិច្ឆ័យបដិសេធរឿងក្តីចោល។

## 7. ការសម្រេចចុងក្រោយនិងអ្វីដែលកើតឡើងបន្ទាប់

នៅក្នុងផ្នែកនេះ នឹងពន្យល់ពីរបៀបដែលគូភាគីទាំងពីរចាំមើលតើនរណាបានឈ្នះក្នុងរឿងក្តីបណ្តេញចេញ ហើយអ្វីដែលកើតឡើងនៅក្រោយពីការសម្រេចជាចុងក្រោយត្រូវបានធ្វើឡើង។

<u>សេចក្តីថ្លែងសម្រេចក្តី</u>

ក្រោយពីទឡ្ហីករណ៍បិទបញ្ចប់ត្រូវបានផ្តល់រួចមក អ្នកជួលអាចស្នើសុំអង្គចៅក្រមឲ្យចេញសេចក្តីសម្រេចក្តី។" សេចក្តីសម្រេចក្តី នឹងពន្យល់ពីមូលហេតុទាំងឡាយដែលអ្នកជួលបានឈ្នះ ឬ ចាញ់ក្តី។ អង្គចៅក្រមជាធម្មតាមិនតម្រូវឲ្យផ្តល់ការសម្រេចសេចក្តីជាលាយលក្ខណ៍អក្សរនោះទេនៅក្នុងការជំនុំជម្រះក្តីខ្លីជាងមួយថ្ងៃ ឬ 8ម៉ោង។ អ្នកជួលត្រូវស្នើសុំអង្គចៅក្រមឲ្យចេញសេចក្តីសម្រេចក្តីនៅមុនអង្គចៅក្រមសម្រេច (មានន័យថា នៅមុនពេលដែលចៅក្រមបញ្ជាក់ពីសេចក្តីសម្រេចរបស់គេ)។

<u>"សាលក្រម" ឬ "ដីកា"</u>

ចៅក្រម ឬ គណៈវិនិច្ឆ័យ នឹងជាធម្មតាសម្រេចទៅលើរឿងក្តីខណៈដែលអ្នកជួលនៅតែស្ថិតនៅក្នុងតុលាការ។ ប្រសិនបើមិននៅទេ អ្នកជួលនឹងត្រូវបានជូនដំណឹងតាមសំបុត្រ ដែលជាធម្មតាក្នុងរយៈពេលពីរឬបីថ្ងៃក្រោយការជំនុំជម្រះក្តី។ សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ឬ "ដីកា" នឹងរួមបញ្ចូលនូវចំណុចបួន៖

1. សេចក្តីថ្លែងដែលនឹងនិយាយថាអ្នកជួលត្រូវបានអនុញ្ញាតឲ្យស្នាក់នៅបន្តក្នុងផ្ទះរហូតដល់ (ប្រសិនបើអ្នកជួលឈ្នះក្តី) ឬ ថាអ្នកជួលត្រូវតែរើចេញ (អ្នកជួលចាញ់ក្តី)
2. ថាតើអ្នកជួលត្រូវតែបង់ប្រាក់ឈ្នួលសងវិញឬអត់

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្តល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្តល់យោបល់ផ្នែកច្បាប់ដែរ។

3. ថាតើភាគីខាងឈ្នះក្ដីអាចទទួលបានប្រាក់ពីភាគីខាងចាញ់ក្ដីសម្រាប់ថ្លៃតុលាការដែរឬទេ។ (ប្រសិនបើអ្នកជួលឈ្នះក្ដី ហើយចង់ឲ្យភាគីម្ខាងទៀតឲ្យបង់ថ្លៃចំណាយរបស់គេ ដែលពួកគេអាចទទួលបានចំណាយមកវិញតាមរយៈការបំពេញទម្រង់បែបបទមួយក្នុងរយៈពេល 10ថ្ងៃក្រោយការជំនុំជម្រះក្ដី។ ទម្រង់បែបបទនោះអាចរកបាននៅទីនេះ៖ https://www.courts.ca.gov/documents/mc010.pdf) និង
4. ថាតើភាគីខាងចាញ់ក្ដីត្រូវបង់ប្រាក់ទៅភាគីខាងឈ្នះក្ដីនូវថ្លៃមេធាវីដែរឬទេ។ ករណីនេះ អាចកើតឡើងទៅបាន ប្រសិនបើមានកិច្ចសន្យាជួលជាលាយលក្ខណ៍អក្សររវាងម្ចាស់ផ្ទះនិងអ្នកជួល ដែលតម្រូវឲ្យមានការចំណាយរបៀបនេះ ហើយភាគីឈ្នះក្ដីបានជួលមេធាវី។ អ្នកជួលមិនទទួលបានថ្លៃមេធាវីទេ ប្រសិនបើពួកគេតំណាងឲ្យខ្លួនឯងនោះ។

**<u>ប្រយ័ត្ន៖</u>** អ្នកជួលត្រូវតែអានដីកាបង្គាប់តុលាការដោយប្រុងប្រយ័ត្នព្រោះថា បើទោះបីជាគេ "ឈ្នះ" នៅថ្ងៃជម្រះក្ដីក៏ពិតមែន តែតុលាការនៅតែអាចចេញដីកាបង្គាប់ឲ្យពួកគេចាត់ការផ្សេងទៀតដើម្បីបញ្ចៀសការបណ្ដេញចេញ។ ឧទាហរណ៍ សាលដីកាអាចនឹងតម្រូវឲ្យអ្នកជួលសងប្រាក់ឈ្នួលវិញទៅតាមកាលបរិច្ឆេទកំណត់ជាក់លាក់ ហើយប្រសិនបើពួកគេមិនសងទេ អ្នកជួលអាចនៅតែត្រូវបានបណ្ដេញចេញបើទោះបីជាពួកគេ "ឈ្នះ" ក្ដីរបស់គេក៏ដោយ។ ប្រសិនបើអ្នកជួលមានពិការភាព មិនយល់ពីអ្វីដែលមានចែងនៅក្នុងសាលដីការបស់គេទេ ពួកគេអាចទូរសព្ទមកកាន់ DRC ដើម្បីសុំជំនួយក្នុងការយល់ពីខ្លឹមសារដែលមានចែងនៅក្នុងដីកាបង្គាប់តុលាការនោះ។

<u>ឈ្នះ ឬ ចាញ់ អ្វីទៅបន្ទាប់?</u>

ឧទាហរណ៍នៃ "ការឈ្នះ" ការជំនុំជម្រះ៖

- ចៅក្រមមានប្រសាសន៍ថា អ្នកជួលត្រូវបានអនុញ្ញាតឲ្យបន្តស្នាក់នៅក្នុងផ្ទះពីព្រោះតែពួកគេបានបញ្ជាក់ពីការការពាររបស់គេនៃការបំពានលើការរ៉ាប់រងនៃការស្នាក់នៅ ប៉ុន្តែចៅក្រមបានចេញដីកាបង្គាប់ឲ្យពួកគេបង់ប្រាក់មួយចំណែកនៃថ្លៃឈ្នួលត្រូវសងក្នុងរយៈពេល 5ថ្ងៃ។
    - ប្រសិនបើអ្នកជួលបង់ប្រាក់ឈ្នួលសងទាន់ពេល (ហើយទទួលបានបង្កាន់ដៃបង់ប្រាក់) អ្នកជួលនឹងឈ្នះក្តី ហើយនឹងមិនត្រូវរើចេញឡើយ។
    - ប្រសិនបើអ្នកជួលមិនបង់ថ្លៃឈ្នួលសងទាន់ពេលទេនោះ ម្ចាស់ផ្ទះនឹងឈ្នះក្តី ហើយអ្នកជួលនឹងត្រូវតែរើចេញ។ (សូមមើលផ្នែកនិយាយពីការជូនដំណឹងឲ្យចាកចេញខាងក្រោម។)

ឧទាហរណ៍នៃ "ការចាញ់" ក្តី៖
ប្រសិនបើអ្នកជួល "ចាញ់" ក្តី ម្ចាស់ផ្ទះនឹងទទួលបាននូវសាលក្រមនៃការកាន់កាប់" ដែលផ្តល់ការកាន់កាប់ទៅលើផ្ទះទៅដល់ម្ចាស់ផ្ទះរបស់គេ។ អ្នកជួលស្ថិតក្នុងស្ថាននេះមានពីរបីជម្រើស៖

1. ពួកគេអាចសុំពេលវេលាបន្ថែមទៀត។
    - ប្រសិនបើចៅក្រមប្រាប់ដល់អ្នកជួលក្នុងបន្ទប់សវនាការថា ពួកគេនឹងត្រូវ "បណ្តេញចេញ" ឬ ត្រូវតែរើចេញនោះ អ្នកជួលអាចសុំទៅចៅក្រមនៅពេលនោះភ្លាមនូវពេលវេលាបន្ថែមទៀតមុននឹងពួកគេត្រូវរើចេញ។ ដើម្បីធ្វើបែបនេះបាន អ្នកជួលអាចនិយាយថា៖ "អង្គតុលាការជាទីគោរព ខ្ញុំសូមស្នើសុំពេល 30ថ្ងៃដើម្បីចេញ។" ការបន្ថែមពេលវេលារើចេញហៅថា "ការពន្យាពេលការអនុវត្ត" នៃសាលដីកាតុលាការ។ (សូមបើលទំព័រទី 11)។
    - អ្នកជួលគួរតែត្រៀមពន្យល់ពីមូលហេតុដែលពួកគេត្រូវការពេលវេលាបន្ថែមដើម្បីរើចេញ។ សម្គាល់៖ អ្នកជួលអាចត្រូវបង់

ថ្លៃឈ្នួលបន្ថែមទៅឲ្យម្ចាស់ផ្ទះសម្រាប់ពេលវេលាស្នាក់នៅបន្ថែមក្នុងផ្ទះ។
    - បើទោះជាចៅក្រមមិនផ្ដល់ឲ្យអ្នកជួលនូវពេលវេលាបន្ថែមក៏ពិតមែន តែអ្នកជួលមិនចាំបាច់រើចេញនៅក្នុងថ្ងៃជាមួយនឹងការជំនុំជម្រះក្ដីរបស់គេដែរ។ (សូមមើលដូចខាងក្រោមទាក់ទងនឹងសេចក្ដីជូនដំណឹងឲ្យចាកចេញ។)
2. អ្នកជួលអាចស្នើសុំ "ការសង្គ្រោះពីការរឹបអូស" ប្រសិនបើសមស្រប។ (សូមបើលទំព័រទី 11)។
3. អ្នកជួលអាចស្នើសុំសាលដីកាបិទបញ្ចប់ក្ដី ដើម្បីឲ្យការបណ្ដេញចេញមិនបង្ហាញនៅលើកំណត់ត្រាឥណទានរបស់គេ។

<u>សេចក្ដីជូនដំណឹងពីការចាកចេញ</u>

សេចក្ដីជូនដំណឹងពីការចាកចេញជាក្រដាសពណ៌សដោយសរសេរអក្សរពណ៌ក្រហម ដែលនិយាយថា អ្នកជួលមានពេល<u>ប្រាំថ្ងៃ</u>ដើម្បីរើចេញ ហើយបញ្ជាក់ពីកាលបរិច្ឆេទដែលអ្នកជួលត្រូវរើចេញ។ អ្នកជួលនឹងមិនទទួលបាននូវការជូនដំណឹងពីការត្រូវចាកចេញរហូតដល់ក្រោយពេលដែលពួកគេចាញ់ក្ដី។ ប៉ូលីសនឹងបិទសេចក្ដីជូនដំណឹងនេះនៅលើទ្វារផ្ទះរបស់អ្នកជួល។

ក្រោយពីប៉ូលីសបិទសេចក្ដីជូនដំណឹងត្រូវចាកចេញលើទ្វារផ្ទះអ្នកជួលរួចមក អ្នកជួលកំពុងស្ថិតនៅក្នុងរជូនដំណឹង ដែលអ្នកជួលនឹងត្រូវតែរើចេញនៅពេលពេលប៉ូលីសនិយាយថាអ្នកជួលត្រូវរើចេញនោះ។

ប្រសិនបើអ្នកជួលត្រូវការសុំពេលពីរបីថ្ងៃបន្ថែមទៀតស្នាក់នៅក្នុងផ្ទះរបស់គេ ហើយម្ចាស់ផ្ទះរបស់គេយល់ព្រមនោះ អ្នកជួលចាំបាច់ត្រូវទទួលបានការអនុញ្ញាត

នេះជាលាយលក្ខណ៍អក្សរ រក្សាទុកការអនុញ្ញាតនេះជាស្រេចដើម្បីបង្ហាញដល់ប៉ូលីស និងត្រូវតែប្រាកដថាម្ចាស់ផ្ទះជូនដំណឹងដល់ប៉ូលីសផងដែរ។ អ្នកជួលក៏អាចទូរសព្ទទៅកាន់ប៉ូលីសដើម្បីបញ្ជាក់ថាម្ចាស់ផ្ទះរបស់គេបានជូនដំណឹងដល់ប៉ូលីសហើយ។

នៅពេលប៉ូលីសមកដល់ ប៉ូលីសនឹងគ្រាន់តែផ្តល់ដល់អ្នកជួលពីរបីនាទីដើម្បីចាកចេញពីផ្ទះតែប៉ុណ្ណោះ ដូច្នេះអ្នកជួលនឹងមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីរើចេញនូវគ្រឿងសង្ហារឹម ឬទ្រព្យរបស់ផ្សេងទៀតឡើយ។ វាទំនងជានឹងមិនជាបញ្ហាទេ ប្រសិនបើពួកគេមានកូនៗ ដែលមានពិការភាព ឬមានជំងឺនោះ។ ពួកគេនឹងត្រូវតែចាកចេញពីផ្ទះរបស់គេភ្លាមៗ។

ប្រសិនបើរបស់ទ្រព្យរបស់អ្នកជួលមិនទាន់ត្រូវបានរើចេញពីផ្ទះនៅមុនពេលប៉ូលីសមកដល់ទេនោះ ម្ចាស់ផ្ទះរបស់ពួកគេនឹងទំនងជារក្សាទុករបស់ទ្រព្យឲ្យគេ ហើយអ្នកជួលនឹងត្រូវតែបង់លុយសងដើម្បីអាចយករបស់ទ្រព្យគេបាន។ ប្រសិនបើអ្នកជួលមិនរើរបស់ទ្រព្យគេចេញនៅមុនពេលប៉ូលីសចាក់សោរបិទ ហើយពួកគេចង់ការពាររបស់ទ្រព្យពួកគេពីការបោះចោលនោះ អ្នកជួលអាចសរសេរលិខិតទៅកាន់ម្ចាស់ផ្ទះ<u>ក្នុងរយៈពេល 18ថ្ងៃនៃការការចាក់សោរបិទ។</u> អ្នកជួលគួរចុះកាលបរិច្ឆេទលើលិខិតនៅថ្ងៃដែលអ្នកជួលសរសេរលិខិតនោះ រក្សាទុកលិខិតនោះមួយច្បាប់សម្រាប់ខ្លួនឯង ផ្ញើមួយច្បាប់តាមសេវាបញ្ជូនលិខិតដែលមានការបញ្ជាក់ ឬ ការយកលិខិតនោះទៅជូនដោយផ្ទាល់ដៃ ហើយចែងតម្រូវក្នុងលិខិតនោះតម្រូវឲ្យម្ចាស់ផ្ទះចុះហត្ថលេខាលើច្បាប់របស់អ្នកជួលបញ្ជាក់ថាគេបានទទួលវា។

នេះជាលិខិតគំរូ៖

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្តល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្តល់យោបល់ផ្នែកច្បាប់ដែរ។

(កាលបរិច្ឆេទ)

គោរពជូន (អ្នកគ្រប់គ្រង/ឈ្មោះម្ចាស់ផ្ទះ)៖

ខ្ញុំមិនអាចយករបស់របរទាំងអស់របស់ខ្ញុំចេញបាននៅមុនថ្ងៃដែលខ្ញុំត្រូវរើចេញនោះទេ។ [បញ្ជី ឬ ការរៀបរាប់ពីរបស់ទ្រព្យដែលនៅសល់។] សូមមេត្តាកុំបោះរបស់ទ្រព្យខ្ញុំចោល។ ខ្ញុំនឹងទាក់ទងអ្នកភ្លាមដើម្បីកំណត់ពេលមកយករបស់របរខ្ញុំ។

សូមអរគុណ

(ឈ្មោះរបស់អ្នក)
(អាសយដ្ឋាន)

ទោះជាយ៉ាងណាក៏ដោយ អ្នកជួលអាចនៅតែត្រូវបង់ប្រាក់ទៅដល់ម្ចាស់ផ្ទះដើម្បីមកយករបស់ទ្រព្យគេវិញ។ ម្ចាស់ផ្ទះមិនអាចគិតថ្លៃច្រើនជាង "ថ្លៃរើចេញសមស្រប" និង ថ្លៃឈ្នួលផ្ទះប្រចាំថ្ងៃសម្រាប់ថ្ងៃនីមួយដែលម្ចាស់ផ្ទះរក្សាទុករបស់ព្រទ្យពួកគេទេ។ អ្នកជួលនឹងចាំបាច់ត្រូវផ្តល់ដល់ម្ចាស់ផ្ទះនូវអាសយដ្ឋាន និងទីកន្លែងដែលគេអាចទទួលលិខិតបានសម្រាប់ម្ចាស់ផ្ទះផ្ញើការទារប្រាក់ថ្លៃឈ្នួល។

**ប្រយ័ត្ន៖** ប្រសិនបើអ្នកជួលមិនផ្តល់លិខិតទៅដល់អ្នកគ្រប់គ្រង/ម្ចាស់ម្ចាស់ផ្ទះទេ អ្នកគ្រប់គ្រង/ម្ចាស់ផ្ទះអាចនឹងអះអាងបានថាអ្នកជួលបានបោះបង់ទ្រព្យសម្បត្តិរបស់គេចោល។

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្តល់យោបល់ផ្នែកច្បាប់ទេ ហើយក៏មិនជំនួសឱ្យការផ្តល់យោបល់ផ្នែកច្បាប់ដែរ។

## 8. ការទទួលសមស្របនៅក្នុងតុលាការ៖

<u>តើការទទួលសមស្របនៅក្នុងតុលាការជាអ្វី?</u>

ការទទួលសមស្របជាការផ្លាស់ប្តូរនៅក្នុងការអនុវត្ត គោលនយោបាយ ឬ នីតិវិធី ដែលអនុញ្ញាតឲ្យបុគ្គលមានពិការភាពពេញចិត្តនូវការទទួលបានដោយស្មើភាព ចំពោះដំណើរការនីតិវិធីក្តីនៅក្នុងតុលាការ។

<u>ហេតុអ្វីបានជាអ្នកជួលអាចនឹងចាំបាច់ត្រូវស្នើសុំនូវការទទួលមួយសមស្រប?</u>

អ្នកជួលអាចនឹងចាំបាច់ត្រូវស្នើសុំការទទួលមួយសមស្រប ពីព្រោះមួយនៃ ពិការភាពរបស់គេអាចនឹងរារាំងពួកគេមិនឲ្យធ្វើជាសាក្សីនៅក្នុងតុលាការបាន បង្ហាញខ្លួននៅក្នុងរឿងក្តីរបស់គេនៅតុលាការបាន ឬ ចូលរួមនៅក្នុង ដំណើរការនីតិវីតុលាការតាមមធ្យោបាយផ្សេងៗ។

ឧទាហរណ៍ អ្នកជួលដែលមានពិការភាពអាចនឹងចាំបាច់ត្រូវញ៉ាំអាហារក្នុង ខណៈកំពុងស្ថិតនៅក្នុងបន្ទប់សវនាការ ឬ បុគ្គលដែលមានបញ្ហាភ្នែកអាចនឹង ចាំបាច់ត្រូវការអ្នកជួយដើម្បីជួយពួកគេក្នុងការទំនាក់ទំនងជាមួយនឹងបុគ្គលិក តុលាការ។ អ្នកផ្សេងដែលមានពិការភាព អាចនឹងត្រូវការឲ្យតុលាការផ្តល់ ឧបករណ៍ជំនួយការស្តាប់ ឬអាន ឬអាចនឹងត្រូវការឲ្យតុលាការ កំណត់សវនាការឡើងវិញទៅកាន់បន្ទប់សវនាការណាមួយដែលងាយស្រួល ចេញចូលជាង។

អ្នកមានពិការភាពខ្លះ អាចនឹងមានសមត្ថភាពស្នើសុំឱ្យលើកកាលបរិច្ឆេទ សវនាការដោយសារតែការទទួល ឧទាហរណ៍ ពិការភាពរបស់គេប៉ះពាល់ដល់ សមត្ថភាពគេត្រូវបង្ហាញខ្លួននៅក្នុងតុលាការ។ ទោះជាយ៉ាងណា វាមិនត្រូវបាន ធានាថាតុលាការនឹងអនុញ្ញាតការទទួលជាពិសេសនេះទេ ហើយលើកលែងតែ មានឯកសារជាលាយលក្ខណ៍អក្សរបញ្ជាក់ថា ការលើកពេលត្រូវបានអនុញ្ញាត

ឯកសារបោះពុម្ពផ្សាយនេះមិនមែនជាការផ្តល់យោបល់ផ្នែកច្បាប់ទេ ហើយក៏ មិនជំនួសឱ្យការផ្តល់យោបល់ផ្នែកច្បាប់ដែរ។

បើមិនអញ្ជើងទេអ្នកជួលនៅតែទៅចូលរួមសវនាការរបស់គេតាមកាលវិភាគកំណត់ពីមុនមកដដែល។

## តើអ្នកជួលស្នើសុំនូវការទទួលសមស្របមួយតាមរបៀបណា?

អ្នកជួលអាចស្នើសុំឲ្យមានការទទួលដោយសមស្របមួយនៅក្នុងតុលាការដោយបំពេញនិងដាក់បញ្ជូននូវទម្រង់ “MC-410” ទៅកាន់អ្នកសម្របសម្រួល ADA របស់សាលាក្តីក្នុងមូលដ្ឋានរបស់គេ។ ទម្រង់នេះមាននៅលើគេហទំព័រនេះ៖ https://selfhelp.courts.ca.gov/jcc-form/MC-410. នេះជាសេចក្តីណែនាំនានាពីរបៀបត្រូវបំពេញវា៖ https://selfhelp.courts.ca.gov/jcc-form/MC-410-INFO. ទម្រង់នេះត្រូវបានចាត់ជាព័ត៌មានសម្ងាត់ហើយមិនត្រូវបានផ្តល់ទៅឲ្យម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះឡើយ។ ប្រសិនបើតុលាការចង់បានព័ត៌មានបន្ថែម អ្នកជួលអាចស្នើសុំឲ្យចែករំលែកព័ត៌មាននេះជាមួយនឹងចៅក្រមជាលក្ខណ:ឯកជន ឬ ដោយពុំមានម្ចាស់ផ្ទះ/មេធាវីម្ចាស់ផ្ទះ និងអ្នកផ្សេងនៅក្នុងបន្ទប់សវនាការស្តាប់ឮ ព័ត៌មានឡើយ។

## តើនេះវាខុសអ្វីពីការទទួលសមស្របនៅខាងក្រៅតុលាការនោះ?

ពិតជាខុសគ្នា ប្រសិនបើអ្នកជួលបានទទួលនូវការទទួលមួយសមស្របពីនិយោជករបស់គេ ឬ ម្ចាស់ផ្ទះ ឬបុគ្គលផ្សេង ឬនីតិបុគ្គលនោះ ពួកគេអាចចង់ស្នើសុំនូវការទទួលប្រហាក់ប្រហែលគ្នាទៅនឹងការចូលរួមនៅក្នុងតុលាការដែរ។ សម្រាប់ព័ត៌មានបន្ថែម អ្នកជួលក៏អាចចូលមើលតំណភ្ជាប់ខាងក្រោម៖
https://www.courts.ca.gov/14362.htm និង
https://www.courts.ca.gov/documents/Disability-Accommodations-in-California-Courts.pdf.